ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ



# សមិទ្ធផល១០ឆ្នាំ
## នៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន
## ២០១៤-២០២៤

២០២៤

# ស្ថានភាពបណ្តុះបណ្តាលគ្រូបង្រៀនមុនឆ្នាំ២០១៤

## ១-ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន




## ២- គុណវុឌ្ឍិគ្រូឧទ្ទេស និងគ្រូបង្រៀននៅមានកម្រិត







| ១៩៧៩-១៩៨៦ | ១៩៨៦-១៩៩៦ |
|---|---|
| ប្រព័ន្ធអប់រំ ៤+៣+៣ | ប្រព័ន្ធអប់រំ ៥+៣+៣ |

## ៣- ចំនួនបាត់បង់មន្ត្រីរាជការពីក្របខ័ណ្ឌធៀបនឹងចំនួនក្របខ័ណ្ឌថ្មីដែលទទួលបាន







## ៤- អាជីពជាគ្រូបង្រៀននៅមិនទាន់មានភាពទាក់ទាញសម្រាប់សិស្សរៀនពូកែ

គុនិស្សិតជាង៨០ភាគរយជាសិស្សដែលទទួលបាននិទ្ទេស D ឬ E
ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ប្រាក់បៀវត្សរ៍គ្រូបង្រៀនវិទ្យាល័យ អប្បបរមា ៦២៩ ១៨០រៀល
អតិបរមា ១ ០៩០ ១១០ រៀល



ប្រាក់បៀវត្សរ៍គ្រូបង្រៀនបឋមសិក្សា អប្បបរមា ៣១០ ៨០០រៀល
អតិបរមា ៥៣៧ ០៣០ រៀល

ប្រាក់អាហារូបករណ៍មិនអាចផ្គត់ផ្គង់ជីវភាពបាន

## ៥-ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅមិនទាន់ឆ្លើយតប និងមិនទាន់ជាប្រព័ន្ធ

១៩៩៦

ប្រព័ន្ធអប់រំ ៦+៣+៣

២០១៣

គោលនយោបាយស្តីពី
គ្រូបង្រៀន

# កំណែទម្រង់គ្រូបង្រៀនពីឆ្នាំ២០១៤ដល់ឆ្នាំ២០២៤

## ១- ការពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រង

- ការប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងបង្រួមការផ្ទេរទៅវិទ្យាស្ថានគរុកោសល្យ
- ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស
- ការប្រែក្លាយវិទ្យាស្ថានជាតិអប់រំជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ
- ការផ្ទេរការគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងសាលាអនុវត្តទាំងអស់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា

## ២- ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីវិក្រឹតការ

- អនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន (១២+៤) សម្រាប់គ្រូបឋមសិក្សា និងគ្រូកម្រិតមូលដ្ឋាន
- បញ្ចូលវិធីសាស្ត្រ កញ្ចប់អំណានដំបូង និងគណិតដំបូង ក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ បឋមសិក្សា
- អនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ+១ សម្រាប់គ្រូកម្រិតមូលដ្ឋាន
- អនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ+២ សម្រាប់គ្រូកម្រិតឧត្តម
- បញ្ចូលវិធីសាស្ត្របង្រៀនសាលាជំនាន់ថ្មីក្នុងកម្មវិធីបណ្តុះបណ្តាលគ្រប់កម្រិត
- បញ្ចូលរង្វាយតម្លៃជាតិ តំបន់ និងអន្តរជាតិក្នុងកម្មវិធីសិក្សា
- អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)

## ៣- ការអភិវឌ្ឍគុណវុឌ្ឍិគ្រូឧទ្ទេស និងគណៈគ្រប់គ្រង







1. និងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈ ឱ្យប្រកបវិជ្ជាជីវៈគ្រូបង្រៀន
2. ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន
3. ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ
4. ធានាលក្ខខណ្ឌចាំបាច់សម្រាប់គ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ

01 បង្កើតវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង

02 ការបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យតាមប្រព័ន្ធ ១២+៤

03 លើកកម្ពស់លក្ខខណ្ឌការងារ និងរស់នៅរបស់គ្រូបង្រៀនតាមការដំឡើងប្រាក់បៀវត្ស

04 ទទួលស្គាល់ស្នាដៃការងារ និងផ្តល់ជារង្វាន់




**២០១៥** — ផែនការគោលនយោបាយស្តីពីគ្រូបង្រៀន

**២០១៦** — ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

**២០១៧** — ស្តង់ដានាយកសាលាគរុកោសល្យ គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

## ៤- ការជ្រើសរើសគរុសិស្សប្រកបដោយសក្ដានុពល និងការលើកកម្ពស់ការរស់នៅរបស់គ្រូឧទ្ទេស

- ចាប់ពីឆ្នាំ២០២៣ គរុសិស្ស-និស្សិត ក៏បានទទួលប្រាក់ឧបត្ថម្ភចំនួន ៧០% នៃប្រាក់បៀវត្សរ៍សរុប

កំណើនប្រាក់បៀវត្សរ៍គ្រូបង្រៀនអប្បរមា
ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤



កំណើនប្រាក់បៀវត្សរ៍គ្រូបង្រៀនអតិបរមា
ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤






## ៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ



## ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននាពេលបច្ចុប្បន្ន




**២០១៨**

ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន

**២០១៩**

ក្របខ័ណ្ឌ និងផែនការសកម្មភាពការអភិវឌ្ឍ
វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា

# គោលដៅអនាគត













២០២៤

ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០
ស្តង់ដាវិជ្ជាជីវៈគ្រូឧត្តម
ស្តង់ដាសាលាគរុកោសល្យគំរូ


អ្នកឯកទេសអប់រំ
ឆ្នើម
នាយកសាលា
ឈានមុខ

# បុព្វកថា

គ្រូបង្រៀនគឺជាបេះដូងនៃការអប់រំ ពោលគឺជាអ្នកធានាឱ្យបាននូវគុណភាពអប់រំ និងជាអ្នកតម្រង់ទិសកុមារ និងយុវជនកម្ពុជាទាំងអស់ឱ្យក្លាយជាពលរដ្ឋពេញលេញ ព្រមទាំងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេស ឱ្យឈានទៅកាន់ប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ ស្របតាមយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យនេះ ចាប់ពីឆ្នាំ២០១៤ មក ក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់យក **កំណែទម្រង់សាលាគរុកោសល្យ** ជាអាទិភាពមួយរបស់ក្រសួង ដោយផ្តោតសំខាន់ទៅលើ ១) ការរៀបចំចក្ខុវិស័យថ្មីសម្រាប់វិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា ២) ការកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ៣) ការដំឡើងបៀវត្សរ៍ និងការបង្កើនគុណវុឌ្ឍិគ្រូ ៤) ការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ជាពិសេសការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន និងរៀន សំដៅឈានទៅបង្កើនលទ្ធផលសិក្សារបស់សិស្សឱ្យកាន់តែប្រសើរឡើង។

លទ្ធផលគួរជាទីមោទនៈនៃកំណែទម្រង់ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ អាចសម្រេចជាផ្លែផ្កាដោយមានការចូលរួម ប្រកបដោយស្មារតីទទួលខុសត្រូវពីបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ក្រសួងពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍនានា គ្រឹះស្ថានអប់រំរដ្ឋ និងឯកជនទាំងគ្រឹះស្ថានដែលអនុវត្តកម្មវិធីសិក្សាជាតិ និងអន្តរជាតិ និងសាកលវិទ្យាល័យនានាដែលទទួលបន្ទុកក្នុងការងារអប់រំគ្រូបង្រៀនទាំងក្នុង និងក្រៅប្រទេស ដើម្បីទទួលបានកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ ទាំងការគាំទ្រលើការលើកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីសិក្សាគុណវុឌ្ឍិគ្រូឧទ្ទេស និងគ្រូបង្រៀន វិធីសាស្ត្របង្រៀន ការរៀបចំផែនការយុទ្ធសាស្ត្រ និងចែករំលែកឧត្តមានុវត្តន៍ជាដើម ។ល។

*សមិទ្ធផលទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបន្តអភិវឌ្ឍវិស័យអប់រំឱ្យឈានទៅប្រកួតប្រជែងទាំងកម្រិតតំបន់ និងពិភពលោក ក្នុងទិសដៅប្រែក្លាយកម្ពុជាជាសង្គមពុទ្ធិ និងវិបុលភាព។*

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

គ្រូបង្រៀនគឺជាបេះដូងនៃប្រព័ន្ធអប់រំ។ ក្រៅពីការបង្រៀន គ្រូត្រូវត្រាយផ្លូវដល់សិស្សានុសិស្សក្នុងការប្រើប្រាស់ចំណេះដឹងនិងបំណិនក្នុងជីវិតនិងសហគមន៍ ជួយដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចផងដែរ។ កំណែទម្រង់វិស័យអប់រំរបស់ក្រសួង អប់រំ យុវជន និងកីឡា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះបានបន្តផ្តល់តួនាទីស្នូលដល់គ្រូបង្រៀន និងទទួលស្គាល់ថាការវិនិយោគលើគ្រូបង្រៀន រួមមានការអប់រំ បណ្តុះបណ្តាល គុណវុឌ្ឍិ បំណិន និងសុខុមាលភាពគ្រូបង្រៀន គឺជាគន្លឹះដ៏សំខាន់សម្រាប់ជំរុញបរិវត្តកម្មវិស័យអប់រំ។

អង្គការយូណេស្កូ (UNESCO) ដែលជាភ្នាក់ងារនាំមុខលើសាកលលោក ផ្នែកការអប់រំនិងអភិវឌ្ឍគ្រូបង្រៀន មានកិត្តិយសខ្ពស់ដែលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងដំណើរការបរិវត្តកម្មនេះ។ តាមរយៈកិច្ចសហការទាំងនេះ យើងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន រួមមានការចូលរួមរៀបចំគោលនយោបាយគ្រូបង្រៀន កែលម្អការបណ្តុះបណ្តាលគ្រូដំបូង បង្កើតប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនដំបូងបង្អស់នៅប្រទេសកម្ពុជា និងបរិវត្តកម្មការរៀននិងបង្រៀននៅកម្រិតថ្នាក់ដំបូងតាមរយៈវិក្រឹតការគ្រូបង្រៀន។ អង្គការយូណេស្កូមានមោទនៈភាពដែលបានចូលរួមគាំទ្រកំណែទម្រង់នេះតាមរយៈកម្មវិធីអប់រំគ្រូបង្រៀនរបស់យើង និងបានរៀបចំកិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធ ស្តីពីគ្រូបង្រៀននិងគោលនយោបាយយុទ្ធសាស្ត្រសម្រាប់វិស័យអប់រំ។

ការចងក្រងសមិទ្ធផលទាំងនេះជាឱកាសសម្រាប់យើងទាំងអស់គ្នាឆ្លុះបញ្ចាំងពីវឌ្ឍនភាព បញ្ហាប្រឈមដែលបានដោះស្រាយ និងចក្ខុវិស័យរួមសម្រាប់ជំហានបន្ទាប់ទៀត។ សមិទ្ធិផលទាំងនេះគឺជាសក្ខីភាពមួយបង្ហាញពីលទ្ធផលជាទីមោទនៈនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ ក្នុងការពង្រឹងការអភិវឌ្ឍគ្រូបង្រៀន។ អង្គការយូណេស្កូ សូមកោតសរសើរខ្ពស់ចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន និងថ្នាក់ដឹកនាំក្រសួង អប់រំ យុវជន និងកីឡា សម្រាប់កិច្ចខិតខំប្រឹងប្រែងគួរឱ្យស្ញប់ស្ញែងក្នុងដំណើរការនេះ។ យើងសូមអបអរសាទរដល់គ្រូបង្រៀនទាំងអស់ទូទាំងប្រទេសកម្ពុជា ដែលបានបំពេញការងារដោយស្វិតស្វាញនិងយកចិត្តទុកដាក់ខ្ពស់។

ក្នុងដំណើរឆ្ពោះទៅមុខ យើងមានចក្ខុវិស័យរួមមួយដ៏ច្បាស់ ពោលគឺបន្តពង្រឹងសមត្ថភាព និង លើកកម្ពស់ឋានៈគ្រូបង្រៀននៅកម្ពុជា ដើម្បីផ្តល់ឱកាសដល់គ្រូបង្រៀនធ្វើការផ្លាស់ប្តូរជាវិជ្ជមាន និង សម្រេចបាននូវនវានុវត្តន៍ក្នុងការបង្រៀន និងបំផុសគំនិតសិស្សានុសិស្សឆ្ពោះទៅរកការសម្រេចបាន នូវចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ ២០៥០។

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៦ កញ្ញា ឆ្នាំ២០២៤

តំណាងអង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា

UNITED NATIONS EDUCATIONAL, SCIENTIFIC AND CULTURAL ORGANIZATION
UNESCO
CAMBODIA

លោក សាដា អ៊ូម៉ា អាឡាម

**ដឹកនាំការផលិតដោយ៖** *ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន*

**ប្រឹក្សាយោបល់ដោយ៖** *លោកជំទាវ គឹម សេដ្ឋានី, ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា, លោកបណ្ឌិត ខាន់ បូផាន់, ឯកឧត្តមបណ្ឌិត សិត សេង, លោកបណ្ឌិត សំ ច័ន្ទកិរុណា, ឯកឧត្តមបណ្ឌិត ជា រដ្ឋា, ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា, ឯកឧត្តមបណ្ឌិត ឌី ខាំបូលី, លោកជំទាវ នាង ផល្លា, លោក ហ៊ិត ស៊ីនួន, លោក ង៉ោ ប៉េងឡុង, លោកបណ្ឌិត ឈូក ច័ន្ទធាយា, លោក ឡុង សុវត្ថិ, លោក ចាន់ តុលា, លោក សេង សំអុល, លោក ង៉ួន សំអុល, លោក ថ្វាង សន្តំ, លោក សោភ័ណ សុភ័ក្ត្រ*

**រៀបរៀងដោយ៖** *លោកជំទាវបណ្ឌិត ឃួន វិច្ឆិកា*

**ត្រួតពិនិត្យ និងកែលម្អដោយ៖**

*បុគ្គលិកនៃនាយកដ្ឋានកិច្ចការបណ្តុះបណ្តាល៖ លោក ធឹង យ៉ុង, លោកស្រី គ័រ ឈុនធាយ, លោកស្រី អ៊ាង សេងលីម, លោក ប៉េង ប៊ុនថន, លោកស្រី ម៉េះ ចាន់ថេត, លោក ឌុច សុខនាង, លោក ងិន រិត, លោក ថ្វាង ផាន់ណារ៉ា, លោក ជាប សារិន, លោក អុក វាន វិទ្យា, លោក ហួត បញ្ញាឫទ្ធិ, លោក មួង ចាន់ទូច, លោកស្រី ផន សុភា, លោក ធាន វាសនា, លោក សុខ សារឿន, លោកស្រី ណៃត ពេជ្រចិន្ដា, លោក លឹម សេង, លោក ហែម សុខល័ក្ខ, លោក ជា ផុន, លោកស្រី តាន់ លីហួង, បុគ្គលិកនៃនាយកដ្ឋានកិច្ចការវិក្រឹតការ ៖ លោក លី គាង, លោក លាង ស៊ុនហ៊ាង, លោកស្រី ម៉ៅ ណារី, លោក ភាង ប៊ុនណៃ, លោកស្រី សៀក សុខនី, លោក ជា ចាន់ធូ, លោក ឈុន រិទ្ធី, លោក សុភាព វណ្ណកក្ដី ព្រមទាំងបុគ្គលិកនៃលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ៖ លោក ឌុយ សុភាក់, លោក លាង សម្បត្តិ, និងកញ្ញា ហេង កន្និថា*

**រៀបចំរចនាទំព័រដោយ៖** *លោក ហួត សារិទ្ធ*

**រៀបចំរចនាទំព័រកាលប្បវត្តិដោយ៖** *លោក ឡៃ រក្សា, កញ្ញា ហេង លីហ័រ, លោក រ៉េន ភារៈ, លោក ស៊ុំ ថាច*

**រូបភាព និងរូបគំនូរដោយ៖** *វិទ្យាស្ថានជាតិអប់រំ, វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, វិទ្យាស្ថានគរុកោសល្យបាត់ដំបង, វិទ្យាស្ថានជាតិអប់រំពិសេស, មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤, សាលាគរុកោសល្យនិងវិក្រឹតការខេត្តទាំង១៦ និង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម, សាលាអនុវត្តន៍ទាំង២៤, នាយកដ្ឋានបឋមសិក្សា, លោក ខែម ចន្ធូ, លោក សេង វិសាល*

**គាំទ្រការរៀបរៀងដោយ៖** *លោកស្រី សំបាត់ អ៊ាត, លោកស្រី ហ៊ំ ស៊ីរី, លោកស្រី ជិត ចាន់វន្នី, កញ្ញា ថ្វាង សូរិយា, កញ្ញា សន សារី, កញ្ញា ញឹប ភារី*

*អគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ*
*នៃក្រសួងអប់រំ យុវជន និងកីឡា*
*២០២៤*

# មាតិកា

**១. ស្ថានភាពការបណ្តុះបណ្តាលគ្រូមុនឆ្នាំ២០១៤** .......... ១៥
**២. សមិទ្ធផលនៃកំណែទម្រង់សាលាគរុកោសល្យក្នុងរយៈពេល ១០ ឆ្នាំ** .......... ២២
*២.១. ការគាំទ្រផ្នែកគោលនយោបាយ* .......... ២៤
*២.២. ការពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងនៅតាមសាលាគរុកោសល្យ* .......... ៤៦
*២.៣. ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងកម្មវិធីវិក្រឹតការ និងឯកសាររៀននិងបង្រៀន* .......... ៥៣
*២.៤. ការអភិវឌ្ឍគុណវុឌ្ឍិគ្រូឧទ្ទេស គណៈគ្រប់គ្រង និងបុគ្គលិក* .......... ៦២
*២.៥. ការជ្រើសរើសគរុសិស្សប្រកបដោយសក្តានុពល និងការលើកកម្ពស់ការរស់នៅរបស់គ្រូឧទ្ទេស* .......... ៦៥
*២.៦. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ* .......... ៦៧
*២.៧. ការផ្សារភ្ជាប់សាលាគរុកោសល្យនឹងសាលាអនុវត្តន៍ និងសាលាសហការ* .......... ៨០
*២.៨. កិច្ចសហប្រតិបត្តិការ* .......... ៨៤
**៣. ផែនការឆ្ពោះទៅកាន់ឆ្នាំ២០៣០ និង២០៥០** .......... ៨៥

# សមិទ្ធផល១០ឆ្នាំ
## នៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន
## ២០១៤-២០២៤

### ១. ស្ថានភាពការបណ្តុះបណ្តាលគ្រូមុនឆ្នាំ២០១៤

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ កម្ពុជាប្រឈមនឹងសង្គ្រាមស៊ីវិល ដែលធ្វើឱ្យការអប់រំមានដំណើរការមិនបានពេញលេញ ហើយគុណភាពអប់រំបានធ្លាក់ចុះជាបន្តបន្ទាប់។ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ការអប់រំបានធ្លាក់ដល់ចំណុចសូន្យ រីឯគ្រូបង្រៀន និងបញ្ញវន្តភាគច្រើនត្រូវបានសម្លាប់រង្គាល។ ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វិស័យអប់រំ ដែលពួកខ្មែរក្រហមព្យាយាមកម្ទេចចោលត្រូវបានស្តារឡើងវិញភ្លាមៗ។ ការប្រមូលគ្រូបង្រៀន និងអ្នកចេះដឹងដែលនៅសេសសល់ព្រមទាំងសិស្សានុសិស្ស ត្រូវបានប្រព្រឹត្តទៅគ្រប់ទិសទី។ រដ្ឋាភិបាលបានប្រើគោលនយោបាយ «អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះ»។ ការបង្រៀន និងផ្ទេរចំណេះដឹងបានចាប់ផ្តើមឡើងយ៉ាងផុសផុលក្នុងសាលារៀន វត្តអារាម តាមផ្ទះប្រជាជន និងក្រោមដើមឈើ រីឯសិស្សានុសិស្សក៏ប្រើក្រដាសចាស់ៗដោយយកធ្យូង ឬដីឥដ្ឋមកសរសេរជាដើម។

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៩ បរវេសនកាលផ្លូវការត្រូវបានប្រារព្ធឡើងនៅអនុវិទ្យាល័យចតុមុខ ក្នុងរដ្ឋធានីភ្នំពេញ រីឯក្រសួងអប់រំ យុវជន និងកីឡាក៏ត្រូវបានបង្កើតឡើងវិញ។ ក្នុងពេលជាមួយគ្នានេះ ការបណ្តុះបណ្តាលគ្រូបង្រៀនក៏ចាប់ផ្តើមជាបន្ទាន់ ដោយមាននាយកដ្ឋានហ្វឹកហ្វឺន និងសុក្រឹតការ ដែលក្រោយមកប្រែក្លាយជានាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអ្នកទទួលខុសត្រូវ។ ក្នុងស្ថានភាពដ៏លំបាកនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនបានចាប់ផ្តើមពីការប្រមូលអតីតគ្រូបង្រៀន សិស្ស និស្សិត និងអ្នកមានចំណេះដឹង ឬកម្រិតវប្បធម៌មួយចំនួន ដែលនៅសេសសល់ពីការសម្លាប់រង្គាលក្នុងរបបខ្មែរក្រហម មកបំប៉នចិត្ត-គរុកោសល្យ និងវិធីសាស្ត្របង្រៀនរយៈពេលខ្លីនៅតាមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តទាំង១៨ បន្ទាប់មកបញ្ជូនទៅកាន់សាលារៀនចំណោះទូទៅទូទាំងប្រទេស។ ជាមួយគ្នានេះដែរ ការបំប៉នមន្ត្រីគ្រប់គ្រងអប់រំក៏ត្រូវបានចាប់ផ្តើមផងដែរ តាមរយៈការបើកវគ្គបំប៉នប្រមូលផ្តុំ នៅសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ ដែលបច្ចុប្បន្នជា «វិទ្យាស្ថានជាតិអប់រំ»។




ប្រព័ន្ធបណ្ដុះបណ្ដាលគ្រូបង្រៀនមុនឆ្នាំ២០១៤

នៅឆ្នាំ១៩៨៥ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ត្រូវបានបង្កើតឡើងតាមសេចក្ដីសម្រេចលេខ ២០៦ ស.សរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៨៥ ដោយចាប់ផ្ដើមបណ្ដុះបណ្ដាលគ្រូបង្រៀនមត្តេយ្យសិក្សានៅឆ្នាំ១៩៨៧ តាមប្រព័ន្ធ ៨+១។ ការបណ្ដុះបណ្ដាលគ្រូបង្រៀននៅកម្រិតមត្តេយ្យសិក្សានេះ បានទទួលការកែលម្អមកអនុវត្តប្រព័ន្ធ ១១+១ នៅឆ្នាំ១៩៩៤ ១២+១ នៅឆ្នាំ១៩៩៧ និង ៩+២ និង១២+២ នៅឆ្នាំ២០១៥។

ចាប់ពីឆ្នាំ១៩៨២ ក្រសួងបានសម្រេចឱ្យសាលាគរុកោសល្យ និងវិក្រឹតការរាជធានីខេត្តទាំង១៨ បណ្ដុះបណ្ដាលគ្រូបង្រៀនបឋមសិក្សា រយៈពេលវែងដោយចាប់ផ្ដើមពីប្រព័ន្ធ ៧+១ បន្ទាប់មក ៨+១ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ ស្របពេលដែលក្រសួងកែទម្រង់ប្រព័ន្ធអប់រំចំណេះទូទៅដោយអនុវត្តរូបមន្តប្រព័ន្ធ១០ឆ្នាំ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ ប្រព័ន្ធ១១ឆ្នាំ ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៩៦ និង១២ឆ្នាំ ចាប់ពីឆ្នាំ១៩៩៦ កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនក៏ទទួលបាននូវការកែលម្អ មកអនុវត្តតាមប្រព័ន្ធ ១២+២ ចាប់ពីឆ្នាំ១៩៩៧។ ទោះជាយ៉ាងនេះក្ដី តម្រូវការគ្រូបង្រៀនសម្រាប់ខេត្តភូមិភាគឦសាន កោះកុង និងតំបន់ដាច់ស្រយាល និងកង្វះខាតអ្នកស្ម័គ្រចិត្តទៅបង្រៀននៅទីនោះ បន្តជំរុញឱ្យក្រសួងអនុវត្តប្រព័ន្ធ ៣+១ សម្រាប់បណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សាដែលជ្រើសរើសពីមូលដ្ឋានផ្ទាល់រហូតដល់ឆ្នាំ១៩៨៤ កម្មវិធី៤+១ ពីឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៧ និង៥+៣ ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩១។

ចាប់ពីឆ្នាំ១៩៨០ ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិត្រូវបានអនុវត្តដោយប្រើកម្មវិធីរយៈពេលខ្លីផង និងតាមប្រព័ន្ធ៩+១ ផង។ ការអនុវត្តកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីពី ៤ខែ ទៅ១០ខែ ឬ ៣ខែកន្ទះចំនួន២ដង សម្រាប់ធនធានមនុស្សដែលនៅសេសសល់ពីសម័យខ្មែរក្រហម បានដំណើរការរហូតដល់ឆ្នាំ១៩៨៧។ នៅឆ្នាំ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ ដែលស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង ព្រៃវែង តាកែវ កំពង់ចាម ត្រូវបានបង្កើតឡើងសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ។ កម្មវិធីបណ្តុះបណ្តាលទទួលបានការកែលម្អជាបន្តបន្ទាប់ដើម្បីពង្រឹងគុណភាពអប់រំ។ ក្រោយពេលដែលប្រព័ន្ធអប់រំចំណេះទូទៅត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធ ៦+៣+៣ ពោលគឺការសិក្សារយៈពេល១២ឆ្នាំ នៅឆ្នាំ១៩៩៦ ប្រកបដោយជោគជ័យ ការអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិក៏ទទួលបានកែលម្អឱ្យទៅជា ១២+២ នៅឆ្នាំ១៩៩៧។ នៅឆ្នាំ២០១៧ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រួមជាមួយសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ត្រូវបានប្រែក្លាយជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដែលវិទ្យាស្ថានទាំងពីរត្រូវបានដំឡើងឋានៈស្មើអគ្គនាយកដ្ឋាននៅឆ្នាំ២០២១។ វិទ្យាស្ថានគរុកោសល្យទាំងពីរ បានចាប់ផ្តើមបណ្តុះ-បណ្តាលគ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានដែលបង្រៀននៅអនុវិទ្យាល័យ តាមប្រព័ន្ធ ១២+៤ ដោយទទួលបានបរិញ្ញាបត្រអប់រំវិជ្ជាជីវៈ ចាប់ពីឆ្នាំសិក្សា២០១៨-២០១៩ និងគ្រូបង្រៀនអនុវិទ្យាល័យតាមប្រព័ន្ធបរិញ្ញាបត្រ+១ ចាប់ពីឆ្នាំសិក្សា ២០២៤-២០២៥។

ដោយឡែក ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅវិទ្យាល័យបានចាប់ផ្តើមពីឆ្នាំសិក្សា១៩៨០-១៩៨១ នៅសាលាគរុវិជ្ជាជាន់ខ្ពស់នៃ «សាកលវិទ្យាល័យភ្នំពេញ» ដែលក្រោយមកបានបំបែកចេញមកជា វិទ្យាស្ថានជាតិអប់រំ ដោយផ្តើមពីការបណ្តុះបណ្តាលរយៈពេល៤ខែ ៧ខែ ១០+៣, ១០+៤ និងបរិញ្ញាបត្រ+១ នៅឆ្នាំ១៩៩៥ រួចអភិវឌ្ឍមកបរិញ្ញាបត្រ+២ ចាប់ពីឆ្នាំ២០២៣។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៤ តាមអនុក្រឹត្យលេខ០៤ អនក្រ.បក វិទ្យាស្ថានជាតិអប់រំបានទទួលការទទួលស្គាល់ឱ្យមានឋានៈស្មើសាកលវិទ្យាល័យ ដែលមានទស្សនៈវិស័យ និងមានភារកិច្ចបណ្តុះ-បណ្តាលធនធានមនុស្ស ដើម្បីបម្រើសេចក្តីត្រូវការនៃការអភិវឌ្ឍសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសចូលរួមយ៉ាងសកម្មក្នុងកំណែទម្រង់ទាំងឡាយដែលទាក់ទងនឹងកំណែទម្រង់គ្រូបង្រៀន មន្ត្រីគ្រប់គ្រងអប់រំ ការបណ្តុះបណ្តាលនាយក និងការពង្រឹងសមត្ថភាពអធិការផងដែរ។

# ការបណ្តុះបណ្តាលគ្រូបង្រៀនពីឆ្នាំ១៩៨០ ដល់ បច្ចុប្បន្ន

## គ្រូបង្រៀនមត្តេយ្យសិក្សា

| ឆ្នាំសិក្សា | ប្រព័ន្ធបណ្តុះបណ្តាល | ចំនួនសរុប |
|---|---|---|
| ១៩៨០-១៩៨៦ | រយៈពេលខ្លី | ២៨៥៧ |
| ១៩៨៧-១៩៩៤ | ៨+១ | ៤៧៥ |
| ១៩៩៤-១៩៩៧ | ១១+១ | ១១៥ |
| ១៩៩៧-១៩៩៨ | ១២+១ | ៦៤៨ |
| ២០០៤-២០១៦ | ១២+២/៩+២ | ១៨៦៩ |
| ២០១៥-២០២៣ | ១២+២ | ១២០៨ |
| សរុប | | ៧១៧២ |

## គ្រូបង្រៀនបឋមសិក្សា

| ឆ្នាំសិក្សា | ប្រព័ន្ធបណ្តុះបណ្តាល | ចំនួនសរុប |
|---|---|---|
| ១៩៨៣-១៩៨៤ | ៣+១ | ៤៧ |
| ១៩៨៤-១៩៨៧ | ៤+១ | ៣០០ |
| ១៩៨៥-១៩៩១ | ៥+៣ | ៣២០ |
| ១៩៨២-១៩៨៧ | ៧+១ | ៥៧៩៥ |
| ១៩៨៧-១៩៩០ | ៨+១ | ៦៦៦៣ |
| ១៩៩០-១៩៩៤ | ៨+២ | ៥២៧៣ |
| ១៩៩៣-១៩៩៧ | ១១+២ | ៣០៣៤ |
| ១៩៩៦-១៩៩៦ | បរិញ្ញាបត្រ+១ | ២៦ |
| ១៩៩៦-១៩៩៨ | ១១+២ | ១,៣០៦ |
| ១៩៩៦-១៩៩៧ | បរិញ្ញាបត្រ+១ | ៦៣ |
| ១៩៩៧-១៩៩៩ | ១២+២/៩+២ | ២,៧៧៩ |
| ១៩៩៧-១៩៩៨ | បរិញ្ញាបត្រ+១ | ៦ |
| ១៩៩៨-២០១៦ | ១២+២/៩+២ | ៤១១៨១ |
| ២០១៥-២០២១ | ១២+២ | ៦៣០៨ |
| ២០១៨-២០២២ | ១២+៤ | ២៩៧ |
| ២០១៩-២០២១ | ១២+២ | ១,២៩២ |
| ២០១៩-២០២៣ | ១២+៤ | ២៩២ |
| ២០២១-២០២៣ | ១២+២ | ១,២១១ |
| ២០២១-២០២៥ | ១២+៤ | ៣០០ |
| សរុប | | ៧៦៤៩៣ |

## គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ

| ឆ្នាំសិក្សា | ប្រព័ន្ធបណ្តុះបណ្តាល | ចំនួនសរុប |
|---|---|---|
| ១៩៨០-១៩៨១ | ៤ ខែ | ១៧៩ |
| ១៩៨១-១៩៨២ | ៥ ខែ | ៣៨១ |
| ១៩៨៣-១៩៨៣ | ៧ ខែ កន្លះ | ៤១៧ |
| ១៩៨៣-១៩៨៤ | ១០ ខែ | ១៥២ |
| ១៩៨១-១៩៨៧ | ៣ ខែកន្លះ (២ ដង) | ៦៦៤៨ |
| ១៩៨០-១៩៨៤ | ៩+១ | ៨៩៩ |
| ១៩៨២-១៩៨៨ | ៧+៣ | ៣៥៨៣ |
| ១៩៨៦-១៩៩២ | ៨+៣ | ៨៤០៥ |
| ១៩៨៩-១៩៩២ | ១១+២ | ១១៧៨ |
| ១៩៩៧-២០១៦ | ១២+២ | ២៣២៦៩ |
| ២០១៥-២០១៧ | អត់ជ្រើសរើស | |
| ២០១៦-២០២០ | ១២+២ | ១៩៣២ |
| ២០១៨-២០២២ | ១២+៤ | ១៨៧ |
| ២០១៩-២០២១ | ១២+២ | ១៩៤ |
| ២០២១-២០២៥ | ១២+៤ | ៦០៥ |
| ២០២១-២០២៣ | ១២+២ | ២៩៧ |
| សរុបរួម | | ៤៨៦៤៧ |

## គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ

| ឆ្នាំសិក្សា | ប្រព័ន្ធបណ្តុះបណ្តាល | ចំនួនសរុប |
|---|---|---|
| ១៩៨០-១៩៨១ | ៤ខែ | ២៧ |
| ១៩៨១-១៩៨២ | ៧ខែ | ៦០ |
| ១៩៨២-១៩៩០ | ១០+៣ | ១៣០៥ |
| ១៩៨៧-១៩៩៤ | ១០+៤ | ២១៤៤ |
| ១៩៩៥-១៩៩៦ | បរិញ្ញាបត្រ+១ | ១៨៤៥៦ |
| ២០២១-២០២៣ | បរិញ្ញាបត្រ+២ | ៨៤០ |
| សរុប | | ២២៨៣២ |

ប្រភព៖ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

ការបណ្តុះបណ្តាលគ្រូបង្រៀនពីឆ្នាំ១៩៨០ ដល់បច្ចុប្បន្ន

ក្នុងន័យនេះ នៅឆ្នាំ ២០១៤ ក្រសួងជួបនូវបញ្ហាប្រឈមសំខាន់ៗចំនួន៤ទាក់ទងនឹងធនធានមនុស្ស៖

**១) គុណវុឌ្ឍិគ្រូបង្រៀននៅមានកម្រិត៖** នៅឆ្នាំ២០១៥ ក្នុងចំណោមបុគ្គលិកបង្រៀនសរុប ចំនួន ៩៦ ២៩៨ នាក់ ដែលស្មើនឹងប្រមាណ ៨៣% នៃចំនួនបុគ្គលិកអប់រំទាំងអស់ បុគ្គលិកបង្រៀនដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រមានចំនួនសរុប ៧៨ ៩៥៤ នាក់ ស្មើនឹង ៨១,៩៨%[1] ហើយអត្រាអ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រ មានការកើនឡើងប្រមាណ ២% ក្នុងមួយឆ្នាំ[2]។ ដោយឡែក គ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាល «ក្នុងដំណាក់កាលកសាងប្រទេសឡើងវិញ» តាមប្រព័ន្ធ ៣+១, ៤+១, ៥+៣ ជាដើម នៅតែបន្តបំពេញការងារក្នុងប្រព័ន្ធអប់រំនៅឡើយក្នុងឆ្នាំ ២០២៤នេះ។




ក្នុងឆ្នាំដដែល ចំណោមគ្រូឧទ្ទេសសរុប ចំនួន ១ ៣៤៣ នាក់ គ្រូឧទ្ទេសដែលមានគុណវុឌ្ឍិក្រោមបរិញ្ញាបត្រមានចំនួន ៤១៥ នាក់ស្មើនឹង ៣០,៩% បរិញ្ញាបត្រ ចំនួន ៦៩៣ នាក់ ស្មើនឹង ៥១,៦% បរិញ្ញាបត្រ ជាន់ខ្ពស់ចំនួន ២២៧ នាក់ ស្មើនឹង ១៦,៩% និងថ្នាក់បណ្ឌិតត្រឹម ៨ នាក់ ស្មើនឹង ០,៦%។[3]




**២) ចំនួនបាត់បង់មន្ត្រីរាជការពីក្របខ័ណ្ឌគ្រូបង្រៀនមានកម្រិតខ្ពស់៖** អត្រាបុគ្គលិកអប់រំដែលផ្ទេរទៅក្រសួងនានា ត្រូវលុបចេញពីក្របខ័ណ្ឌ និងដាក់ឱ្យចូលនិវត្តន៍ ធៀបនឹងចំនួនក្របខ័ណ្ឌថ្មីដែលក្រសួងទទួលបាន មានអត្រាខ្ពស់ ដែលអត្រានេះនៅមិនទាន់រួមបញ្ចូលចំនួនបុគ្គលិកអប់រំដែលបានទទួលមរណភាព។ ជាក់ស្តែង នៅឆ្នាំ២០១៣ ការបាត់បង់មន្ត្រីរាជការពីក្របខ័ណ្ឌគ្រូបង្រៀនមានចំនួនសរុប ២ ៩៥២នាក់ ស្មើនឹង ៦១,៨៣% នៃចំនួនក្របខ័ណ្ឌថ្មីដែលមានចំនួន ៤ ៧៧២នាក់ រីឯនៅឆ្នាំ២០១៤ ការបាត់បង់មន្ត្រីរាជការពីក្របខ័ណ្ឌគ្រូបង្រៀនមានចំនួនសរុប ៣ ៤២៧នាក់ ស្មើនឹង ៥៩,៥០% នៃចំនួនក្របខ័ណ្ឌថ្មី ដែលមានចំនួន ៥ ៧៥៩នាក់។

[1] HRMIS 2024

[2] EMIS 2013

[3] HRMIS 2024




ចំនួនបាត់បង់មន្ត្រីរាជការពីក្របខ័ណ្ឌធៀបនឹងចំនួនក្របខ័ណ្ឌថ្មីឆ្នាំ ២០១៣ និង២០១៤

ដើម្បីឆ្លើយតបនឹងតម្រូវការគ្រូបង្រៀន ក៏ដូចជាតម្រូវការក្នុងការអប់រំសិស្សនៅតាមតំបន់ដាច់ស្រយាល ដែលពុំមានសិស្សគ្រប់ចំនួនអាចបង្កើតថ្នាក់រៀនបាន ក្នុងឆ្នាំសិក្សា២០១២-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់គ្រូជាប់កិច្ចសន្យា និងបុគ្គលិកបណ្ដែតចំនួន ៣ ៤៨៨នាក់ និងគ្រូបង្រៀន២វេន និងបង្រៀនថ្នាក់គួប ចំនួន ១៦ ៦៦០នាក់នៅកម្រិតបឋមសិក្សា រីឯឆ្នាំសិក្សា ២០១៣-២០១៤ ក្រសួងបានប្រើប្រាស់គ្រូជាប់កិច្ចសន្យា និងបុគ្គលិកបណ្ដែត ចំនួន ៣ ៤៥១នាក់ និងគ្រូបង្រៀន២វេន និងបង្រៀនថ្នាក់គួបចំនួន ១៧ ០៣៥នាក់ នៅកម្រិតបឋមសិក្សា។[4] គ្រូបង្រៀនជាប់កិច្ចសន្យា ជាទូទៅមានគុណវុឌ្ឍិត្រឹមកម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬទាបជាងនេះទៅតាមទីតាំងភូមិសាស្ត្រ រីឯគ្រូបង្រៀន ២វេន ឬថ្នាក់គួបក៏មានកម្រិតគុណវុឌ្ឍិទាប ដែលជាកត្តាប្រឈមក្នុងការធានាគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀន។

**៣) អាជីពជាគ្រូបង្រៀននៅមិនទាន់មានភាពទាក់ទាញសម្រាប់សិស្សពូកែ៖** ការទាក់ទាញសិស្សពូកែឱ្យមកចូលធ្វើគ្រូបង្រៀននៅមានកម្រិត ពោលគឺ គរុសិស្ស គរុនិស្សិតប្រមាណជាង៨០% ដែលបានប្រឡងចូលគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ជាសិស្សដែលទទួលបាននិទ្ទេស D ឬ E ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ កត្តានេះអាចបណ្ដាលមកពីការផ្ដល់តម្លៃទាបដល់វិជ្ជាជីវៈ និងឋានៈគ្រូបង្រៀននៅក្នុងសង្គម ក៏ដូចជាបៀវត្សរ៍របស់គ្រូបង្រៀនដែលមានចំនួនស្មើនឹងប្រមាណ

[4] របាយការណ៍សន្និបាតអប់រំឆ្នាំ ២០១២-២០១៣ និង២០១៣-២០១៤

៦០% នៃបៀវត្សរ៍របស់អ្នកមានវិជ្ជាជីវៈផ្សេងទៀតក្នុងវិស័យឯកជន ដែលមានគុណវុឌ្ឍិ និងបំណិនប្រហាក់ប្រហែលគ្នា។[5] នៅឆ្នាំ២០១៣ បៀវត្សរ៍អប្បបរមារបស់គ្រូបង្រៀនកម្រិតបឋមសិក្សាមានចំនួន ៣១០ ៨០០ រៀល គ្រូកម្រិតមូលដ្ឋានចំនួន ៤៣៨ ០១០ រៀល និងកម្រិតឧត្តមដែលបង្រៀននៅវិទ្យាល័យចំនួន ៦២៩ ១៨០រៀល និងប្រាក់បៀវត្សរ៍អតិបរមារបស់គ្រូបង្រៀនកម្រិតបឋមសិក្សាមានចំនួន ៥៣៧ ០៣០ រៀល គ្រូកម្រិតមូលដ្ឋានចំនួន ៧៥៨ ៩៩០ រៀល និងកម្រិតឧត្តមចំនួន ១ ០៩០ ១១០ រៀល ខណៈឆ្នាំ២០១៤ ប្រាក់បៀវត្សរ៍អប្បបរមារបស់គ្រូបង្រៀនកម្រិតបឋមសិក្សាមានចំនួន ៥៥០ ០០០ រៀល គ្រូកម្រិតមូលដ្ឋានចំនួន ៥៩៤ ៤០០ រៀល និងកម្រិតឧត្តមចំនួន ៧៧៨ ៨០០ រៀល និងប្រាក់បៀវត្សរ៍អតិបរមារបស់គ្រូបង្រៀនកម្រិតបឋមសិក្សាមានចំនួន ៦២៨ ២៤០ រៀល គ្រូកម្រិតមូលដ្ឋានចំនួន ៨៤៥ ២០០ រៀល និងកម្រិតឧត្តមចំនួន ១ ១៣៦ ០០០រៀល។[6] គ្រូបង្រៀនជាច្រើនបានបង្ខំចិត្តប្រកបមុខរបរទីពីរដើម្បីទទួលបានកម្រៃបន្ថែមសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។




មូលហេតុចម្បងដែលធ្វើឱ្យអាជីពជាគ្រូបង្រៀននៅមិនទាន់មានភាពទាក់ទាញ

**៤) ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅមិនទាន់ឆ្លើយតប៖** គ្រូបង្រៀនភាគច្រើនពុំមានឱកាសក្នុងការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទេ។ ត្បិតក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍបានធ្វើវិក្រឹតការនៅនឹងកន្លែង និងវិក្រឹតការរយៈពេលខ្លី ប៉ុន្តែវិក្រឹតការរយៈពេលវែងដែលមានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីច្បាស់លាស់នៅពុំទាន់ត្រូវបានអនុវត្តនោះទេ។ ជាមួយគ្នានេះ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពុំទាន់មានការផ្សារភ្ជាប់ទៅនឹងការដំឡើងឋានៈ ឬវឌ្ឍនភាពអាជីពសម្រាប់រយៈពេលវែង។

[5] គោលនយោបាយស្តីពីគ្រូបង្រៀន៖ ផែនការសកម្មភាពខេមរភា ឆ្នាំ២០១៤
[6] នាយកដ្ឋានបុគ្គលិកឆ្នាំ ២០១៣ និង ២០១៤

## ២. សមិទ្ធផលនៃកំណែទម្រង់សាលាគរុកោសល្យក្នុងរយៈពេល ១០ ឆ្នាំ

*បរិបទនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលសំដៅលើការរីកចម្រើនផ្នែកបច្ចេកវិទ្យា បានអនុញ្ញាតឱ្យមនុស្សអាចស្វែងរកព័ត៌មានគ្រប់យ៉ាង គ្រប់រូបភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ បដិវត្តន៍នេះបានផ្លាស់ប្តូររបៀបគិត របៀបធ្វើ របៀបរស់នៅ និងរបៀបដោះស្រាយបញ្ហារបស់មនុស្ស។ ក្នុងបរិបទនេះ ដើម្បីសម្រេចឱ្យបាននូវទិសដៅអភិវឌ្ឍកម្ពុជាឆ្នាំ២០៣០ និង២០៥០ ឱ្យកម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់ ទាមទារឱ្យពលរដ្ឋកម្ពុជាមានគុណសម្បទាសតវត្សរ៍ទី២១ ពោលគឺ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា។*




គុណសម្បទាសតវត្សរ៍ទី២១

គ្រូបង្រៀនជាភ្នាក់ងារផ្លាស់ប្តូរក្នុងការដឹកនាំសិស្សដើម្បីបង្កើតឧត្តមភាពសម្រាប់សង្គម និងក្លាយជាពលរដ្ឋសកលដែលមានគុណសម្បទាសតវត្សរ៍ទី២១។ ក្នុងន័យនេះ គុណភាព និងឧត្តមភាពគ្រូបង្រៀនគឺជាគន្លឹះនៃការអភិវឌ្ឍសង្គមជាតិ។ ដូច្នេះ ក្នុងរយៈពេល១០ឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យ អប់រំ ២០១៤-២០១៨ និង២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់យក កំណែទម្រង់សាលាគរុកោសល្យ ពោលគឺការប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូទាំង២៩ រួមមាន វិទ្យាស្ថានជាតិអប់រំ(១) វិទ្យាស្ថានគរុកោសល្យ(២) វិទ្យាស្ថានជាតិអប់រំពិសេស(១) មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ(៤) សាលាគរុកោសល្យនិងវិក្រឹតការខេត្ត(១៦) និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម(១) ឱ្យក្លាយជាមជ្ឈមណ្ឌលឧត្តមភាពក្នុងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនគ្រប់កម្រិតដើម្បីជានាបាននូវគុណភាព និងឧត្តមភាព ឆ្លើយតបនឹងតម្រូវការក្នុងបរិបទថ្មីនេះ។




ផែនទីបង្ហាញទីតាំងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទូទាំងប្រទេស

សមិទ្ធផលសំខាន់ៗទាក់ទងនឹងកំណែទម្រង់សាលាគរុកោសល្យក្នុងរយៈពេល ១០ឆ្នាំ មានដូចខាងក្រោម៖

## ២.១. ការគាំទ្រផ្នែកគោលនយោបាយ

### ២.១.១. ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន

### ក. ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន (២០១៥-២០២០)

នៅក្នុងខែមករា ឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡាបានទទួលកិច្ចសហការពីអង្គការ UNESCO ដោយមានការចូលរួមពីដៃគូអភិវឌ្ឍផ្សេងទៀតដូចជា JICA, UNICEF, NEP, World Bank, EU និង SIDAជាដើម ក្នុងការរៀបចំផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន (២០១៥-២០២០) ដោយបែងចែកជាសកម្មភាពសម្រាប់រយៈពេលខ្លី(២០១៥-២០១៧) និងរយៈពេលមធ្យម (២០១៨-២០២០) ក្នុងគោលបំណងអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន ដែលបានដាក់ចេញកាលពីឆ្នាំ២០១៣ ពោលគឺអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដោយកំណត់គោលដៅចំនួន ៤ គឺ៖

- ទាក់ទាញ និងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន
- ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន
- ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ
- ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

ដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងបួនខាងលើ ក្រសួងបានដាក់ចេញយុទ្ធសាស្ត្រសំខាន់ៗចំនួន៩ និងយុទ្ធសាស្ត្ររងចំនួន៣៤ៗ យុទ្ធសាស្ត្រទាំង ៩ នៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន (២០១៥-២០២០) មានដូចតទៅ៖

យុទ្ធសាស្ត្រទី១ ៖ កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការ

យុទ្ធសាស្ត្រទី២ ៖ ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈគ្រូបង្រៀន

យុទ្ធសាស្ត្រទី៣ ៖ កំណត់ស្តង់ដាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន

យុទ្ធសាស្ត្រទី៤ ៖ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

យុទ្ធសាស្ត្រទី៥ ៖ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

យុទ្ធសាស្ត្រទី៦ ៖ អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ

យុទ្ធសាស្ត្រទី៧ ៖ លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

យុទ្ធសាស្ត្រទី៨ ៖ ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន

យុទ្ធសាស្ត្រទី៩ ៖ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀន

នៅឆ្នាំ២០១៩ ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០ ត្រូវបានយកមកពិនិត្យឡើងវិញ ក្នុងទិសដៅពិនិត្យមើលពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកន្លងមក ទិដ្ឋភាពរួម និងអនុសាសន៍មួយចំនួនក្នុងការធ្វើបច្ចុប្បន្នកម្មផែនការនេះ។ នៅឆ្នាំ២០២២ ផែនការនេះក៏ត្រូវបានយកមកពិនិត្យឡើងវិញ ដែលជាចំណុចចាប់ផ្តើមឈានទៅដល់ការអភិវឌ្ឍផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០។

## ខ. ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០

ផែនការសកម្មភាពនេះត្រូវបានអភិវឌ្ឍផ្អែកលើ ១)សកម្មភាពពុំទាន់បានអនុវត្តនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០ ២)អនុសាសន៍នៃការពិនិត្យឡើងវិញនូវផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៩ ដែលពុំទាន់បានដោះស្រាយ ៣)ការវិភាគឯកសារគោលនយោបាយផែនការសកម្មភាព និងក្របខ័ណ្ឌនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ៤)ការវិភាគឯកសារគោលនយោបាយគ្រូបង្រៀនដែលជាឧត្តមានុវត្តន៍ផ្អែកលើភស្តុតាង និង ៥)គំនិតផ្តួចផ្តើមនានាដែលបានលើកឡើងនៅក្នុងសិក្ខាសាលាកំណត់អាទិភាព និងពិគ្រោះយោបល់ស្តីពីផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ដែលមានការចូលរួមពីគណៈកម្មការអភិវឌ្ឍផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ដៃគូអភិវឌ្ឍ និងក្រុមការងារវិស័យអប់រំ។ យោងតាមលទ្ធផលនៃសកម្មភាព និងសិក្ខាសាលាខាងលើ យុទ្ធសាស្ត្រទាំង ៩ នៃគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ ត្រូវបានបង្រួមទៅជាយុទ្ធសាស្ត្រធំៗចំនួន៤ ដែលត្រូវបានបន្សុំជាមួយយុទ្ធសាស្ត្រនៃគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ និងផ្នែកសំខាន់ៗទាំង ៤ នៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៥-២០២០។

**យុទ្ធសាស្ត្រទាំង៤ មានដូចតទៅ៖**

**យុទ្ធសាស្ត្រទី១៖ ការគ្រប់គ្រងគ្រូបង្រៀន** ផ្តោតលើការអនុវត្តការគ្រប់គ្រងគ្រូបង្រៀនដើម្បីធានាថាគោលនយោបាយ និងផែនការអប់រំត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព។ ដូច្នេះការវិនិយោគលើការអប់រំគឺជាការផ្លាស់ប្តូរជីវិតរបស់អ្នកសិក្សា និងអនាគតសង្គម។ កត្តានេះតម្រូវឱ្យ

មានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំនូវផលជះនៃការវិនិយោគលើវិស័យអប់រំ ដើម្បីធានាថា ធនធានបានទៅដល់គោលដៅដែលបានគ្រោងទុក និងទទួលបានលទ្ធផលសិក្សាដូចដែលបានរំពឹងទុកក្នុងគោលនយោបាយអប់រំ។

**យុទ្ធសាស្ត្រទី២ ៖ បរិវត្តកម្មភាពជាអ្នកដឹកនាំ** ផ្ដោតលើអ្នកដឹកនាំអប់រំដែលពង្រឹងស្វ័យភាព ពង្រីកនិងលើកកម្ពស់ចំណាប់អារម្មណ៍របស់បុគ្គលិកអប់រំ បង្កើតការយល់ដឹងនិងការទទួលយកនូវគោលបំណងនិងបេសកកម្មអប់រំ និងចេះលើកទឹកចិត្តបុគ្គលិកឱ្យគិតពីផលប្រយោជន៍រួមជាធំតាមរយៈការអនុវត្តប្រកបដោយនវានុវត្តន៍ និងបរិយាបន្ន ។ អ្នកដឹកនាំតាមបែបបរិវត្តកម្ម ត្រូវបានគាំទ្រតាមរយៈកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

**យុទ្ធសាស្ត្រទី៣៖ ការអប់រំគ្រូបង្រៀន** ផ្ដោតលើការអប់រំគ្រូបង្រៀនសតវត្សរ៍ទី២១ ដែលអភិវឌ្ឍសមត្ថភាពតាមរយៈកម្មវិធីអប់រំ និងសម្ភារៈសិក្សាប្រកបដោយបរិយាបន្ន និងមានលក្ខណៈឆ្លុះបញ្ចាំងលើកកម្ពស់សមត្ថភាព និងការគោរពចំពោះភាពចម្រុះ ហើយត្រូវមានជម្រើសសិក្សាដែលឆ្លើយតបនឹងបរិបទ គរុកោសល្យ និងកម្មវិធីអប់រំបែបចម្រុះ។ មូលដ្ឋានគ្រឹះនៃការអប់រំគ្រូបង្រៀន គឺការរៀនពីការបង្រៀន ការរៀនពីការបង្រៀនតាមមុខវិជ្ជា និងរៀនដើម្បីក្លាយជាគ្រូបង្រៀន។ ការអប់រំគ្រូបង្រៀនអាចពង្រឹងដោយបន្ស៊ីជាមួយនឹងកស្តុតាងនៃឧត្តមានុវត្តន៍ទាំងក្នុងតំបន់ និងអន្តរជាតិ។

**យុទ្ធសាស្ត្រទី៤៖ អត្តសញ្ញាណ និងការអភិវឌ្ឍគ្រូបង្រៀន** ផ្ដោតលើការលើកកម្ពស់អត្តសញ្ញាណគុណតម្លៃ និងវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀនត្រូវតែទទួលស្គាល់អត្តសញ្ញាណ និងវិជ្ជាជីវៈរបស់ខ្លួនហើយអភិវឌ្ឍនៅក្នុងការប្រតិបត្តិផ្ទាល់ ដែលនឹងធ្វើឱ្យជីវភាព គុណតម្លៃវិជ្ជាជីវៈ ឋានៈវិជ្ជាជីវៈ និងឋានៈសង្គមមានភាពប្រសើរឡើង។ កម្មវិធីក្រឹតការគ្រូបង្រៀនត្រូវបានបញ្ចូលក្នុងការអនុវត្តវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀនត្រូវមានសិទ្ធិអំណាចក្នុងការរៀបចំ បកស្រាយ និងគ្រប់គ្រងកម្មវិធីសិក្សា និងជ្រើសរើសខ្លឹមសារមេរៀន និងវិធីសាស្ត្របង្រៀនអាទិភាព។

យុទ្ធសាស្ត្រទាំង៤ នេះ ស្ថិតក្រោមគោលការណ៍ និងការអនុវត្តដូចខាងក្រោម ៖

**១) បរិវត្តកម្មការអប់រំ៖** គោលនយោបាយស្ដីពីគ្រូបង្រៀនដែលមានធនធានគាំទ្រគ្រប់គ្រាន់ និងត្រូវបានអនុវត្តប្រកបដោយឆន្ទៈនយោបាយ និងជំនាញរដ្ឋបាល គឺជាការវិនិយោគដ៏ល្អបំផុតដែលប្រទេសមួយត្រូវធ្វើដើម្បីលើកកម្ពស់វិស័យអប់រំ ហើយការជំរុញឱ្យគ្រូបង្រៀនយល់ច្បាស់ពីគោលនយោបាយ ដែលអាចនាំឱ្យមានការផ្លាស់ប្ដូរយូរអង្វែងគឺមានសារៈសំខាន់យ៉ាងខ្លាំង ។

**២) ការធានាគុណភាពប្រកបដោយចីរភាព** រួមបញ្ចូលសមាសធាតុនៃការធានាគុណភាពពាក់ព័ន្ធនឹងការរាយការណ៍ ស្វ័យវាយតម្លៃ និងសូចនាករសមិទ្ធកម្ម និងការលើកកម្ពស់គុណភាពដែលផ្ដោត

លើការកែលម្អបទពិសោធនៃការរៀន និងបង្រៀន។ ប្រព័ន្ធអប់រំទំនើបត្រូវមានតុល្យភាពរវាងតម្រូវការទាំងពីរ ពោលគឺការធានាគុណភាព និងការលើកកម្ពស់គុណភាព តាមរយៈការធានាគុណភាពប្រកបដោយចីរភាព។

**៣) ការអប់រំឌីជីថល** បច្ចេកវិទ្យា និងការរៀនតាមប្រព័ន្ធឌីជីថល បានផ្សារភ្ជាប់គ្នាទៅគ្រប់ផ្នែកនៃការបង្រៀន និងរៀន ដើម្បីអភិវឌ្ឍសមត្ថភាពឌីជីថលរបស់គ្រូបង្រៀន និងសិស្ស ឱ្យឆ្លើយតបទៅនឹងបរិវត្តកម្ម ការអប់រំសតវត្សរ៍ទី២១។ ការអប់រំឌីជីថល គឺជាការប្រើនូវបច្ចេកវិទ្យាឌីជីថល និងសម្ភារៈសិក្សាផ្សេងទៀតដើម្បីផ្តល់នូវបរិយាកាសសិក្សាដែលត្រូវបានរៀបចំឡើងយ៉ាងល្អ ប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល មានអន្តរកម្ម និងគាំទ្រដល់អ្នកសិក្សាគ្រប់រូប គ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

ដើម្បីធានាបាននូវភាពជោគជ័យ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀននៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានក្រុមការងារកំណែទម្រង់គ្រូបង្រៀនចំនួនប្រាំមួយ នឹងធ្វើការត្រួតពិនិត្យជារួម និងដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន។ អង្គភាព ឬនាយកដ្ឋានដែលបានកំណត់នឹងទទួលខុសត្រូវទាំងការអនុវត្ត និងការត្រួតពិនិត្យតាមដាន និងការវាយតម្លៃនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀននឹងធ្វើរបាយការណ៍វឌ្ឍនភាពនៃគំនិតផ្តួចផ្តើម លទ្ធផលរំពឹងទុក និងសូចនាករដូចមានចែងនៅក្នុងសកម្មភាពនីមួយៗ បញ្ហាប្រឈម និងបញ្ហាពាក់ព័ន្ធនានា។ របាយ-ការណ៍នេះនឹងរួមបញ្ចូលចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អ មេរៀនដែលបានរៀន សនិទានកម្មនៃសកម្មភាពដែលមិនបានអនុវត្ត និងឧត្តមានុវត្តន៍។ រីឯរបាយការណ៍ពិនិត្យឡើងវិញ ក៏នឹងផ្តល់នូវការវិភាគលម្អិតនៃការងារដែលបានអនុវត្ត និងសមិទ្ធផលដែលទទួលបាន។

## ២.១.២. ស្តង់ដាសាលាគរុកោសល្យ

### ក. ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន (Teacher Education Provider Standard-TEPS)

នៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន (Teacher Education Provider Standard-TEPS) ដើម្បីធានាបាននូវការយល់ដឹងរួមមួយក្នុងចំណោមអ្នកផ្តល់សេវាអប់រំគ្រូបង្រៀនដែលមានសក្តានុពល ពោលគឺជួយថ្នាក់ដឹកនាំនៃសាលាគរុកោសល្យនានាក្នុងការចាត់វិធានការចាំបាច់ ដើម្បីកែលម្អស្ថាប័នរបស់ខ្លួន ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យ (TEC) ដែលមានធនធានគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់ រួមទាំងសម្ភារៈបរិក្ខារ បុគ្គលិកសាស្ត្រាចារ្យ និងបុគ្គលិក

រដ្ឋបាលស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងស្តង់ដាជាតិសម្រាប់ការទទួលស្គាល់ជាស្ថាប័នដែលផ្តល់កម្មវិធីអប់រំ។ ស្តង់ដានេះក៏ជាគោលការណ៍ណែនាំសម្រាប់គ្រឹះស្ថានឧត្តមសិក្សាដែលមានស្រាប់ក្នុងការពង្រីកសេវាកម្មក្នុងការផ្តល់កម្មវិធីអប់រំគ្រូបង្រៀនផងដែរ។

ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬ TEPS មានស្តង់ដាចំនួន ៨ គឺ៖

**១) ស្តង់ដាទី១៖ ស្តង់ដាគ្រឹះស្ថាន**

គ្រឹះស្ថានឧត្តមសិក្សា ដែលអាចផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ត្រូវទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) និងទទួលបានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**២) ស្តង់ដាទី២៖ កម្មវិធីអប់រំគ្រូបង្រៀន**

កម្មវិធីអប់រំគ្រូបង្រៀនត្រូវបង្កើតឡើង ដោយយោងលើឯកសារពាក់ព័ន្ធនានា និងភស្តុតាងគ្រប់គ្រាន់ស្តីពីការអប់រំ និងការបណ្តុះបណ្តាលគ្រូបង្រៀន រាប់ទាំងមាត្រាពាក់ព័ន្ធក្នុងរដ្ឋធម្មនុញ្ញ ច្បាប់អប់រំនិងឯកសារគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ពល់កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវរៀបចំតាមប្រព័ន្ធក្រេឌីត។

- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មត្តេយ្យសិក្សា
- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់បឋមសិក្សា
- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មធ្យមសិក្សាបឋមភូមិ
- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មធ្យមសិក្សាទុតិយភូមិ។

**៣) ស្តង់ដាទី៣៖ គោលការណ៍កម្មវិធីសិក្សា**

ដើម្បីធានាឱ្យការអប់រំគ្រូបង្រៀនឱ្យមានគុណភាព កម្មវិធីទាំងអស់ត្រូវតែ៖

- រៀបចំកម្មវិធីបរិញ្ញាបត្រអប់រំ ដែលមានជំនាញឯកទេសបង្រៀនតាមភូមិសិក្សា និងមុខវិជ្ជាឯកទេស និងជំនាញអប់រំផ្សេងៗ
- អនុវត្តតាមសេចក្តីសម្រេច០៤/០៤ស្តីពីប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត ចុះថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ២០០៤ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- មានភាពស៊ីគ្នា និងប្រទាក់ក្រឡាគ្នាជាលំដាប់ ដើម្បីធានាទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពពីមួយឆ្នាំទៅមួយឆ្នាំ និងរវាងទ្រឹស្តីនិងការអនុវត្ត
- បញ្ចូលមុខវិជ្ជាភាសាអង់គ្លេស និងបច្ចេកវិទ្យាព័ត៌មានវិទ្យា
- បញ្ចូលកម្មសិក្សាវិជ្ជាជីវៈគ្រូបង្រៀនដែលមានតម្លៃមិនតិចជាង៥ ក្រេឌីត

- បញ្ចូលកិច្ចការស្រាវជ្រាវសរសេរសារណាដើម្បីបញ្ចប់ការសិក្សា ដែលមានតម្លៃមិនលើស ៦ ក្រេឌីត។

**៤) ស្តង់ដាទី៤៖ ធនធានកម្មវិធី**

គុណភាពនៃការស្រាវជ្រាវ ការបង្រៀន និងសេវាផ្សេងៗរបស់កម្មវិធីអប់រំគ្រូបង្រៀនពឹងផ្អែកទាំងស្រុងលើគុណវុឌ្ឍិ និងបទពិសោធរបស់សាស្ត្រាចារ្យ។ បន្ថែមលើវិញ្ញាបនបត្រនៃការទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានដែលត្រូវផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ត្រូវបង្ហាញអំពីភាពគ្រប់គ្រាន់នៃធនធានមនុស្ស និងសម្ភាររូបវន្ត។ កម្មវិធីអប់រំគ្រូបង្រៀនត្រូវមាន សាស្ត្រាចារ្យដែលមានគុណវុឌ្ឍិស្មើកម្រិតអប់រំដែលត្រូវបង្រៀន ( បរិញ្ញាបត្រ/បរិញ្ញាបត្រជាន់ខ្ពស់/បណ្ឌិត) និងមានបទពិសោធបង្រៀនយ៉ាងតិច ៥ ឆ្នាំ មានចំនួនមិនលើសពី ៥០ ភាគរយ នៃសាស្ត្រាចារ្យដែលបង្រៀននៅក្នុងកម្មវិធី។

**៥) ស្តង់ដាទី៥៖ ការជ្រើសរើសគរុនិស្សិត**

គ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាស្ថានអប់រំគ្រូបង្រៀនត្រូវមានយន្តការជ្រើសរើសនិស្សិតឱ្យចូលរៀន ដែលមានតម្លាភាព និងយុត្តិធម៌ ដើម្បីធានាថា គរុនិស្សិតនឹងមានសមត្ថភាពលើផ្នែកទាំងបីគឺវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា គ្រប់គ្រាន់សម្រាប់បន្តការសិក្សាកម្រិតឧត្តមសិក្សា។

កម្មវិធីអប់រំគ្រូបង្រៀនត្រូវមានគោលការណ៍ អំពីលក្ខខណ្ឌនៃការជ្រើសរើសគរុនិស្សិតឱ្យចូលរៀនទទួលបេក្ខជនដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង/ឬមានគុណវុឌ្ឍិ សមមូលសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មត្តេយ្យសិក្សាបឋមសិក្សា និង/ឬអនុវិទ្យាល័យ។

**៦) ស្តង់ដាទី៦៖ សាលាអនុវត្តន៍ និងសាលាសហការ**

កម្មសិក្សាគរុកោសល្យជាផ្នែកមួយសម្រាប់ពង្រឹងសមត្ថភាពរបស់គរុនិស្សិត ដោយរក្សាតុល្យការនៃទ្រឹស្តីដែលបានរៀន និងបទពិសោធក្នុងថ្នាក់រៀនជាមួយសិស្ស។

កម្មវិធីអប់រំគ្រូបង្រៀនត្រូវមាន «សៀវភៅណែនាំស្តីពីការអនុវត្តកម្មសិក្សាគរុកោសល្យ» ដែលមានសេចក្តីណែនាំលម្អិតអំពីលក្ខខណ្ឌ វិធាន និងនីតិវិធីសម្រាប់គរុនិស្សិតចុះកម្មសិក្សាគរុកោសល្យនៅតាមសាលាអនុវត្តន៍ និងសាលាសហការ។

កម្មវិធីអប់រំគ្រូបង្រៀន ត្រូវធានាបង្កើតទំនាក់ទំនងផ្លូវការជាមួយសាលារៀនសហការដែលពាក់ព័ន្ធទៅនឹងកម្មវិធីអប់រំ ដែលគ្រឹះស្ថានផ្តល់តាមកម្រិតសិក្សាដើម្បីសម្រួលឱ្យគរុនិស្សិត ចុះទទួលបទពិសោធវិជ្ជាជីវៈបង្រៀនជាក់ស្តែង។

គរុនិស្សិតទទួលឱកាសគ្រប់គ្រាន់ដើម្បីបង្កើតទំនាក់ទំនង បង្រៀន និងធ្វើសកម្មភាពសិក្សា

ផ្សេងៗទៀត ជាមួយសិស្សក្នុងភូមិសិក្សាដែលដូចគ្នានឹងកម្មវិធីអប់រំដែលគរុនិស្សិតរៀននៅក្នុងស្តង់ដា ទី ២។

កម្មវិធីអប់រំគ្រូបង្រៀន និងសាលារៀនសហការត្រូវធានាផ្តល់ទំនុកបម្រុង និងភាពងាយស្រួល ដល់គរុនិស្សិត និងការដឹកនាំដោយសាស្ត្រាចារ្យដែលមានសមត្ថភាពគ្រប់គ្រាន់និងមានបទពិសោធ យ៉ាងតិច ៥ ឆ្នាំក្នុងការបង្រៀន។

កម្មវិធីអប់រំ និងសាលារៀនសហការត្រូវណែនាំ ត្រួតពិនិត្យ និងវិនិច្ឆ័យសមត្ថភាពគរុនិស្សិត បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយអនុលោមតាមស្តង់ដាទី៣ អមដោយរបាយការណ៍វាយតម្លៃ គរុនិស្សិតដោយផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យសត្យានុម័តដូចមានចែងក្នុង «សៀវភៅណែនាំស្តីពី ការអនុវត្តកម្មសិក្សាគរុកោសល្យ»។

**៧) ស្តង់ដាទី៧៖ សមត្ថភាពគរុនិស្សិត**

កម្មវិធីអប់រំគ្រូបង្រៀនត្រូវបង្ហាញថា គរុនិស្សិតក្រោយបញ្ចប់ការសិក្សាពីកម្មវិធីអប់រំគ្រូបង្រៀន នឹងបំពេញបាននូវកញ្ចប់សមត្ថភាព ដូចមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជា និងស្តង់ដា សមត្ថភាពគ្រូបង្រៀនរបស់អាស៊ានក្នុងសតវត្សរ៍ទី២១។

**៨) ស្តង់ដាទី៨៖ ការធានាគុណភាពផ្ទៃក្នុង**

កម្មវិធីអប់រំគ្រូបង្រៀនត្រូវរៀបចំគោលការណ៍ណែនាំសម្រាប់កំណត់ និងវាយតម្លៃកម្មវិធីអប់រំ គ្រូបង្រៀន។

កម្មវិធីអប់រំគ្រូបង្រៀនត្រូវបង្កើតយន្តការត្រួតពិនិត្យគុណភាពផ្ទៃក្នុង និងឆ្លើយតបទៅលើការ ធានាគុណភាពដែលត្រូវបានរៀបចំឡើងដោយភាគីពាក់ព័ន្ធផ្សេងៗ។

កម្មវិធីអប់រំបង្រៀនត្រូវប្រមូលព័ត៌មាន និងទិន្នន័យនានា ដូចជា ដំណើរការបង្កើតកម្មវិធី ដំណើរការបង្រៀន និងរៀន ការវាយតម្លៃមុខវិជ្ជា ការវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត ការស្ទង់មតិគរុនិស្សិត ការស្ទង់មតិនិយោជក និងមតិយោបល់ពីភាគីពាក់ព័ន្ធ ទុកធ្វើជាភស្តុតាង សម្រាប់វាយតម្លៃកម្មវិធីអប់រំ ។

កម្មវិធីអប់រំគ្រូបង្រៀនត្រូវរៀបចំរបាយការណ៍ស្វ័យវាយតម្លៃអំពីគុណភាព ការកែប្រែ ដូចជា បន្ថែម ឬបន្ថយមុខវិជ្ជា និងបញ្ហាប្រឈមនានា សម្រាប់ដាក់ជូនស្ថាប័នមានសមត្ថកិច្ច ពិនិត្យ ជារៀងរាល់ឆ្នាំ។

## ខ. ស្តង់ដាសាលាគរុកោសល្យគំរូ




*នៅឆ្នាំ២០២៤ ស្របពេលដែលក្រសួងកំពុងដាក់ឱ្យអនុវត្តនូវស្តង់ដាសាលារៀនគំរូ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈតាំងពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សា ក្រសួងក៏បានដាក់ចេញផងដែរនូវស្តង់ដាសាលាគរុកោសល្យគំរូ ក្នុងទិសដៅធានាការបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ដោយផ្តល់ឱ្យគរុសិស្ស គរុនិស្សិតនូវបំណិនវិជ្ជាជីវៈជាគ្រូបង្រៀនពេញលេញមុន និងក្រោយពេលចេញទៅបម្រើការងារជាគ្រូបង្រៀននៅតាមសាលារៀនគោលដៅ។*

*ស្តង់ដាសាលាគរុកោសល្យគំរូត្រូវបានអភិវឌ្ឍឡើងដើម្បីវាយតម្លៃលើគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងធានាបាននូវនិរន្តរភាពនៃដំណើរការគ្រឹះស្ថានដែលមានស្តង់ដាចំនួន៥ គឺ៖*

**១) ស្តង់ដាទី១៖ លទ្ធផលបណ្តុះបណ្តាល**

- **គុណសម្បទាគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាល៖** *ភាពជាគ្រូបង្រៀន ដែលមានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន មានការទទួលស្គាល់ពីនាយកសាលា សហការី សិស្ស មាតាបិតា និងសហគមន៍ ពោលគឺទទួលបានការគាំទ្រពីកន្លែងដែលខ្លួនបំពេញការងារ ព្រមទាំងគាំទ្រសាលារៀនដែលកំពុងបម្រើការងារឱ្យក្លាយជាសាលារៀនគំរូ*
- **លទ្ធផលសិក្សារបស់គរុសិស្ស គរុនិស្សិត៖** *លទ្ធផលវាយតម្លៃមុខវិជ្ជាឯកទេស កម្មសិក្សាគរុកោសល្យ ស្រាវជ្រាវប្រតិបត្តិ ការអនុវត្តតេស្តវាយតម្លៃសិស្សអន្តរជាតិ* PISA *វង្វាយតម្លៃលទ្ធផលការសិក្សាសិស្សបឋមសិក្សាតំបន់អាស៊ីអាគ្នេយ៍* SEA PLM, *តេស្តស្តង់ដាភាសាបរទេស* ICT *លទ្ធផលធៀបនឹងស្តង់ដាវិជ្ជាជីវៈ និងលទ្ធផលប្រឡងបញ្ចប់។*

**២) ស្តង់ដាទី២៖ ធនធានបណ្តុះបណ្តាល**

- **ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** *បួងមេ អគារសិក្សា សួន បន្ទប់សិក្សា បន្ទប់គ្រូឧទ្ទេស បណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ICT សុខភាព សិល្បៈ សាលាគរុកោសល្យមេត្រី ការថែទាំហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងបរិស្ថាន*
- **ធនធានមនុស្ស៖** *កម្រិតគុណវុឌ្ឍិចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ កម្រិតវិជ្ជាជីវៈឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ*
- **កម្មវិធីបណ្តុះបណ្តាល៖** *កម្មវិធី និងឯកសារបណ្តុះបណ្តាល ផែនការបណ្តុះបណ្តាល ការពិនិត្យតាមដានការអនុវត្តកម្មវិធីបណ្តុះបណ្តាល កម្មសិក្សាគរុកោសល្យ និងសកម្មភាពក្រៅកម្មវិធីបណ្តុះបណ្តាល*
- **វិក្រឹតការគ្រូបង្រៀន៖** *ការទទួលស្គាល់ជាអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានកម្មវិធី និងអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិ។*

**៣) ស្តង់ដាទី៣៖ កិច្ចសហប្រតិបត្តិការ**

- **ការផ្សារភ្ជាប់សាលាគរុកោសល្យ និងសាលាអនុវត្តន៍៖** *ផែនការចុះគាំទ្រសាលាអនុវត្តន៍ គាំទ្រលើការដឹកនាំគ្រប់គ្រង គាំទ្រលើការអនុវត្តកម្មវិធីសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀននៅសាលាអនុវត្តន៍*
- **កិច្ចសហប្រតិបត្តិការជាមួយសហគមន៍ គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍ៖** *ការចូលរួមកិច្ចការសហគមន៍ ការស្វែងរកកាគាំទ្រពីសហគមន៍ និងដៃគូអភិវឌ្ឍ កិច្ចសហការប្រតិបត្តិការជាមួយគ្រឹះស្ថានអប់រំក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងការចុះគាំទ្រសាលារៀនឱ្យសម្រេចបានជាសាលារៀនគំរូ។*

**៤) ស្តង់ដាទី៤៖ អភិបាលកិច្ចល្អ**

- **ការដឹកនាំនិងគ្រប់គ្រង៖** *ប្រព័ន្ធដឹកនាំ និងគ្រប់គ្រងប្រកបដោយឧត្តមភាព ផែនការអភិវឌ្ឍគ្រឹះស្ថាន ការគ្រប់គ្រងទិន្នន័យគ្រឹះស្ថាន និងការវាយតម្លៃការបំពេញការងារបុគ្គលិក*
- **ការធានាគុណភាពគ្រឹះស្ថាន៖** *ការធានាគុណភាពផ្ទៃក្នុង និងការធានាគុណភាពផ្ទៃក្រៅ*
- **ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាល៖** *ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាល។*

**៥) ស្តង់ដាទី៥៖ ការស្រាវជ្រាវ និងនវានុវត្តន៍**

- **ការលើកកម្ពស់ការងារស្រាវជ្រាវ និងនវានុវត្តន៍៖** *ការស្រាវជ្រាវប្រតិបត្តិ ការបោះពុម្ព និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ*

- **ការកសាងឯកសារ/សៀវភៅមេរៀន៖** *ការនិពន្ធចងក្រងសៀវភៅមេរៀន និងការបោះពុម្ពសៀវភៅមេរៀន។*

*សាលាគរុកោសល្យទាំងអស់ត្រូវរៀបចំគណៈកម្មការវាយតម្លៃផ្ទៃក្នុង និងធ្វើការជាមួយផ្នែកពាក់ព័ន្ធផ្ទៃក្នុងនានាដើម្បីធ្វើស្វ័យវាយតម្លៃ រួចរៀបចំរបាយការណ៍ស្វ័យវាយតម្លៃដោយភ្ជាប់ជាមួយឯកសារជាភស្តុតាងពាក់ព័ន្ធឱ្យបានច្បាស់លាស់ រួចដាក់ពាក្យស្នើមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការវាយតម្លៃផ្ទៀងផ្ទាត់បន្ថែម មុននឹងដាក់ជូនទៅថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។ ការវាយតម្លៃគឺអាស្រ័យលើពិន្ទុសរុបដែលទទួលបាន ធៀបនឹងពិន្ទុសរុបនៃសូចនាករទាំង៥០ ដែលមានចែងក្នុងស្តង់ដាទាំង៥ ដោយពិន្ទុទទួលបានសរុបចាប់ពី ៩៥% ឡើង នឹងត្រូវចាត់ទុកថាបានបំពេញស្តង់ដាសាលាគរុកោសល្យគំរូ ពេញលេញ រីឯសាលាគរុកោសល្យដែលទទួលបានពិន្ទុសរុបចាប់ពី ៨០% ដល់តិចជាង ៩៥% នឹងត្រូវចាត់ទុកថា បានបំពេញស្តង់ដាសាលាគរុកោសល្យគំរូ មានស្តង់ដា ហើយសាលាគរុកោសល្យដែលទទួលបានពិន្ទុសរុបចាប់ពី ៦០% ដល់តិចជាង ៨០% នឹងត្រូវចាត់ទុកថាបានបំពេញស្តង់ដាសាលាគរុកោសល្យគំរូ មានស្តង់ដាអប្បបរមា។*

## ២.១.៣. ស្តង់ដានាយកសាលារៀន




*អភិបាលកិច្ចសាលារៀនត្រូវបានកំណត់ថា ជាកត្តាមួយសំខាន់នៅក្នុងការជំរុញឱ្យសាលារៀនមានគុណភាព និងអាចបណ្តុះអ្នកសិក្សាឱ្យមានគុណសម្បទាសតវត្សរ៍ទី២១។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ចក្ខុវិស័យ រយៈពេលវែងដល់ឆ្នាំ២០៣០ និងរៀបចំស្តង់ដានាយកសាលារៀនដោយផ្តោតជាសំខាន់លើគុណវឌ្ឍិ បទពិសោធការងារ ការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងការរៀន ឧត្តមភាពរបស់នាយកសាលារៀន និងការផ្សារភ្ជាប់សាលារៀន និងសហគមន៍ ក្នុងគោលដៅពង្រឹងការផ្តល់សេវាអប់រំប្រកបដោយគុណភាព ភាពឆ្លើយតប និងសុខដុមនីយកម្មក្នុងអន្តភាព។*

ស្តង់ដានាយកសាលាមានចំនួន ៦ គឺ៖

**១) ស្តង់ដាទី១៖ កម្រិតវប្បធម៌ និងបទពិសោធការងារ**

នាយកសាលារៀន ត្រូវមាន

- កម្រិតវប្បធម៌យ៉ាងទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឬប្រសិទ្ធផលគ្រប់គ្រាន់ដូចជា នាយកល្អប្រចាំឆ្នាំណាមួយជាដើម
- វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន
- ចំណេះដឹងមូលដ្ឋាន ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងវប្បធម៌ទូលំទូលាយ
- ចំណេះដឹងជំនាញភាសាបរទេសអាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង
- បទពិសោធបំពេញការងារជាគ្រូបង្រៀនយ៉ាងតិច ៥ឆ្នាំ។

**២) ស្តង់ដាទី២៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន**

នាយកសាលារៀនត្រូវមានសមត្ថភាព និងគុណសម្បត្តិដែលបង្ហាញពីភាពខ្លាំង និងប្រសិទ្ធភាពរបស់ខ្លួនក្នុងការគ្រប់គ្រង និងបំពេញការងារឱ្យអស់ពីសមត្ថភាព និងលទ្ធភាព ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ។

នាយកសាលារៀន ដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង ត្រូវដឹកនាំដោយធ្វើជាគំរូ បង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ ហ៊ានបង្ហាញពីតម្លាភាព និងគណនេយ្យភាព អ្វីៗដែលបានធ្វើត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ មានមោទនភាពលើវិជ្ជាជីវៈរបស់ខ្លួន ត្រូវបំពេញការងារឱ្យអស់ពីលទ្ធភាព និងមានសមត្ថភាពចេះជ្រើសរើសចំណុចណាជាអាទិភាពមកធ្វើមុន ហ៊ានសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈម បង្ហាញឥរិយាបថ ភាពជាសហគ្រិនភាព។ លើសពីនេះ នាយកសាលារៀនចាំបាច់ត្រូវអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងនោះមានស្វ័យសិក្សា ស្រាវជ្រាវនិងគាំទ្រតម្លៃទស្សនវិស័យរបស់អាស៊ាន។ សូចនាករសំខាន់ៗនៃស្តង់ដានេះមានការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ មានភាពជាអ្នកដឹកនាំ និងមានការប្តេជ្ញាចិត្តខ្ពស់។

**៣) ស្តង់ដាទី៣៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍**

នាយកសាលារៀនចាំបាច់ត្រូវមានការគិត និងការវិភាគដោយប្រមូលភស្តុតាងទិន្នន័យ និងស្នើជាជម្រើសក្នុងការដោះស្រាយបញ្ហា ព្រមទាំងគិតទៅលើគំនិតថ្មីៗ ធ្វើឱ្យប្រសើរឡើងក្នុងការបំពេញការងារ និងចាំបាច់ត្រូវស្វែងយល់អំពីក្របខ័ណ្ឌគតិយុត្ត តាមរយៈការអភិវឌ្ឍសមត្ថភាព ការពង្រឹងយន្តការ និងគោលការណ៍ជំរុញប្រសិទ្ធភាពការងារ ដោយមានការចូលរួម ដើម្បីធ្វើការសម្រេចចិត្ត

បានត្រឹមត្រូវ។ ក្នុងន័យនេះ នាយកសាលាត្រូវតាមដាន សិក្សាស្វែងយល់ពីចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង រៀបចំផែនការសកម្មភាពឱ្យឆ្លើយតប ធ្វើការបែងចែកការទទួលខុសត្រូវ និងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ព្រមទាំងធ្វើការពិនិត្យតាមដាន វាយតម្លៃ និងកែលម្អការងារជាប្រចាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ សូចនាករសំខាន់ៗនៃស្តង់ដានេះមានការយល់ដឹង និងផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ការអនុវត្តចក្ខុវិស័យនិងផែនការសកម្មភាព និងការត្រួតពិនិត្យនិងវាយតម្លៃ។

**៤) ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន**

*ការគ្រប់គ្រងរដ្ឋបាលសាលារៀន ជាភារកិច្ចសំខាន់មួយរបស់អ្នកដឹកនាំក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកគុណភាព និងប្រសិទ្ធភាពដើម្បីធ្វើការវាស់ស្ទង់ និងដោះស្រាយបញ្ហាចំពោះមុខលើការរៀបចំអង្គភាពមួយដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានា សំដៅធ្វើឱ្យមានការអភិវឌ្ឍលើគ្រប់ផ្នែក ដូចជាបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយតភាពការងារ និងត្រួតពិនិត្យវាយតម្លៃការផ្តល់សេវា ការគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក ថ្នាក់ សិស្ស ការរៀបចំផែនការសកម្មភាព និងថវិកាដើម្បីបង្ហាញភស្តុតាងជាក់លាក់ ក្នុងការអនុវត្តអ្វីដែលថ្មីរបស់នាយកសាលារៀន។ សូចនាករសំខាន់ៗនៃស្តង់ដានេះមានការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុ។*

**៥) ស្តង់ដាទី៥៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន**

*ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ការបង្រៀន និងរៀន មិនអាចកាត់ផ្តាច់ពីតួនាទីរបស់អ្នកដឹកនាំសាលារៀនដែលជាកត្តាជំរុញដ៏សំខាន់ ធានាដល់គុណភាពក្នុងការអនុវត្តការងាររបស់គ្រូបង្រៀន។ ស្តង់ដានេះជួយនាយកសាលារៀនឱ្យទទួលបានជោគជ័យក្នុងការធ្វើឱ្យសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅ។ នាយកសាលារៀនចាំបាច់ត្រូវដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា ការបង្កើតបរិស្ថាននិងបរិយាកាសសិក្សា ការធ្វើអធិការកិច្ចនិងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការផ្តល់លទ្ធផលសិក្សា។ សូចនាករសំខាន់ៗនៃស្តង់ដានេះមាន ការគ្រប់គ្រងការរៀន និងការបង្រៀន ការស្រាវជ្រាវ ការសហការ និងទំនាក់ទំនង ការអភិវឌ្ឍសមត្ថភាព និងការធ្វើអធិការកិច្ចផ្ទៃក្នុង។*

**៦) ស្តង់ដាទី៦៖ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍**

*សហគមន៍មានតួនាទីដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសាលារៀន។ ទំនាក់ទំនងល្អរវាងសាលារៀន និងសហគមន៍ជាកត្តាចាំបាច់មិនអាចខ្វះបាន។ ប្រការនេះជាកម្លាំងចលករ និងជាប្រភពមិនចេះរីងស្ងួត ក្នុងការលើកកម្ពស់គុណភាពបង្រៀន រៀន និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការចូលរួម*

រៀបចំផែនការ ស្វែងរកធនធាន និងការពិនិត្យតាមដានវឌ្ឍនភាព ក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំ ឱ្យមានជីវិតស្រស់បំព្រង ប្រកបដោយសុខដុមនីយកម្ម។ សូចនាករសំខាន់ៗនៃស្តង់ដានេះមាន អាជ្ញាធរដែនដី មាតាបិតា និងភាគីពាក់ព័ន្ធ។

## ២.១.៤. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស

នៅឆ្នាំ២០១០ ក្រសួងបានរៀបចំនូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងត្រូវបានយកមកពិនិត្យឡើងវិញនៅឆ្នាំ២០១៦ ដោយផ្តោតលើ៖




**១) ចំណេះដឹងវិជ្ជាជីវៈ** ដោយសំដៅលើចំណេះដឹ សិស្ស ពោលគឺស្គាល់សិស្ស យល់ដឹងពីស្ថានភាពគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស គោលនយោបាយអប់រំជាតិ មានចំណេះដឹងលើខ្លឹមសារមេរៀន ពោលគឺទ្រឹស្តីនៃការសរសេរកិច្ចតែងការ ខ្លឹមសារកម្មវិធីសិក្សា និងខ្លឹមសារបង្រៀន របៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ព្រមទាំងចំណេះដឹងពីរបៀបរៀនរបស់សិស្ស ដែលសំដៅ វិធីធ្វើឱ្យប្រសើរឡើងនៃបរិស្ថានថ្នាក់រៀន និងសហគមន៍ រៀនរបស់សិស្ស ភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្ស។

**២) ប្រតិបត្តិវិជ្ជាជីវៈ** ដោយសំដៅលើការធ្វើផែនការ និងការពិនិត្យតាមដានវាយតម្លៃលទ្ធផលសិក្សា ក្នុងនោះមានការរៀបចំកិច្ចតែងការ កម្មវិធីបង្រៀន វាយតម្លៃបានត្រឹមត្រូវ រៀបចំសម្ភារបង្រៀន រៀបចំសំណួរវាយតម្លៃ ចូលរួមតាមដានលទ្ធផលសិក្សារបស់សិស្ស ផ្តល់ព័ត៌មានត្រឡប់ទៅមាតាបិតាពីចំណេះដឹង បំណិន និងចរិយារបស់សិស្ស។ ការគ្រប់គ្រងបរិស្ថានសិក្សា ពោលគឺគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព និងជួយសិស្សឱ្យមានអន្តរកម្មជាមួយសិស្សដទៃ ជួយសិស្សបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន និងរៀបចំវិធីជួយសិស្សរៀនយឺត ចូលរួមអភិវឌ្ឍសាលារៀនដើម្បីទ្រទ្រង់ការសិក្សាសិស្ស និងមិត្តរួមអាជីព ព្រមទាំងវិធីបង្រៀន ដោយក្នុងនោះមានវិធីសាស្ត្របង្រៀនផ្សេងៗ ការផ្តល់មធ្យោបាយសមស្របទៅតាមរបៀបរៀនរបស់សិស្ស ការផ្តល់ឱកាសឱ្យសិស្សចូលរួមគិត និងដោះស្រាយបញ្ហាប្រកបដោយការច្នៃប្រឌិត និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការសិក្សាជាដើម។

**៣) សិក្សាវិជ្ជាជីវៈ** ដោយសំដៅលើការធ្វើស្វ័យសិក្សា ដូចជាវាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួន

និងការប្រើផែនការសម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់ អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងបំណិនក្នុងការបង្រៀន និងរៀន ព្រមទាំងចូលរួមកែលម្អការបង្រៀនតាមរយៈការអានអត្ថបទនានាទាក់ទងនឹងវិជ្ជាជីវៈគ្រូដើម្បីពង្រឹងចំណេះដឹងខ្លួនឯង និងចែករំលែកទៅអ្នកដទៃឱ្យការបង្រៀនកាន់តែប្រសើរ និងធ្វើអន្តរកម្មជាមួយគ្រូដទៃតាមរយៈការចូលរួមសិក្ខាសាលាវគ្គបំប៉ន និងចែកបទពិសោធជាដើម។

៤) **សីលធម៌វិជ្ជាជីវៈ** ដោយសំដៅលើការយកចិត្តទុកដាក់ និងថែរក្សាសិស្សជានិច្ច និងធ្វើការដើម្បីប្រយោជន៍សិស្ស និងសង្គម ប្ដេជ្ញាចិត្ត និងចូលរួមការចែករំលែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មានអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងទំនាក់ទំនងល្អជាមួយសិស្ស និងសហគមន៍ ព្រមទាំងប្រើប្រាស់ភាពយុត្តិធម៌ តម្លាភាព ក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសមាជិកដទៃក្នុងសហគមន៍។

ក្នុងទិសដៅធានាឱ្យបានថា គ្រូបង្រៀនដែលទទួលបានការបណ្ដុះបណ្ដាលរួចមានស្ដង់ដារវិជ្ជាជីវៈទាំង ៤ ដូចបានបញ្ជាក់ខាងលើ នៅឆ្នាំ២០២៤ ក្រសួងបានរៀបចំស្ដង់ដារវិជ្ជាជីវៈគ្រូឧទ្ទេសមត្តេយ្យ មជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីឱ្យសាលាគរុកោសល្យនានាអាចអប់រំគរុសិស្ស និស្សិត និងវិក្រឹតការគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាពតាមរយៈការធានាថា គរុនិស្សិតទាំងអស់ដែលបានបញ្ចប់កម្មវិធីអប់រំគ្រូបង្រៀន មានសមត្ថភាពបង្រៀនប្រកបដោយប្រសិទ្ធភាពនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងធានាថាកម្មវិធីអប់រំគ្រូបង្រៀនត្រូវបានរៀបចំឡើង និងអនុវត្តដើម្បីដឹកនាំគ្រូបង្រៀនដែលទើបចេញថ្មីចូលទៅក្នុងគន្លងអាជីពគ្រូបង្រៀនតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ស្ដង់ដារវិជ្ជាជីវៈគ្រូឧទ្ទេសមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគមានដូចខាងក្រោម៖




១) **ស្តង់ដាទី១៖ ចំណេះដឹងវិជ្ជាជីវៈ**

សំដៅលើចំណេះដឹងអំពីគរុនិស្សិត មុខវិជ្ជាឯកទេស វិធីរៀនរបស់គរុនិស្សិត និងបរិបទអប់រំ។

២) **ស្តង់ដាទី២៖ ៖ ប្រត្តិបត្តិវិជ្ជាជីវៈ**

សំដៅលើការរៀបចំផែនការ ការពិនិត្យតាមដាន និងការវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត ការគ្រប់គ្រង

បរិស្ថានសិក្សា វិធីសាស្ត្របង្រៀន និងកិច្ចសហការ។

**៣) ស្តង់ដាទី៣៖ ការអភិវឌ្ឍវិជ្ជាជីវៈ**

សំដៅលើការធ្វើស្វ័យសិក្សា និងការឆ្លុះបញ្ចាំង ការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការចូលរួមជាសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ។

**៤) ស្តង់ដាទី៤៖ សីលធម៌វិជ្ជាជីវៈ**

សំដៅលើការយកចិត្តទុកដាក់ចំពោះគរុនិស្សិត ការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវលើវិជ្ជាជីវៈគ្រូបង្រៀន ការធ្វើជាគំរូវិជ្ជមាននៃចរិយាធម៌ សមត្ថភាពលើកកម្ពស់វប្បធម៌ និងយុត្តិធម៌ក្នុងការអប់រំ ការវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត។

**៥) ស្តង់ដាទី៥៖ ការស្រាវជ្រាវអប់រំ**

សំដៅលើចំណេះដឹង និងជំនាញស្រាវជ្រាវអប់រំ ការអនុវត្តការស្រាវជ្រាវអប់រំ។

**៦) ស្តង់ដាទី៦៖ ការអនុវត្តកម្មវិធីអប់រំ**

សំដៅលើការអនុវត្ត និងការឆ្លុះបញ្ចាំងពីកម្មវិធីអប់រំគ្រូបង្រៀន ការផ្តល់ព័ត៌មានត្រឡប់ពីកម្មវិធីអប់រំគ្រូបង្រៀន។

## ២.១.៥. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

## ក. គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ក្នុងបរិបទនៃការអប់រំក្នុងសតវត្សរ៍ទី២១នេះ បុគ្គលិកអប់រំត្រូវបន្តធ្វើបច្ចុប្បន្នភាពលើវិជ្ជាសម្បទា និងបំណិនសម្បទា។ បុគ្គលិកអប់រំចាំបាច់ត្រូវមានចំណេះដឹងអំពីកម្មវិធីសិក្សា ដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន វិធីបង្រៀន ការវាយតម្លៃ និងត្រូវមានចំណេះដឹងអំពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងការងារអប់រំ ទើបអាចផ្តល់នូវសេវាអប់រំប្រកបដោយគុណភាព។

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធបានជំរុញលើកទឹកចិត្តធ្វើវិក្រឹតការនៅនឹងកន្លែង និងវិក្រឹតការផ្សេងៗតាមគ្រប់រូបភាព ប៉ុន្តែមិនទាន់មានសង្គតិភាព និង ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់ការអនុវត្តនៅឡើយ។ ការងារវិក្រឹតការកន្លងមកបានបំពេញតម្រូវការគ្រូបង្រៀនមួយភាគតូច និងមិនទាន់មានកាលកំណត់ជាក់លាក់ ព្រមទាំងមិនទាន់ផ្សារភ្ជាប់ទាំងស្រុងទៅនឹងប្រព័ន្ធវាយតម្លៃការបំពេញការងារ និងប្រព័ន្ធលើកទឹកចិត្តច្បាស់លាស់។

នៅឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងគោលនយោបាយស្តីពី «ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ» ដោយមានចក្ខុវិស័យបណ្តុះស្មារតីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ពេញមួយជីវិតការងារប្រកបដោយសមធម៌ ដល់បុគ្គលិកអប់រំគ្រប់រូប ក្នុងគោលបំណងអភិវឌ្ឍបុគ្គលិកអប់រំឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសក្តានុពលបំពេញការងាររហូតដល់ពេលបញ្ចប់អាជីព។ គោលនយោបាយនេះមានគោលដៅ៖ ១)ធានាឱ្យមានក្របខ័ណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ២)ធានាថាបុគ្គលិកអប់រំគ្រប់រូបនឹងទទួលបានវគ្គវិក្រឹតការទៀងទាត់ ៣)ធានាឱ្យមានការលើកទឹកចិត្តក្នុងការលើកកម្ពស់គុណវុឌ្ឍបុគ្គលិកអប់រំ ៤)ធានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពបុគ្គលិកអប់រំ និង ៥)ធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់បុគ្គលិកអប់រំ។

ដើម្បីសម្រេចឱ្យបាននូវគោលដៅដែលបានកំណត់ គោលនយោបាយស្តីពី «ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ» ក៏បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៦ គឺ ១)កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ២)កំណត់ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ៣)កំណត់តម្រូវការនៃការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ ៤)គ្រប់គ្រង និងអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ ៥)លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀនឱ្យនៅក្នុងប្រព័ន្ធអប់រំ និង ៦)អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។

## ខ. ការគាំទ្រគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

នៅឆ្នាំ២០២០ ក្រសួងបានបង្កើតការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីជាសេនាធិការឱ្យក្រសួងអប់រំ និងកីឡា ក្នុងការរៀបចំ និងកំណត់បទប្បញ្ញត្តិការអភិវឌ្ឍវិជ្ជាជីវៈ តាមរយៈក្រុមការងារអន្តរនាយកដ្ឋាន, គ្រប់គ្រងទិន្នន័យ និងក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, កំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព រួមមានស្តង់ដាគំរូ ការទទួលស្គាល់ និងការធានាគុណភាព, គ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលា និង អ្នកឯកទេសអប់រំ, អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) ក្នុងការគ្រប់គ្រងទិន្នន័យគ្រូបង្រៀន រួមមានទិន្នន័យការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំដូចបានកំណត់ក្នុងក្របខ័ណ្ឌគតិយុត្តិ និងផែនការសកម្មភាព ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា, គ្រប់គ្រងម៉ូឌុលនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) រួមមានព័ត៌មានអំពីអ្នកផ្តល់សេវា និងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងកត់ត្រាទិន្នន័យរបស់បុគ្គលិកអប់រំដែលបានអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ។

ក្នុងទិសដៅអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ប្រកបដោយប្រសិទ្ធភាព ក្រសួងបានរៀបចំក្របខ័ណ្ឌ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលានៅឆ្នាំ២០១៩។ ផែនការសកម្មភាព គ្របដណ្តប់ពីឆ្នាំ២០១៩-២០២៣ និងបន្តដល់ឆ្នាំ២០២៤។ នៅឆ្នាំ២០២១ ក្រសួងបានរៀបចំសៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំៈ មគ្គុទ្ទេសក៍ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនៅកម្ពុជា ដើម្បីបង្កភាពងាយស្រួលដល់ភាគីពាក់ព័ន្ធដូចជាគ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ អ្នកគ្រប់គ្រង អ្នកផ្តល់សេវាស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងបុគ្គលិកអប់រំដទៃទៀត ក្នុងការរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ឯកសារនេះក៏បានបញ្ជាក់ច្បាស់ពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតាមសាលារៀន, បែបបទអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមមានការរៀបចំផែនការសិក្សាវិជ្ជាជីវៈសម្រាប់បុគ្គលិកអប់រំ ការប្រើប្រាស់ប្រព័ន្ធក្រេឌីតក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, ទំនាក់ទំនង និងការបន្សុំរវាងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធដទៃទៀត, គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, បែបបទ និងយន្តការទទួលស្គាល់គុណភាពអ្នកផ្តល់សេវា និងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ព្រមទាំងព័ត៌មាន និងការផ្សព្វផ្សាយដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំពិសេសតាមប្រព័ន្ធអនឡាញជាដើម។

ក្នុងគោលបំណងផ្តល់ភាពងាយស្រួល ដល់ការងារគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់បុគ្គលិកអប់រំម្នាក់ៗ ក្រសួងក៏បានរៀបចំកម្មវិធីទូរសព្ទដៃវៃឆ្លាត HRCPD ដែលបុគ្គលិកអប់រំគ្រប់រូបអាចទាញយកមកប្រើប្រាស់ក្នុងទូរសព្ទវៃឆ្លាតរបស់ខ្លួន ដោយនៅក្នុងកម្មវិធីនេះ អ្នកប្រើប្រាស់អាចស្វែងរកសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ចុះឈ្មោះក្នុងសកម្មភាព ទទួលជាសិក្ខាកាម តាមដានការទទួលស្គាល់ការបញ្ចប់ដោយជោគជ័យនូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការតាមដានការសិក្សាមើលពីក្រេឌីតដែលទទួលបាន ព្រមទាំងពិនិត្យមើលព័ត៌មានផ្ទាល់ខ្លួន និងស្នើសុំកែតម្រូវជាដើម។

## ២.១.៦. គន្លងអាជីពគ្រូបង្រៀន

នៅឆ្នាំ២០១៨ ក្រសួងបានរៀបចំក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀនក្នុងគោលដៅទាក់ទាញ និងលើកទឹកចិត្តពលរដ្ឋពូកែ និងមានសមត្ថភាពក្នុងការចាប់យកអាជីពគ្រូបង្រៀន និងរក្សាគ្រូបង្រៀនល្អ នាយកល្អ និងអ្នកឯកទេសអប់រំពូកែៗដើម្បីបម្រើការងារក្នុងប្រព័ន្ធអប់រំ តាមរយៈការអភិវឌ្ឍគន្លងគ្រូបង្រៀន គន្លងគណៈគ្រប់គ្រងសាលារៀន និងគន្លងអ្នកឯកទេសអប់រំ, ការកំណត់លក្ខណៈវិនិច្ឆ័យ

និងសូចនាករគុណផលការងារនៅកម្រិតនីមួយៗនៃគន្លងអាជីពទាំងបី, ព្រមទាំងការបង្កើតយន្តការអនុវត្ត និងវាយតម្លៃជាប្រព័ន្ធ ដើម្បីទាក់ទាញ អភិវឌ្ឍ គាំទ្រ និងលើកទឹកចិត្តគ្រូបង្រៀន។

គន្លងអាជីពគ្រូបង្រៀនត្រូវបានបែងចែកជាបីគន្លងគឺ ១)គន្លងគ្រូបង្រៀន ២)គន្លងគណៈគ្រប់គ្រងសាលារៀន និង ៣)គន្លងអ្នកឯកទេសអប់រំ ដោយគន្លងនីមួយៗបែងចែកជាបីកម្រិតគឺ គ្រូឈានមុខគ្រូគំរូនិងគ្រូផ្ដើម,នាយកឈានមុខនាយកគំរូនិងនាយកផ្ដើម,និងអ្នកឯកទេសឈានមុខ អ្នកឯកទេសគំរូ និងអ្នកឯកទេសផ្ដើម។ ក្នុងលក្ខណៈវិនិច្ឆ័យបានកំណត់យកនូវលក្ខខណ្ឌតម្រូវ និងជម្រើសជាច្រើនមានជាអាទិ៍ សញ្ញាបត្រ អតីតភាពការងារ ព្រឹត្តិបត្រស្រាវជ្រាវវិជ្ជាជីវៈ សម្ភារឧបទេស សៀវភៅ ឯកសារសោតទស្សន៍ដែលបេក្ខជនបានផលិត ឬសរសេរ ការរៀបចំតេស្តស្តង់ដា សមត្ថភាពភាសាបរទេស បំណិនក្នុងការប្រើប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការរៀន និងបង្រៀន និងការចូលរួមក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ បទពិសោធពិសេសពោលគឺចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀនក្នុងតំបន់ជួបការលំបាក លិខិតគាំទ្រវិជ្ជាជីវៈដែលបញ្ជាក់ពីក្រមសីលធម៌វិជ្ជាជីវៈរបស់បេក្ខជន និងស្នាដៃកន្លងមក។

នៅឆ្នាំ២០២១ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនត្រូវបានយកមកពិនិត្យ និងកែលម្អបន្ថែមឱ្យស្របតាមតម្រូវការជាក់ស្តែង ដោយបែងចែកអាជីពគ្រូបង្រៀនជាបីគន្លងគឺ ១)គន្លងបង្រៀន ២)គន្លងគ្រប់គ្រង និង ៣)គន្លងឯកទេសអប់រំ ដោយគន្លងនីមួយៗបែងចែកជាបីកម្រិតគឺ គ្រូល្អ គ្រូឈានមុខ និងគ្រូផ្តើម, នាយកល្អ នាយកឈានមុខ និងនាយកផ្តើម, និង អ្នកឯកទេសអប់រំល្អ អ្នកឯកទេសអប់រំឈានមុខ និងអ្នកឯកទេសអប់រំផ្តើម។ ក្របខណ្ឌដែលកែលម្អរួចនេះ បានបែងចែកគន្លងអ្នកឯកទេសអប់រំជាប្រាំឯកទេស រួមមាន ១)គោលនយោបាយ និងផែនការអប់រំ ២)អភិវឌ្ឍន៍កម្មវិធីសិក្សា ៣)ការវាយតម្លៃលទ្ធផលសិក្សា ៤)គរុកោសល្យ និងវិធីសាស្ត្របង្រៀន និង ៥)ការគ្រប់គ្រងរដ្ឋបាលអប់រំ។



សម្រាប់លក្ខណៈវិនិច្ឆ័យ គឺផ្តោតលើចំណុចសំខាន់ៗដូចជា គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ លទ្ធផលសិក្សារបស់សិស្ស និងសមត្ថភាពវិជ្ជាជីវៈ សម្រាប់គន្លងបង្រៀន និងគន្លងគ្រប់គ្រង រីឯគន្លងឯកទេសអប់រំ ផ្តោតលើគុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ និងសមត្ថភាព វិជ្ជាជីវៈ។

ការរៀបចំគន្លងអាជីពគ្រូបង្រៀននេះ គឺជាផ្នែកមួយសំខាន់ក្នុងការបំពេញប្រព័ន្ធគាំទ្រគ្រូបង្រៀនឱ្យមានភាពពេញលេញ គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់ ពោលគឺទំនាក់ទំនងរវាងគន្លងអាជីពគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដានាយកសាលារៀន។




ទំនាក់ទំនងរវាងគន្លងអាជីពគ្រូបង្រៀន
ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដានាយក[7]

[7] ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន ២០២១

## ២.១.៧. ផែនការអភិវឌ្ឍសាលាគរុកោសល្យ

*នៅឆ្នាំ២០១៩ ក្រសួងបានដាក់ចេញនូវផែនការសកម្មភាពស្តីពីការអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្តសម្រាប់ទិសដៅរយៈពេល ៥ ឆ្នាំ (២០១៩-២០២៣) ក្នុងទិសដៅអភិវឌ្ឍគ្រូបង្រៀនឱ្យក្លាយជាភ្នាក់ងារដឹកនាំសិស្សឱ្យបង្កើតឧត្តមភាពសម្រាប់សង្គមតាមរយៈ ១)ការពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងនៅតាមគ្រឹះស្ថានបណ្តុះ-បណ្តាលគ្រូ ២)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យស្របតាមស្តង់ដា និងបច្ចេកវិទ្យាជំនាន់ថ្មី ៣)អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសឱ្យមានគុណសម្បទាសតវត្សរ៍ទី២១ កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបនឹងកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស និងតម្រូវការសង្គម ក្នុងយុគសម័យឧស្សាហកម្មជំនាន់៤.០ ៤)លើកកម្ពស់ការស្រាវជ្រាវ និងប្រើប្រាស់ការស្រាវជ្រាវសម្រាប់កែលម្អការរៀន និងបង្រៀន ស្របតាមក្របខ័ណ្ឌដូចខាងក្រោម៖*



ដើម្បីសម្រេចបានតាមគោលដៅ ផែនការយុទ្ធសាស្ត្រនេះបានកំណត់យុទ្ធសាស្ត្រចំនួន ៩ គឺៈ

**១) ពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងនៅតាមសាលាគរុកោសល្យ**

- រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីដាក់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង
- ពិនិត្យឡើងវិញលក្ខណៈវិនិច្ឆ័យគ្រូឧទ្ទេសជ្រើសរើសថ្មី និងផ្លាស់ប្តូរទីកន្លែងធ្វើការ
- ពិនិត្យ និងកែលម្អផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឱ្យឆ្លើយតបនឹងតម្រូវការនៃបរិបទរៀន និងបង្រៀនសតវត្សរ៍ទី២១
- ពិនិត្យ និងកែលម្អយន្តការ និងដំណើរការតាមដាន និងវាយតម្លៃ លទ្ធផលសិក្សា
  - ពិនិត្យតាមដានការបណ្តុះបណ្តាល
  - វាយតម្លៃសមត្ថភាពគរុសិស្ស-និស្សិត
  - បូកសរុបការងារបណ្តុះបណ្តាលប្រចាំឆ្នាំ
- ផ្តល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់អ្នកគ្រប់គ្រង
- រៀបចំការប្រឡងប្រណាំងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូល្អ គ្រូឧទ្ទេសល្អ
- ជំរុញកិច្ចសហការជាមួយដៃគូ សហគមន៍ និងសាលារៀន

**២) អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងកម្មវិធីវិក្រឹតការ និងឯកសាររៀននិងបង្រៀន**

- ពិនិត្យឡើងវិញ និងទំនើបកម្មកម្មវិធីបណ្តុះបណ្តាល
  - វាយតម្លៃកម្មវិធីដែលកំពុងអនុវត្ត
  - រៀបចំកម្មវិធីថ្មី
  - សាកល្បងកម្មវិធីថ្មី
- ពិនិត្យឡើងវិញ និងធ្វើទំនើបកម្មកម្មវិធីវិក្រឹតការ
- ពិនិត្យឡើងវិញកម្មវិធីគ្រូជួយគ្រូបង្រៀន(mentoring)
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យ
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ

**៣) អភិវឌ្ឍគុណវុឌ្ឍិគ្រូឧទ្ទេស គណៈគ្រប់គ្រង និងបុគ្គលិក**

- រៀបចំប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកគ្រប់គ្រង គ្រូឧទ្ទេស និងបុគ្គលិក
- រៀបចំស្តង់ដាគ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- កំណត់តម្រូវការនៃចំណេះវិជ្ជា និងបំណិនឯកទេសដែលត្រូវអភិវឌ្ឍជាចាំបាច់

- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូឧទ្ទេស និងបុគ្គលិក
  - បំប៉នគ្រូឧទ្ទេសថ្នាក់ជាតិ
  - បំប៉នគ្រូឧទ្ទេស
  - បំប៉នបុគ្គលិករដ្ឋបាល
- ទទួលស្គាល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូឧទ្ទេស តាមប្រព័ន្ធក្រេឌីត
- កសាងបណ្តាញគ្រូឧទ្ទេសតាមមុខវិជ្ជា
- លើកកម្ពស់ការស្រាវជ្រាវ និងប្រើប្រាស់លទ្ធផលស្រាវជ្រាវ
- ទទួលស្គាល់ ចងក្រង និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ
- បណ្តុះបណ្តាលជំនាញស្រាវជ្រាវដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការរៀននិងបង្រៀន

**៤) លក្ខខណ្ឌការងារ និងការរស់នៅរបស់គ្រូឧទ្ទេស**

- ពិនិត្យឡើងវិញលើប្រាក់មុខងារ និងការលើកទឹកចិត្តរបស់គ្រូឧទ្ទេស
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធវាយតម្លៃគ្រូឧទ្ទេស និងការលើកទឹកចិត្តដល់គ្រូឧទ្ទេស
- កែលម្អ ឬរៀបចំបន្ទប់ការងារប្រចាំថ្ងៃសម្រាប់គ្រូឧទ្ទេសដែលបំពាក់ដោយបរិក្ខារចាំបាច់
- កែលម្អឬបង្កើតប្រព័ន្ធលើកទឹកចិត្តនិងគាំទ្រដល់គ្រូឧទ្ទេស
- ផ្សារភ្ជាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូឧទ្ទេសទៅនឹងគន្លងអាជីពគ្រូបង្រៀន
- ផ្តល់ឱកាសនិងលើកទឹកចិត្តដល់គ្រូឧទ្ទេសដើម្បីឱ្យមានការផ្លាស់ប្តូរបទពិសោធតាមគ្រប់រូបភាព

**៥) ការជ្រើសរើសគរុសិស្ស-គរុនិស្សិតប្រកបដោយសក្តានុពល**

- ពិនិត្យ និងពង្រឹងដំណើរការជ្រើសរើសគរុសិស្ស គរុនិស្សិត ដើម្បីទទួលបានសិស្សដែលមានសមត្ថភាពចូលរៀនក្នុងប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន

**៦) កែលម្អលក្ខខណ្ឌធ្វើការរបស់គរុសិស្ស-គរុនិស្សិត**

- កសាងអន្តេវាសិកដ្ឋាន
- ពិនិត្យ និងកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់គរុសិស្ស គរុនិស្សិត

**៧) ថវិកាគាំទ្រ**

- ផ្តល់ថវិកាឱ្យទាន់ពេលវេលា
- ផ្តល់ថវិកាសម្រាប់ការស្រាវជ្រាវគរុកោសល្យ
- កៀរគរថវិកា និងការឧបត្ថម្ភគាំទ្រពីច្រើនប្រភព

**៨) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ**

- កែលម្អបរិស្ថាន និងអនាម័យក្នុងបរិវេណគ្រឹះស្ថាន
- រៀបចំបន្ទប់សិក្សា បន្ទប់ពហុបំណង បន្ទប់Micro-Teaching បន្ទប់រោងជាង បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ និងបន្ទប់ភាសា ដែលបំពាក់ដោយបរិក្ខារស្របតាមបច្ចេកវិទ្យាថ្មីៗ និងឆ្លើយតបនឹងការរៀន និងបង្រៀនក្នុងសតវត្សរ៍ទី២១
- រៀបចំបណ្ណាល័យ និងឯកសារគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ

**៩) ការផ្សារភ្ជាប់រវាងសាលាគរុកោសល្យ និងសាលាអនុវត្តន៍ និងសាលាសហការ**

- ពិនិត្យ និងកែលម្អគោលការណ៍ណែនាំសម្រាប់កម្មសិក្សានៅតាមសាលាអនុវត្តន៍
- ពិនិត្យនិងកែលម្អប្រព័ន្ធវាយតម្លៃលើគុណសម្បទា និងគុណផលរបស់គរុសិស្ស គរុនិស្សិតពេលចុះកម្មសិក្សា

គិតត្រឹមឆ្នាំ២០២៤ នេះ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំរួចជាស្រេចនូវគោលនយោបាយស្តីពីគ្រូបង្រៀន ព្រមទាំងប្រព័ន្ធគាំទ្រគ្រប់ជ្រុងជ្រោយទាំងក្នុងការបណ្តុះបណ្តាល វិក្រឹតការ និងប្រព័ន្ធគាំទ្រគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ។ ការដាក់ចេញនូវកំណែទម្រង់សាលាគរុកោសល្យ ពោលគឺសំដៅលើការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឱ្យក្លាយជា «គ្រូបង្រៀនប្រកបដោយឧត្តមភាព» ស្របតាមបរិបទសតវត្សរ៍ទី ២១ នេះ បានទទួលការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល ដោយអាចបញ្ជាក់បានតាមរយៈការប្រែក្លាយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ តាមរយៈអនុក្រឹតលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤។

## ២.២. ការពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងនៅតាមសាលាគរុកោសល្យ

### ២.២.១. ការលើកកម្ពស់កម្រិតបណ្តុះបណ្តាលគ្រូ

### ក. ការប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការជាវិទ្យាស្ថានគរុកោសល្យ

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបងត្រូវបានបង្កើតឡើង ដែលដើមឡើយជាអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ និងជាអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង និងសាលាគរុកោសល្យនិងវិក្រឹតការខេត្តបាត់ដំបង។ វិទ្យាស្ថាន











ការបណ្តុះបណ្តាលដែលនាំមកនូវនវានុវត្តន៍ និងសាមគ្គីភាពនៅវិទ្យាស្ថានទាំងពីរ

គរុកោសល្យទាំងពីរនេះមានការកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់បរិញ្ញាបត្រអប់រំ តាមប្រព័ន្ធ ១២+៤ និងធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ។ នៅឆ្នាំ ២០២២ វិទ្យាស្ថានគរុកោសល្យទាំងពីរបានទទួលស្គាល់ជាគ្រឹះស្ថានឧត្តមសិក្សា ដែលមានឋានៈស្មើអគ្គនាយកដ្ឋាន។ នៅឆ្នាំ២០២៤ វិទ្យាស្ថានគរុកោសល្យទាំងពីរក៏បានចាប់ផ្តើមអនុវត្តការបណ្តុះបណ្តាលគ្រូអនុវិទ្យាល័យតាមប្រព័ន្ធបរិញ្ញាបត្រ+១ ផងដែរ។

ក្នុងទិសដៅលើកកម្ពស់គុណភាពនៃការគ្រប់គ្រង ក្រសួងបានរៀបចំយន្តការ ក្នុងការជ្រើសរើសនាយកវិទ្យាស្ថានតាមរយៈការប្រឡង ដោយមានវិញ្ញាសារសរសេរ និងការសម្ភាស។ បច្ចុប្បន្ន វិទ្យាស្ថានទាំងពីរដឹកនាំដោយនាយកដែលមានសញ្ញាបត្របណ្ឌិត និងមានបទពិសោធក្នុងការដឹកនាំ ស្រាវជ្រាវក្នុងវិស័យអប់រំ និងគណៈគ្រប់គ្រងដែលមានគុណវុឌ្ឍិចាប់ពីសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។

នៅខែធ្នូ ឆ្នាំ២០២២ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបងបានទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិសម្រាប់រយៈពេល ៥ ឆ្នាំ ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC)។ វិញ្ញាបនបត្រនេះបញ្ជាក់ពីការបំពេញបាននូវគុណភាពអប់រំឧត្តមសិក្សាតាមស្តង់ដាជាតិរួមមាន ១)ចក្ខុវិស័យ បេសកកម្ម និងគោលបំណងដែលឆ្លើយតបនឹងតម្រូវការថ្នាក់ជាតិ តំបន់ ឬអន្តរជាតិ ២)អភិបាលកិច្ច និងការគ្រប់គ្រង ៣)បុគ្គលិកអប់រំ ៤)កម្មវិធីអប់រំ ៥)សេវានិស្សិត ៦)ធនធានសិក្សា ៧)ធនធានរូបវន្ត ៨)ធនធានហិរញ្ញវត្ថុ និង ៩)ការធានាគុណភាពអប់រំផ្ទៃក្នុង។

តាមរយៈការអនុវត្តកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន វិទ្យាស្ថានគរុកោសល្យទាំងពីរបានខិតខំធ្វើការអភិវឌ្ឍលើគ្រប់រូបភាព ទាំងខាងផ្នែករឹង និងផ្នែកទន់ ដោយមានការគាំទ្រពីជំនួយហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលនៃប្រទេសជប៉ុន និងប្រជាជនជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារ JICA រួមជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ ដៃគូអភិវឌ្ឍនានាផ្សេងទៀត។

## ខ. ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស

ក្នុងឆ្នាំ២០១៧ វិទ្យាល័យអប់រំពិសេសទាំង ៥ របស់អង្គការគ្រួសារថ្មី បានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន កីឡា។ ក្នុងឆ្នាំដដែល ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់បង្រៀនកុមារពិការនៅកម្ពុជា និងឈរលើគោលការណ៍គោរពអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន «វិទ្យាស្ថានជាតិអប់រំពិសេស»

ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។ វិទ្យាស្ថាននេះមានតួនាទីជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡាលើបញ្ហាអប់រំកុមារមានពិការភាព ការបណ្តុះបណ្តាលគ្រូ និងវិក្រឹតការគ្រូ និងធនធានសម្រាប់ទ្រទ្រង់ដល់វិស័យអប់រំកុមារមានពិការភាពនៅកម្ពុជា។

ក្នុងខែមិថុនា ឆ្នាំ២០២០ ក្រសួងបានរៀបចំ «កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនជំនាញអប់រំពិសេស» លើជំនាញពិការភ្នែក និងជំនាញគថ្លង់ ក្នុងគោលបំណងផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ដែលមានសញ្ញាបត្រគរុកោសល្យស្រាប់ ឱ្យមានជំនាញអប់រំពិសេសស្របតាមស្តង់ដារជាតិ និងអន្តរជាតិ។ កម្មវិធីនេះមានរយៈពេល ១ ឆ្នាំ ដោយផ្តោតទាំងខ្លឹមសារ វិធីសាស្ត្របង្រៀន និងវិធីវាយតម្លៃលទ្ធផលសិក្សារបស់គរុសិស្សស្របតាមគុណសម្បទាសតវត្សរ៍ទី២១ និងតម្រូវការទីផ្សារការងារជាក់ស្តែង។

នៅឆ្នាំ២០២១ ក្រសួងបានប្រែក្លាយសាលាអង្គការជំនួយនៃក្តីសង្ឃឹមសម្រាប់សហគមន៍ ទៅជាវិទ្យាល័យអប់រំពិសេសក្រុងតាខ្មៅ។ ក្នុងន័យនេះ វិទ្យាស្ថានជាតិអប់រំពិសេសក៏បានពង្រីកវិសាលភាពខ្លួនក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនសិស្សពិការសតិបញ្ញា និងអូទីសឹមផងដែរ។

## គ. ការប្រែក្លាយវិទ្យាស្ថានជាតិអប់រំជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ

វិទ្យាស្ថានជាតិអប់រំ គឺជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនតែមួយគត់ដែលទទួលបន្ទុក ១) បណ្តុះបណ្តាលដំបូងដល់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ២)វិក្រឹតការគ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំ និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ជាពិសេសគ្រូបង្រៀននៅតាមសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញ សម្រាប់កែលម្អការបង្រៀន និងការវាយតម្លៃ ដោយអនុវត្តតាមក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីថ្នាក់ទី១០-១២ រួមទាំងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និង ៣) ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់នាយកសាលារៀន អធិការអប់រំ និងមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។

ក្នុងថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ វិទ្យាស្ថានជាតិអប់រំបានទទួលការអនុញ្ញាត ក្នុងការបណ្តុះ-បណ្តាលបរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសវិទ្យាសាស្ត្រ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ផងដែរ។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ វិទ្យាស្ថានជាតិអប់រំក៏បានទទួលការអនុញ្ញាតក្នុងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យបន្ថែមទៀត ដើម្បីចូលរួមលើកកម្ពស់វិធីសាស្ត្របង្រៀនស្របតាមតម្រូវការសតវត្សរ៍ទី២១ នៅតាមសាលាជំនាន់ថ្មី។









សកម្មភាពបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានជាតិអប់រំពិសេស









សកម្មភាពបណ្តុះបណ្តាលគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ

ក្នុងគោលបំណងប្រែក្លាយវិទ្យាស្ថានជាតិអប់រំ ឱ្យទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ និងមានការទទួលស្គាល់កម្រិតតំបន់ និងសកលលោក ក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍន៍គ្រូបង្រៀន អ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកស្រាវជ្រាវ និងអ្នកវាយតម្លៃគុណភាពអប់រំ វិទ្យាស្ថានជាតិអប់រំបានទទួលអនុក្រឹតថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិអប់រំ ពីរាជរដ្ឋាភិបាលនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ក្នុងការកំណត់ អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិអប់រំ ឱ្យស្រប តាមលក្ខណៈវិនិច្ឆ័យរបស់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីក្លាយជាមជ្ឈមណ្ឌលឧត្តមភាពក្នុងការបណ្តុះ-បណ្តាលគ្រូបង្រៀន និងភាពជាអ្នកដឹកនាំ ការអភិវឌ្ឍជាប្រចាំ ការស្រាវជ្រាវ និងការលើកកម្ពស់ការរៀន និងបង្រៀន សំដៅរួមចំណែកអភិវឌ្ឍប្រទេស និងលើកស្ទួយអត្តសញ្ញាណជាតិ។ អនុក្រឹត្យនេះក៏កំណត់ផងដែរនូវរចនាសម្ព័ន្ធថ្មីរបស់វិទ្យាស្ថាន។

ក្នុងឆ្នាំ២០២៤ នេះ ក្នុងទិសដៅលើកកម្ពស់គុណភាពអប់រំនៅកម្រិតមធ្យមសិក្សា វិទ្យាស្ថានជាតិអប់រំបានលើកកម្ពស់កម្មវិធីបណ្តុះបណ្តាលដំបូងដល់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ពីការអនុវត្តកម្មវិធីបញ្ញាបត្រ+១ មកជាបញ្ញាបត្រ+២ ដែលមានតម្លៃសមមូលទៅនឹងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។ វិទ្យាស្ថានក៏បានបើកទទួលគរុនិស្សិតបង់ថ្លៃជំនាន់ទី១ ក្នុងការសាកល្បងឈានទៅដល់ការអនុវត្តការផ្តល់អាជ្ញាបណ្ណគ្រូបង្រៀន ជាលើកដំបូងផងដែរ។

គិតមកដល់ឆ្នាំ២០២៤នេះ វិទ្យាស្ថានជាតិអប់រំ បាននិងកំពុងអនុវត្តកម្មវិធីចំនួន ៨ គឺ

១)ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញាបត្រ+២ ២)ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានភាសាបារាំងតាមប្រព័ន្ធ១២+៤ ៣)ការបណ្តុះបណ្តាលនាយកសាលាមធ្យមសិក្សាទុតិយភូមិ ៤)ការបណ្តុះបណ្តាលអធិការអប់រំ ៥)ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ៦)ការបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ភាសាបារាំង ៧)ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ប្រឹក្សាគរុកោសល្យ និង ៨)ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតអប់រំ។

## ២.២.២. ការគ្រប់គ្រងសាលាគរុកោសល្យ

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៤ នៅខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តទាំង ១៥ និងសាលាអនុវត្តន៍ ត្រូវបានផ្ទេរការគ្រប់គ្រងឱ្យមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងអប់រំ យុវជន និងកីឡា។

ក្នុងឆ្នាំដដែលនេះ អនុវិទ្យាល័យអនុវត្តន៍ និងបឋមសិក្សាអនុវត្តន៍នៃមន្ទីរអប់រំ យុវជន និងកីឡា

ខេត្តបាត់ដំបង ក៏ត្រូវបានផ្ទេរមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានគរុកោសល្យបាត់ដំបង រីឯអនុវិទ្យាល័យអនុវត្តន៍ និងបឋមសិក្សាអនុវត្តន៍នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ក៏ត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដូចគ្នា។ យន្តការនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សារភ្ជាប់វិទ្យាស្ថានគរុកោសល្យទៅនឹងសាលាអនុវត្តន៍ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀននិងរៀនរបស់ គរុសិស្ស គរុនិស្សិត និងដើម្បីពិនិត្យ និងកែលម្អគោលការណ៍ណែនាំសម្រាប់កម្មសិក្សានៅតាមសាលាអនុវត្តន៍ ព្រមទាំងពិនិត្យនិងកែលម្អប្រព័ន្ធវាយតម្លៃលើគុណសម្បទា និងគុណផលរបស់គរុសិស្ស គរុនិស្សិត ពេលចុះកម្មសិក្សា។

## ២.៣. ការអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាលនិងកម្មវិធីក្រឹតការ និងឯកសាររៀននិងបង្រៀនប្រព័ន្ធបណ្ដុះបណ្ដាលគ្រូក្នុងឆ្នាំ២០២៤




ប្រព័ន្ធបណ្ដុះបណ្ដាលគ្រូក្នុងឆ្នាំ២០២៤

### ២.៣.១. ការអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាល

### ក. កម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន(១២+៤) សម្រាប់គ្រូបឋមសិក្សា និងគ្រូកម្រិតមូលដ្ឋាន

ស្របពេលបង្កើតវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង នៅឆ្នាំ២០១៧ ក្រសួងបានប្រែក្លាយការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិពី១២+២ មកជាថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន១២+៤ ដោយអនុវត្តការសិក្សាតាមប្រព័ន្ធក្រេឌីតពេញលេញ ការវាយតម្លៃតាមប្រព័ន្ធ មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ការលើក

កម្ពស់ស្វ័យសិក្សា និងការសិក្សាស្រាវជ្រាវរបស់គរុនិស្សិត។ កម្មវិធីសិក្សានេះមានក្រេឌីតសរុបចំនួន ១២០ ដោយផ្តោតលើ ១)ការសិក្សាពីការអប់រំ ២)ការសិក្សាពីកម្មវិធីសិក្សា ៣)ចំណេះដឹងលើមុខវិជ្ជាឯកទេស ៤)ការលើកកម្ពស់សមត្ថភាពភាសា និងបំណិនឧទ្ទេស សរសេរសម្រាប់ការបង្រៀន ៥) មុខវិជ្ជារួម និង ៦)កម្មសិក្សាគរុកោសល្យ។ រីឯការបណ្តុះបណ្តាលតាមប្រព័ន្ធ ១២+២ នៅបន្តអនុវត្តរហូតដល់គរុសិស្សជ្រើសរើសចុងក្រោយឆ្នាំ២០២៤ បញ្ចប់ការសិក្សា។ ក្នុងន័យនេះ ប្រព័ន្ធ ១២+២ នឹងលែងអនុវត្តទាំងស្រុងនៅឆ្នាំសិក្សា ២០២៦-២០២៧។

## ខ. ការបញ្ចូលកញ្ចប់អំណានថ្នាក់ដំបូង និងគណិតថ្នាក់ដំបូងក្នុងកម្មវិធីបណ្តុះបណ្តាល

ក្នុងឆ្នាំ២០១៨ ក្រសួងបានដាក់ចេញឱ្យសាកល្បងនូវកញ្ចប់អំណានថ្នាក់ដំបូងនៅកម្រិតបឋមសិក្សា ក្នុងទិសដៅពង្រឹងសមត្ថភាពអាន សរសេរ ស្តាប់ និងនិយាយភាសាខ្មែររបស់សិស្សានុសិស្សឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ ដេប៉ាតឺម៉ង់ភាសានៃវិទ្យាស្ថានគរុកោសល្យទាំងពីរក៏ដូចជានាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការក៏បានសហការជាមួយអង្គការ RTI ដែលជាអង្គការលេចធ្លោក្នុងការរៀបចំកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមរយៈកម្មវិធីកុមាររៀនកុមារចេះ ក្នុងការរៀបចំកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនការអាន និងសរសេរភាសាខ្មែរកម្រិតទាប និងកម្រិតខ្ពស់។ ក្នុងការរៀបចំនេះ ក្រុមការងារបានបញ្ចូលកញ្ចប់អំណាននេះទៅក្នុងកម្មវិធីបង្រៀនគរុសិស្ស គរុនិស្សិតផងដែរ។ ការអនុវត្តដោយប្រើកញ្ចប់អំណានថ្នាក់ដំបូងនេះបានប្រព្រឹត្តឡើងចាប់តាំងពីឆ្នាំ២០២០មក ទៅលើគរុនិស្សិតជំនាន់ទី១ រហូតដល់បច្ចុប្បន្ននេះ។

វិធីសាស្ត្របង្រៀនបែបកញ្ចប់អំណានដំបូងនេះ ត្រូវបានបញ្ជ្រាបក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូកម្រិតបឋមសិក្សា ១២+២ ដែលបន្តអនុវត្តនៅតាមសាលាគរុកោសល្យ និងវិក្រឹតការទាំង១៦ និងក្នុងកម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន ១២+៤ កម្រិតបឋមសិក្សាចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី៤។ នៅក្នុងឆ្នាំទី២ ឆមាសទី១ កម្មវិធីនេះផ្តោតលើមុខវិជ្ជាវិធីសាស្ត្របង្រៀនការអាន ការសរសេរភាសាខ្មែរកម្រិតទាប និងបានបញ្ចូលវិធីសាស្ត្របង្រៀនកញ្ចប់អំណានថ្នាក់ទី១ ដោយផ្តោតលើសមាសភាគទាំង៥ (ការស្គាល់សូរ ការស្គាល់តួ អក្សរនិងសូរ វាក្យសព្ទ ការអានស្ទាត់ និងការអានយល់ន័យ) សកម្មភាពគោលទាំង៧ (ការស្គាល់សូរ ការស្គាល់តួអក្សរ ការអានព្យាង្គ និងពាក្យ វាក្យសព្ទ ការអាន

ល្បះ ការអានអត្ថបទខ្លី និងការសរសេរ) ដោយប្រើគោលការណ៍៣ (គ្រូធ្វើ គ្រូនិងសិស្សធ្វើ និង សិស្សធ្វើ)។ នៅឆ្នាំទី២ ឆមាសទី២ កម្មវិធីនេះផ្តោតលើមុខវិជ្ជាវិធីសាស្ត្របង្រៀនការអាន ការសរសេរភាសាខ្មែរកម្រិតទាប (កញ្ចប់ អំណានថ្នាក់ទី២ និងទី៣) ដោយពង្រឹងបន្ថែមលើចំណេះដឹងពីកញ្ចប់អំណានដំបូង ព្រមទាំងផ្តោតលើការហ្វឹកហាត់ការបង្រៀនតាមកញ្ចប់អំណានដំបូង។ នៅឆ្នាំទី៣ ឆមាសទី១ មុខវិជ្ជាវិធីសាស្ត្របង្រៀនការអាន សរសេរភាសាខ្មែរកម្រិតខ្ពស់ (ថ្នាក់ទី៤ ដល់ទី៦) ផ្តោតលើវិធីសាស្ត្របង្រៀនការអានយល់ន័យ និងការសរសេរ និងវិធីសាស្ត្របង្រៀនបំណិនផ្សេងៗ។ វិធីសាស្ត្របង្រៀននៅឆ្នាំទី៣នេះ ក៏នៅតែបញ្ជ្រាបវិធីសាស្ត្របង្រៀនបែបកញ្ចប់អំណានដំបូងនេះ។ នៅឆ្នាំទី៣ ឆមាសទី២ មុខវិជ្ជាវិធីសាស្ត្របង្រៀនការអាន សរសេរភាសាខ្មែរ កម្រិតខ្ពស់ (ថ្នាក់ទី៤ ដល់ទី៦) បានផ្តោតលើវិធីសាស្ត្របង្រៀន

ការអានយល់ន័យ និងការសរសេរ និងវិធីសាស្ត្របង្រៀនបំណិនផ្សេងៗ ព្រមទាំងផ្តោតលើការហ្វឹកហាត់ក្រុមតូច ក្រុមធំ ដើម្បីឱ្យកាន់តែស្ទាត់ជំនាញ។ នៅឆ្នាំទី៤ ឆមាសទី១ និង ឆមាសទី២ ការសិក្សារបស់គរុសិស្ស គរុនិស្សិតផ្តោតលើការវាយតម្លៃការសិក្សាកញ្ចប់អំណានដំបូង និងការកែលម្អការបង្រៀនភាសាខ្មែរ។

ទន្ទឹមគ្នានេះ ក្រសួងតាមរយៈនាយកដ្ឋានបឋមសិក្សា ដោយមានការចូលរួមពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត បានសហការជាមួយអង្គការយូណេស្កូ (UNESCO) បានផលិតកញ្ចប់គណិតវិទ្យាថ្នាក់ដំបូងសម្រាប់ថ្នាក់ទី១ ទី២ និងទី៣ ដែលមានដាក់បញ្ចូលនូវវិធីសាស្ត្របង្រៀនថ្មីៗប្រកបដោយភាពច្នៃប្រឌិត មានសម្ភារៈសម្បូរបែបទាក់ទាញឱ្យសិស្សចូលចិត្តរៀនសូត្រ និងរៀនសូត្រតាមរយៈការលេងកម្សាន្ត។ កញ្ចប់គណិតវិទ្យាថ្នាក់ទី១ និងទី២ ត្រូវដាក់ឱ្យសាកល្បងនៅខេត្តសៀមរាបក្នុងឆ្នាំ ២០១៨ ដល់២០២០ ដើម្បីលើកកម្ពស់សមត្ថភាពសិស្សនៅកម្រិតបឋមសិក្សា។ កញ្ចប់គណិតវិទ្យាកម្រិតថ្នាក់ដំបូងនេះ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនចាប់ពីឆ្នាំ២០២២ នៅតាមសាលាគរុកោសល្យ និងវិក្រឹតការទាំង១៦ ដែលអនុវត្តកម្មវិធី ១២+២ និងក្នុងកម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន ១២+៤ កម្រិតបឋមសិក្សាចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី៤ ផងដែរ។



## គ. កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនអនុវិទ្យាល័យតាមប្រព័ន្ធថ្នាក់បរិញ្ញាបត្រ+១

នៅឆ្នាំ២០២៤ នេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនអនុវិទ្យាល័យ តាមប្រព័ន្ធបរិញ្ញាបត្រ+១ ដោយចាប់ផ្តើមដាក់ឱ្យអនុវត្តនៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង និងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សម្រាប់គ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យា។ កម្មវិធីសិក្សានេះមានក្រេឌីតសរុបចំនួន ៣០ ក្រេឌីត ដោយចែកជា ៥ បណ្តុំមុខវិជ្ជាសិក្សា ១)ចំណេះដឹងលើមុខវិជ្ជាឯកទេស ២)ការសិក្សាពីការអប់រំ ៣)ការសិក្សាពីកម្មវិធីសិក្សា ៤) កម្មសិក្សាគរុកោសល្យ និង៥)ការស្រាវជ្រាវ។ គ្រូបង្រៀនដែលមានបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនអនុវិទ្យាល័យតាមប្រព័ន្ធបរិញ្ញាបត្រ +១ នេះ ហើយបានបំពេញការងារយ៉ាងតិច ៣ឆ្នាំ មានសិទ្ធិបន្តការសិក្សាតាមរយៈកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនយ៉ាងតិច ១៥ ក្រេឌីត បន្ថែមទៀតនៅគ្រឹះស្ថានអប់រំគ្រូបង្រៀន ដើម្បីទទួលបានបរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនវិទ្យាល័យ។ នេះគឺជានវានុវត្តន៍ថ្មីមួយដែលមានលក្ខណៈទន់ភ្លន់ និងផ្តល់ឱកាស ក៏ដូចជាលើកទឹកចិត្តគ្រូបង្រៀនឱ្យបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## ឃ. កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ+២ សម្រាប់គ្រូកម្រិតឧត្តម

នៅឆ្នាំ២០២១ វិទ្យាស្ថានជាតិអប់រំបានរៀបចំក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ដែលបានដាក់ឱ្យអនុវត្តជាលើកដំបូងនៅក្នុងឆ្នាំសិក្សា២០២៣-២០២៤។ ក្របខ័ណ្ឌកម្មវិធីនេះ ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ឱ្យឆ្លើយតបទៅនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ពោលគឺមានសមត្ថភាពពេញលេញក្នុងការរៀន និងបង្រៀនដោយប្រើវិធីសាស្ត្របង្រៀនស្របតាមបរិបទបច្ចុប្បន្ន និងនាពេលអនាគត។ ក្របខ័ណ្ឌនេះត្រូវបានរៀបចំឡើងដោយផ្អែកលើទស្សនវិជ្ជាអប់រំ ភាពជឿជាក់ ការតម្រង់ទិស ទ្រឹស្តីនៃការរៀន និងបង្រៀន និងតម្រូវការសង្គមនាយុគសម័យឌីជីថល តាមរយៈទស្សនៈអប់រំបែបជឿនលឿន និងទស្សនវិជ្ជាអប់រំបែបស្ថាបនានិយម ដោយជឿជាក់ថា កម្មវិធីបណ្តុះបណ្តាលពហុមុខវិជ្ជានេះ នឹងផ្តោតការយកចិត្តទុកដាក់ទៅលើជំនាញទូទៅនៅក្នុងដំណាក់កាលដំបូង និងបំណិនការងារប្រតិបត្តិវិជ្ជាជីវៈនៅដំណាក់កាលបន្ត។ កម្មវិធីបណ្តុះបណ្តាលនេះក៏នឹងផ្តល់មូលដ្ឋានគ្រឹះទាំងខាងផ្នែកបញ្ញត្តិ និងទ្រឹស្តីរឹងមាំដល់អ្នកសិក្សាឱ្យមានឱកាសគ្រប់គ្រាន់ ដើម្បីយកចំណេះដឹងនិងបំណិនទាំងនោះទៅប្រើប្រាស់ក្នុងលក្ខខណ្ឌការងារជាក់ស្តែង។ ក្នុងន័យនេះ គ្រូបង្រៀនត្រូវបានរំពឹងថានឹងបណ្តុះភាពចង់ចេះ ចង់ដឹងរបស់អ្នកសិក្សា និងជំរុញឱ្យមានការគិតកម្រិតខ្ពស់ និង

ការកសាងចំណេះដឹងតាមរយៈការស្រាវជ្រាវជាក់ស្តែង ដើម្បីចូលរួមដោះស្រាយបញ្ហានានាក្នុងសង្គម និងនាំមកនូវការផ្លាស់ប្តូរប្រកបដោយភាពវិជ្ជមាន។

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាចម្បង សម្រាប់ការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយនិរន្តរភាព។ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ពិតជាមានសារៈសំខាន់សម្រាប់អភិវឌ្ឍគ្រូបង្រៀនឱ្យបានគ្រប់ជ្រុងជ្រោយទាំងរាងកាយ បញ្ញាញាណ និងស្មារតី ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គម ចំណេះដឹង ប្រកបដោយនិរន្តរភាព ភាពសុខដុមរមនា និងសន្តិភាព។

## ង. ការបញ្ចូលវិធីសាស្ត្របង្រៀនសាលាជំនាន់ថ្មីក្នុងកម្មវិធីបណ្តុះបណ្តាលគ្រប់កម្រិត

ក្រោយការដាក់ឱ្យអនុវត្តសាកល្បងនូវកម្មវិធីសាលាជំនាន់ថ្មីចាប់ពីឆ្នាំ២០១៦ និងបានជំរុញឱ្យសិស្សានុសិស្សទទួលបានគុណសម្បទាសតវត្សរ៍ទី២១ប្រកបដោយជោគជ័យ ក្រសួងបានជំរុញការអនុវត្ត និងបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនសាលាជំនាន់ថ្មីនេះឱ្យកាន់តែស៊ីជម្រៅ ក្នុងកម្មវិធីបណ្តុះ-បណ្តាលគ្រូបង្រៀនគ្រប់កម្រិត នៅតាមសាលាគរុកោសល្យនានា។ វិធីសាស្ត្របង្រៀនសាលាជំនាន់ថ្មីនេះ គឺការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមទ្រឹស្តីស្ថាបនានិយម (constructivism learning theory) ពោលគឺការសិក្សាបែបសកម្ម ដែលសិស្សស្វែងរកពុទ្ធិដោយផ្ទាល់ តាមរយៈការស្រាវជ្រាវ ដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ដោយប្រើវិធីសាស្ត្របង្រៀនតាមបែបរិះរក (Inquiry-based learning) ការអនុវត្តគម្រោង (Project-Based Learning) ជាដើម និងឈានទៅកាន់ពុទ្ធិកម្រិតខ្ពស់បំផុតតាមប្លូមតាក់សូណូមី (Bloom's taxonomy) ក៏ដូចជាមានបំណិនសតវត្សរ៍ទី២១ ដូចជាការត្រិះរិះពិចារណា ដោះស្រាយបញ្ហា សហការធ្វើការងារជាក្រុម និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការរៀន និងបង្រៀនជាដើម។

## ច. ការបញ្ចូលតេស្តវង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិក្នុងកម្មវិធីសិក្សា

រាល់កម្មវិធីសិក្សាតែងមានការសិក្សាពីកម្មវិធីសិក្សា ដែលក្នុងនោះអ្នកសិក្សានឹងបានសិក្សាពីកម្មវិធីសិក្សាដែលកំពុងអនុវត្តក្នុងកម្រិតសិក្សាដែលគរុសិស្ស-និស្សិតត្រូវទៅបំពេញការងារ វិធីសាស្ត្របង្រៀន វិធីសាស្ត្រវង្វាយតម្លៃទាំងតាមដំណាក់កាល និងបែបសរុប។ យ៉ាងណាមិញ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀន ក្រសួងក៏បានបញ្ចូលការអនុវត្តតេស្តវង្វាយតម្លៃថ្នាក់ជាតិសម្រាប់គ្រប់ភូមិសិក្សា វង្វាយកម្រិតតំបន់សម្រាប់កម្រិតបឋមសិក្សា (Southeast Asia Primary Learning Metrics ហៅកាត់ថា SEA-PLM) និងវង្វាយកម្រិតអន្តរជាតិនៅកម្រិតអនុវិទ្យាល័យ (Programme for International

Student Assessment ហៅកាត់ថា PISA ) ទៅក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀននៅតាមសាលាគរុកោសល្យផងដែរ។ រង្វាយតម្លៃកម្រិតតំបន់ និងអន្តរជាតិនេះជារង្វាយតម្លៃតាមបែបការផ្សារភ្ជាប់អ្វីដែលរៀននៅក្នុងថ្នាក់ទៅនឹងជីវភាពប្រចាំថ្ងៃ ដែលទាមទារឱ្យសិស្សមានបំណិនក្នុងការប្រើប្រាស់ពុទ្ធិដែលមានក្នុងការដោះស្រាយបញ្ហា។



## ២.៣.២. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងកម្មវិធីវិក្រឹតការ

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា និងមន្ត្រីគ្រប់គ្រងត្រូវបានរៀបចំឱ្យមានជាលក្ខណៈប្រព័ន្ធ និងបើកទូលាយទៅកាន់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ អង្គភាពក្រោមឱវាទក្រសួង និងដៃគូអភិវឌ្ឍនានាក្នុងការស្នើសុំការទទួលស្គាល់គុណភាព តាមយន្តការដូចខាងក្រោម៖




តារាង៨៖ យន្តការក្នុងការទទួលបាននូវការទទួលស្គាល់គុណភាពវិក្រឹតការគ្រូ

គិតត្រឹមចុងខែមិថុនា ឆ្នាំ២០២៤ នេះ ក្រសួងបានផ្តល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពជាអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD Providers) ដល់គ្រឹះស្ថានអប់រំចំនួន ៤ ដែលមានសុពលភាពចំនួន ៣ ឆ្នាំ ក្នុងនោះមានវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ វិទ្យាស្ថានគរុកោសល្យបាត់ដំបង និងវិទ្យាល័យព្រះស៊ីសុវត្ថិជំនាន់ថ្មី ព្រមទាំងផ្តល់វិញ្ញាបនបត្រទទួលស្គាល់គុណភាពការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD Offering) បណ្តោះអាសន្នសម្រាប់រយៈពេល ៣ ឆ្នាំ និងពេញសិទ្ធិរយៈពេល ៥ ឆ្នាំ សម្រាប់សកម្មភាពបណ្តុះបណ្តាល ចំនួន៤៣ ដល់

អង្គភាពក្រោមឱវាទក្រសួង ដៃគូអភិវឌ្ឍ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូសរុបចំនួន១០។

ក្រៅពីនេះ កម្មវិធីបណ្តុះបណ្តាលបន្តផ្សេងទៀតក៏ត្រូវបានរៀបចំឡើងនៅតាមគ្រឹះស្ថាននានាក៏ដូចជានៅតាមនាយកដ្ឋានជំនាញនានាផងដែរ ដែលក្រសួងបាននឹងកំពុងជំរុញក្នុងការស្នើសុំការទទួលស្គាល់គុណភាពជាបន្តបន្ទាប់។

### ២.៣.៣. ការអភិវឌ្ឍឯកសាររៀន និងបង្រៀន

ការអភិវឌ្ឍឯកសាររៀន និងបង្រៀនគឺជាផ្នែកគាំទ្រមួយសំខាន់ក្នុងការបណ្តុះបណ្តាលគរុសិស្សគរុនិស្សិតឱ្យទទួលបានគុណសម្បទាដែលមានចែងក្នុងក្របខ័ណ្ឌកម្មវិធីសិក្សា។ ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ ក្រសួងបានលើកទឹកចិត្ត និងជំរុញឱ្យនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងសាលាគរុកោសល្យទូទាំងប្រទេសចងក្រងសៀវភៅបណ្តុះបណ្តាលតាមមុខវិជ្ជា វិធីសាស្ត្របង្រៀន ការគ្រប់គ្រងបណ្ណាល័យជាដើម ដោយប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ និងតាមរយៈគម្រោងនានា ដោយអនុញ្ញាតឱ្យប្រើប្រាស់ស្នាដៃទាំងនេះជាសូចនាករសំខាន់មួយក្នុងការវាយតម្លៃ ការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

ជាលទ្ធផល នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យទាំង២ បានចូលរួមអភិវឌ្ឍជាបន្តបន្ទាប់នូវសៀវភៅសិក្សានានាសៀវភៅពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្រ សៀវភៅគ្រប់គ្រងបន្ទប់ពិសោធន៍ សៀវភៅប្រើប្រាស់ឧបករណ៍ពិសោធន៍ សៀវភៅណែនាំស្តីពីការអប់រំស្នេម សៀវភៅណែនាំប្រតិបត្តិសម្រាប់បណ្ណារក្សសាលាមធ្យមសិក្សា និងសៀវភៅជំនួយក្នុងការគ្រប់គ្រងសាលារៀនសម្រាប់នាយកសាលាជាដើម។

ក្នុងពេលជាមួយគ្នា វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យទាំងពីរក៏បានរៀបចំបណ្តុះ-បណ្តាលជាប្រចាំដល់គ្រូឧទ្ទេសស្តីពីវិធីសាស្ត្រស្រាវជ្រាវក្នុងវិស័យអប់រំ និងបានរៀបចំជាផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការស្រាវជ្រាវផងដែរ។


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION , YOUTH AND SPORT
សៀវភៅ
គ្រប់គ្រងបន្ទប់ពិសោធន៍
និងប្រើប្រាស់សម្ភារពិសោធន៍
រូបវិទ្យា
សម្រាប់ការរៀន និងបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ
កក្កដា ២០២៣


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION , YOUTH AND SPORT
សៀវភៅ
គ្រប់គ្រងបន្ទប់ពិសោធន៍
និងប្រើប្រាស់សម្ភារពិសោធន៍
ផែនដីវិទ្យា
សម្រាប់ការរៀន និងបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ
កក្កដា ២០២៣


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION , YOUTH AND SPORT
សៀវភៅ
គ្រប់គ្រងបន្ទប់ពិសោធន៍
និងប្រើប្រាស់សម្ភារពិសោធន៍
ជីវវិទ្យា
សម្រាប់ការរៀន និងបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ
កក្កដា ២០២៣


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION , YOUTH AND SPORT
H2O
សៀវភៅ
គ្រប់គ្រងបន្ទប់ពិសោធន៍
និងប្រើប្រាស់សម្ភារពិសោធន៍
គីមីវិទ្យា
សម្រាប់ការរៀន និងបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ
កក្កដា ២០២៣

## ២.៤. ការអភិវឌ្ឍគុណវុឌ្ឍិគ្រូឧទ្ទេស គណៈគ្រប់គ្រង និងបុគ្គលិក

ការលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសឱ្យមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ និងមានស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ជាផ្នែកមួយសំខាន់ដែលក្រសួងតែងយកចិត្តទុកដាក់។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានបង្កើតយន្តការក្នុងការប្រឡងជ្រើសរើសគ្រូឧទ្ទេសដែលមានបំណងចូលមកបម្រើការងារនៅតាមសាលាគរុកោសល្យ ដោយជ្រើសរើសគុណវុឌ្ឍិចាប់ពីសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ដោយឆ្លងកាត់ការធ្វើតេស្តសមត្ថភាពលើជំនាញឯកទេស ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងវិធីសាស្រ្តបង្រៀន។ ទន្ទឹមនឹងនេះ ក្រសួងបានផ្តល់អាទិភាព និងអាហារូបករណ៍ដល់គ្រូឧទ្ទេសក្នុងការបន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតទាំងក្នុង និងក្រៅប្រទេស។ ឆ្លើយតបនឹងអាទិភាពរបស់ក្រសួងក្នុងការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព ក្រសួងក៏បានកំណត់អាទិភាពក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ ទាំងតាមរយៈអាហារូបករណ៍នានា ក៏ដូចជាការប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងថវិកាគម្រោង ក្នុងនោះមានជាអាទិ៍ ការបញ្ជូនគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំចំនួន ៩ រូប ទៅសិក្សានៅប្រទេសជប៉ុន ថៃ ហ្វីលីពីនដោយក្នុងនោះ ទៅបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន៧ រូប និងបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងបណ្ណាល័យចំនួន ២រូប។ ក្នុងពេលជាមួយគ្នា ក្រសួងបានផ្តល់ឱកាសដល់គ្រូឧទ្ទេសបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិអប់រំ និងសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីបណ្តុះបណ្តាលគ្រូឧទ្ទេសនៅប្រទេសអូស្ត្រាលី កូរ៉េខាងត្បូង និងជប៉ុន ជាដើម។

ក្នុងឆ្នាំ២០១៩ ២០២០ និងឆ្នាំ២០២៣ ក្រសួងបានប្រើថវិការដ្ឋក្នុងការបញ្ជូនគ្រូឧទ្ទេស និងបុគ្គលិកអប់រំ សរុបចំនួន១១៣ នាក់ ទៅសិក្សារយៈពេល ២ ខែ នៅវិទ្យាស្ថានជាតិអប់រំសិង្ហបុរីលើជំនាញ ១)ដឹកនាំនិងគ្រប់គ្រងសាលារៀន ២)សៀវភៅសិក្សា និងកម្មវិធីសិក្សា ៣)វិធីសាស្រ្តបង្រៀនស្ទែម ៤)វិធីសាស្រ្តបង្រៀនតាមបែបរិះរកផ្នែកវិទ្យាសាស្រ្ត ៥)វិធីសាស្រ្តបង្រៀនតាមបែបរិះរកផ្នែកវិទ្យាសាស្រ្តសង្គម ៦)ការអភិវឌ្ឍកម្មវិធីសិក្សាតាមបែបបញ្ញត្តិ ជាដើម។ ចាប់ពីឆ្នាំ ២០១៩ ដល់ ២០២១ ក្រសួងបានសហការជាមួយអង្គការយូណេស្កូ (UNESCO) ក្រោមកម្មវិធី STEPCam ដំណាក់កាលទី១ ក្នុងការរៀបចំកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យ និងវិក្រឹតការខេត្តនានា សរុបចំនួន ៦៧ នាក់ ឱ្យបន្តការសិក្សាដល់កម្រិតបរិញ្ញាបត្រអប់រំ ដោយជោគជ័យ។ ទន្ទឹមនឹងនេះ ក្រសួងក៏បានប្រើប្រាស់ថវិកាគម្រោង USEDP1 ក្នុងការសហការជាមួយគ្រូជំនាញផ្នែកវិទ្យាសាស្ត្រនៃវិទ្យាស្ថានជាតិអប់រំសិង្ហបុរី ក្នុងការពិនិត្យវិភាគកម្មវិធីសិក្សាថ្មីផ្នែកមុខវិជ្ជាវិទ្យាសាស្រ្ត វិភាគស្ថានភាពវិទ្យាស្ថានជាតិអប់រំ និងបណ្តុះបណ្តាលវិធីសាស្រ្តបង្រៀនគណិតវិទ្យា និងស្ទែមទៅកាន់គ្រូឧទ្ទេស

និងគ្រូបង្រៀននៅតាមសាលាធនធានផងដែរ។ ម៉្យាងទៀត តាមរយៈមូលនិធិថេម៉ាសេកនៃប្រទេសសិង្ហបុរី ក្រសួងក៏បានបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀនសតវត្សរ៍ទី២១ ដល់នាយកសាលា បុគ្គលិកអប់រំ និងគ្រូឧទ្ទេសសរុបចំនួន ១២១ នាក់ ដែលការបណ្តុះបណ្តាលតាមវគ្គខ្លីៗនេះប្រើពេល ២ ឆ្នាំ បន្តបន្ទាប់គ្នា ដើម្បីឱ្យអ្នកសិក្សាបានសិក្សាពីទ្រឹស្តី បទពិសោធ និងយកទៅអនុវត្តផ្ទាល់មុនបន្តការសិក្សាទៅវគ្គបន្តបន្ទាប់ទៀត។

តាមរយៈការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន គោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងអនុម័តគោលការណ៍ផ្តល់ឋានៈជាគ្រូឧទ្ទេស និងគ្រូឧទ្ទេសរងនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ក៏ដូចជាការឈានទៅការប្រើប្រាស់ឋានៈសាស្ត្រាចារ្យតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូដូចជា វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង គុណវុឌ្ឍិគ្រូឧទ្ទេសមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ក្នុងនោះគ្រូឧទ្ទេសដែលមានសញ្ញាបត្របណ្ឌិតមានការកើនឡើងពី ៨ នាក់ មកចំនួន ៣០ នាក់ រីឯកម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានកើនឡើងជិត ៣ ដង ពី២២៧ នាក់ មក ៦៧៥នាក់ ស្របពេលដែលចំនួនគ្រូឧទ្ទេសដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬក្រោមបរិញ្ញាបត្រមានការថយចុះគួរឱ្យកត់សម្គាល់ ដូចក្នុងតារាងខាងក្រោម៖




ប្រភព៖ HRMIS ២០១៥ និងអគ្គ.បវ ២០២៤

តារាងប្រៀបធៀបស្តីពីគុណវុឌ្ឍិគ្រូឧទ្ទេសឆ្នាំ២០១៥ និង២០២៤

រីឯការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនវិញ ក្នុងការអនុវត្តគម្រោងកែលម្អការអប់រំមធ្យមសិក្សា (SEIP) និងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ក្រសួងបានរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូ (TUP) និងគណៈគ្រប់គ្រងសាលារៀន (LUP) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផង និងចូលរួមអនុវត្តកំណែទម្រង់សាលារៀនផង។ ក្នុងទិសដៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឱ្យមានសញ្ញាបត្របរិញ្ញាបត្រ ពិសេសដើម្បីដោះស្រាយបញ្ហាកង្វះគ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្រសួងក៏បានអនុវត្តកម្មវិធីពន្លឿនសម្រាប់វិក្រឹតការគ្រូកម្រិតមធ្យមសិក្សាបឋមភូមិឱ្យក្លាយជាគ្រូមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ ចំនួន ៣ជំនាន់ សរុបចំនួន ២ ៦៨៩នាក់។

តាមរយៈការខិតខំប្រឹងប្រែងនេះ ចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិចាប់ពីបរិញ្ញាបត្រឡើងមានការកើនឡើងពី ១៧ ៩៤៤នាក់ នៃចំនួនគ្រូបង្រៀនសរុប ៩៦ ២៩៨នាក់ ស្មើនឹង ១៨ ភាគរយ នៃចំនួនគ្រូបង្រៀនសរុបនៅឆ្នាំ២០១៥ មកជា ៣៨ ១៩៩ នាក់ នៃចំនួនគ្រូបង្រៀនសរុប ៩៨ ៩៦១ នាក់ ស្មើនឹង ៣៨,៦៣ ភាគរយ នៅឆ្នាំ២០២៤។




ប្រភព៖ HRMIS ២០២៤

តារាងប្រៀបធៀបស្ដីពីគុណវុឌ្ឍិគ្រូបង្រៀនឆ្នាំ២០១៥ និង២០២៤

## ២.៥. ការជ្រើសរើសគរុសិស្សប្រកបដោយសក្ដានុពល និងការលើកកម្ពស់ការរស់នៅរបស់គ្រូឧទ្ទេស

ក្នុងគោលបំណងជ្រើសរើសគរុសិស្ស-គរុនិស្សិតប្រកបដោយសក្ដានុពល ពោលគឺទាក់ទាញសិស្សរៀនពូកែឱ្យចូលធ្វើគ្រូបង្រៀន ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅរបស់គ្រូឧទ្ទេស និងបុគ្គលិកអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានដំឡើងប្រាក់បៀវត្សរ៍ជូនគ្រូបង្រៀនជាប្រចាំ។ ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤ ១)ប្រាក់បៀវត្សរ៍អប្បបរិមារបស់បុគ្គលិកអប់រំក្របខ័ណ្ឌ គ ពោលគឺគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាកើនឡើងជាង ៣ ដង ពី ៣១០ ៨០០ រៀល ដល់ ១ ៤៥០ ៩៥០ រៀល ២)បុគ្គលិកអប់រំក្របខ័ណ្ឌ ខ ពោលគឺគ្រូកម្រិតមូលដ្ឋាន កើនឡើងជាង ២ ដង ពី ៤៣៨ ០១០ រៀល ដល់ ១ ៥៥៩ ០០០ រៀល និង ៣) បុគ្គលិកអប់រំក្របខណ្ឌ ក ពោលគឺគ្រូកម្រិតឧត្តម កើនឡើងជិត ២ ដង ពី ៦២៩ ១៨០ រៀល ដល់ ១ ៧៦៧ ៣៥០ រៀល។ ទន្ទឹមនឹងនេះ បៀវត្សរ៍អតិបរមាក៏មានការកើនឡើងគួរឱ្យកត់សម្គាល់។




ប្រភព៖ នាយកដ្ឋានបុគ្គលិក ២០២៤

កំណើនបៀវត្សរ៍គ្រូបង្រៀនអប្បបរមាពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានបុគ្គលិក ២០២៤

កំណើនបៀវត្សរ៍គ្រូបង្រៀនអតិបរមាពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤

ចាប់ពីឆ្នាំ២០២៣ គរុសិស្ស-និស្សិត ក៏បានទទួលប្រាក់ឧបត្ថម្ភចំនួន ៧០ ភាគរយនៃប្រាក់បៀវត្សរ៍សរុបចាប់តាំងពីថ្ងៃចាប់ផ្ដើមនៃការចូលរៀននៅតាមសាលាគរុកោសល្យនានាផងដែរ។ ក្នុងន័យនេះ គរុសិស្ស-និស្សិតក្របខ័ណ្ឌ គ ទទួលបានប្រាក់ឧបត្ថម្ភចំនួន ១ ០២៩ ០០០ រៀល ក្របខ័ណ្ឌ ខ ទទួលបានប្រាក់ឧបត្ថម្ភចំនួន ១ ០៤៨ ២៥០ រៀល និងក្របខ័ណ្ឌ ក ទទួលបានប្រាក់ឧបត្ថម្ភចំនួន ១ ១៣២ ០០០ រៀល ក្នុង១ខែ។

ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានផ្ដល់ការលើកទឹកចិត្តជាច្រើនទៀតដូចជាការផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំខ្មែរ លំហែមាតុភាព ប្រាក់សោធននិវត្តន៍ ពិការភាព មរណភាព ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់បុគ្គលិកអប់រំដែលបំពេញការងារនៅតំបន់ជួបការលំបាក ក៏ដូចជាច្បាប់បន្តការសិក្សាដោយរក្សាប្រាក់បៀវត្សរ៍ បេឡាសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងសម្រាប់កូនមន្ត្រីរាជការ ព្រមទាំងជាការលើកទឹកចិត្តផ្សេងៗទៀតដូចជាការទទួលស្គាល់គ្រូល្អ នាយកល្អ សាលាស្អាត សាលាស្តង់ដាគំរូ ជាដើម។

សម្រាប់គរុនិស្សិតផ្នែកអប់រំកាយ និងកីឡា បឋមសិក្សា និងអនុវិទ្យាល័យដែលប្រឡងចូលក្របខ័ណ្ឌក្នុងឆ្នាំ២០២៤ សម្រាប់ផែនការជ្រើសរើសឆ្នាំ២០២៣ ដែលទទួលការបណ្ដុះបណ្ដាលតាមប្រព័ន្ធ ១២+៤ ឬបរិញ្ញាបត្រ+១ នឹងទទួលបានក្របខ័ណ្ឌ ក។ ការលើកទឹកចិត្តដោយផ្ដោតលើគុណវុឌ្ឍិ

នេះគឺជានវានុវត្តន៍ថ្មីមួយ ព្រោះកន្លងមក ប្រភេទក្របខ័ណ្ឌត្រូវបានផ្តល់ទៅដល់គ្រូបង្រៀនតាមកម្រិតសិក្សាដែលខ្លួនទទួលបន្ទុក ពោលគឺគ្រូបឋមសិក្សាមានក្របខ័ណ្ឌ គ គ្រូអនុវិទ្យាល័យ ឬគ្រូមូលដ្ឋានមានក្របខ័ណ្ឌ ខ និង គ្រូកម្រិតឧត្តម ឬគ្រូកម្រិតវិទ្យាល័យទទួលបានក្របខ័ណ្ឌ ក។

## ២.៦. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

### ២.៦.១. វិទ្យាស្ថានគរុកោសល្យបាត់ដំបង និងរាជធានីភ្នំពេញ

ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ គម្រោងបង្កើតវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង (E-TECs) បានប្រើប្រាស់ថវិកា៣០ លានដុល្លារសហរដ្ឋអាមេរិក គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានផ្តោតសំខាន់លើការពង្រឹងសមត្ថភាពគ្រូបង្រៀនថ្មីនៅកម្ពុជា និងការសាងសង់ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនៃវិទ្យាស្ថានទាំងពីរ ឱ្យក្លាយជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូកម្រិតបរិញ្ញាបត្រវិជ្ជាជីវៈ ១២+៤។

ការសាងសង់នៅវិទ្យាស្ថានគរុកោល្យបាត់ដំបងរួមមាន អគាររដ្ឋបាល ១ខ្នង ៣ជាន់ ស្មើ ២៩បន្ទប់ ដោយមានបំពាក់សម្ភារៈការិយាល័យដូចជា តុ ទូ កៅអី ម៉ាស៊ីនត្រជាក់ និងកុំព្យូទ័រ, អគារសិក្សា ១ខ្នង ៣ជាន់ ស្មើ ២៩បន្ទប់ ក្នុងនោះមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់សិល្បៈ បន្ទប់តន្ត្រី និងបន្ទប់គេហកិច្ច, អគារបណ្ណាល័យមាន ៣ជាន់ រួមមានបណ្ណាល័យ បន្ទប់ស្វ័យសិក្សា សាលសហសិក្សា ២បន្ទប់ និងបន្ទប់កុំព្យូទ័រ ៤បន្ទប់, អគារពហុមុខងារ ១ជាន់ ដែលអាចប្រើជាសាលប្រជុំកីឡា និងសិល្បៈ, អគារអន្តេវាសិកដ្ឋាន ១ខ្នង ៤ជាន់ ស្មើ ២២បន្ទប់ ក្នុងនោះបន្ទប់គេង ១៧ ក្នុង ១បន្ទប់មានគ្រែពីរជាន់ ៨ និងតុវែង ១ និងកៅអី ៨, ចំណែក ៥បន្ទប់ទៀតរួមមាន បន្ទប់ផ្ទះបាយ ១ បន្ទប់បោកគក់ ១ បន្ទប់ផ្ទុតទឹក ១ បន្ទប់បង្គន់អនាម័យ ១ និងបន្ទប់ស្នាក់នៅរបស់គ្រូ ១។ ក្រៅពីនេះក៏មានការបំពាក់កុំព្យូទ័រ ៣២គ្រឿង ក្នុង ១បន្ទប់, ការបំពាក់សម្ភារៈ និងឧបករណ៍នៅតាមបន្ទប់ពិសោធន៍ បន្ទប់សិល្បៈ តន្ត្រី និងបន្ទប់គេហកិច្ច និងការផ្តល់សៀវភៅអានសម្រាប់បណ្ណាល័យផងដែរ។

រីឯនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញក៏មានការសាងសង់អគាររដ្ឋបាល ១ខ្នង ៣ជាន់ ស្មើ ១៦ បន្ទប់ ដោយមានបំពាក់សម្ភារៈការិយាល័យដូចជា តុ ទូ កៅអី ម៉ាស៊ីនត្រជាក់ និងកុំព្យូទ័រ, ការសាងសង់អគារសិក្សា ១ខ្នង ២ជាន់ ស្មើ ៧បន្ទប់ ក្នុងនោះមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់សិល្បៈ និងបន្ទប់គេហកិច្ច, ការសាងសង់អគារបណ្ណាល័យមាន ២ ជាន់ រួមមានសាលសៀវភៅ សាលអាន និងបន្ទប់ កុំព្យូទ័រចំនួន ៤, ការសាងសង់អគារពហុមុខងារ ១ជាន់ផ្ទាល់ដី ដែលអាច

ប្រើប្រាស់បានជាសាលប្រជុំ កីឡា និងសិល្បៈ ការបំពាក់កុំព្យូទ័រ ៣២គ្រឿង ក្នុង ១បន្ទប់, ការបំពាក់សម្ភារៈ និងឧបករណ៍នៅតាមបន្ទប់ពិសោធន៍ បន្ទប់សិល្បៈ តន្ត្រី និងបន្ទប់គេហកិច្ច និង ការផ្តល់សៀវភៅអានសម្រាប់បណ្ណាល័យ ព្រមទាំងមាន បំពាក់អ៊ីនធឺណែតល្បឿនលឿន (១៥០Mb) គ្រប់អគារសិក្សា សម្រាប់ឱ្យបុគ្គលិកអប់រំ និងគរុនិស្សិតប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវផងដែរ។ លើសពីនេះ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបានទទួលសំណង់អគារអន្តេវាសិកដ្ឋានគ្រូ០១ខ្នង កម្ពស់០៤ជាន់ ចែកចេញជា ៧០បន្ទប់ស្នាក់នៅ ដែលជាជំនួយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបានសាងសង់រួចរាល់ដោយកងវិស្វកម្មសម្តេចតេជោ ហ៊ុន សែន ដែលត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ដោយ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤។

ក្នុងពេលជាមួយគ្នា ក្រសួងក៏បានជួសជុលកែលម្អអគារសិក្សា ១៣ ខ្នង មាន ៩៨ បន្ទប់ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង គាំទ្រដោយថវិការាជរដ្ឋាភិបាលផងដែរ។

ក្រៅពីនេះ វិទ្យាស្ថានគរុកោសល្យទាំង២ ក៏ទទួលបាននូវការកែលម្អហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើនទៀត ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាលកម្ពុជា រួមមានៈ ការជួសជុលអគារសិក្សា មានស្រាប់ ក្លោងទ្វារ របងច្រកចូល សួនច្បារ ទីលានកីឡាបាល់ទាត់ បាល់ទះ ផ្លូវបេតុង និងការស្តារស្រះស្តុកទឹក។ល។ ព្រមទាំងទទួលការគាំទ្រពី សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបំពាក់គ្រែពូក ក្នុងអន្តេវាសិកដ្ឋាន និងការកសាងបណ្តាញលូទឹក ក្នុងឆ្នាំ២០២៤ ផងដែរ។





អគាររដ្ឋបាល និងអន្តេវាសិកដ្ឋាននៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ












វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ














វិទ្យាស្ថានគរុកោសល្យបាត់ដំបង

## ២.៦.២. វិទ្យាស្ថានជាតិអប់រំ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិទ្យាស្ថានជាតិអប់រំបានប្រែមុខមាត់ថ្មី ដោយមានអគារសរុបចំនួន ១៨ ក្នុងនោះមានអគារសាងសង់ថ្មីចំនួន២ រួមមានអគារសិក្សា«មហាវិទ្យាល័យគរុកោសល្យ» កម្ពស់៦ ជាន់ ស្មើ ៥៤បន្ទប់ ដែលជាការសាងសង់ដោយប្រើប្រាស់ថវិកាពជរដ្ឋាភិបាល, និងអគារ «បណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត» កម្ពស់ ៦ជាន់ ស្មើនឹង ៣៧បន្ទប់ អគារចាស់ជួសជុលកែលម្អចំនួន១៤ ដែលប្រើប្រាស់ថវិកាគម្រោងUSESDP2 , អគារNGPRC ថ្មី កែលម្អដោយអង្គការ KAPE និងវិទ្យាល័យអនុវត្តន៍ ។ បន្ទប់សិក្សាបានរៀបចំឱ្យក្លាយជាបន្ទប់ដែលមានផាសុកភាព និងរៀបចំស្របតាមការអប់រំសតវត្សរ៍ទី២១ រីឯសាលសហសិក្សា បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ បន្ទប់សាស្ត្រាចារ្យ ការិយាល័យធ្វើការ និងសាលប្រជុំ ក៏ទទួលបានការកែលម្អ និងបំពាក់សម្ភារបរិក្ខារទំនើប។ ក្រៅពីនេះ ទីកន្លែងទំនេរក៏ត្រូវបានរៀបចំឱ្យមានបរិស្ថានបៃតងសមស្របក្នុងការលំហែ ឬប្រើប្រាស់ជាកន្លែងបំពេញការងារពិភាក្សាក្រុមរបស់គរុនិស្សិត និងបុគ្គលិក ព្រមទាំងមានទីកន្លែងហាត់កីឡា ចំណតយានយន្ត អាហារដ្ឋាន និងបន្ទប់ទឹកដែលមានអនាម័យផងដែរ។




ប្លង់មេនៃវិទ្យាស្ថានជាតិអប់រំ











វិទ្យាស្ថានជាតិអប់រំ

## ២.៦.៣. សាលាគរុកោសល្យ និងវិក្រឹតការខេត្ត

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលាគរុកោសល្យ ក៏ជាផ្នែកមួយសំខាន់ដែលក្រសួងបាន និងកំពុងយកចិត្តទុកដាក់។ ក្នុងការអនុវត្តមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំទី៣ (GPE3) ដែលមានថវិកា ២០,៦ លានដុល្លារអាមេរិក ក្រសួងបានផ្តោតលើការអភិវឌ្ឍសមត្ថភាព និងកម្មវិធីអប់រំគ្រូបង្រៀន មានរយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។ គម្រោងនេះ ក៏ផ្តោតផងដែរលើការពង្រឹងការគ្រប់គ្រងតាមសាលារៀន (SBM) ការអនុវត្តអំណានថ្នាក់ដំបូង (EGRA) និងគណិតវិទ្យាថ្នាក់ដំបូង (EGMA) និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន ១១ ក្នុងនោះមានខេត្តកំពត កំពង់ស្ពឺ កំពង់ធំ ពោធិ៍សាត់ បន្ទាយមានជ័យ ក្រចេះ កំពង់ឆ្នាំង ស្វាយរៀង ព្រះវិហារ ព្រះសីហនុ និងស្ទឹងត្រែង ដោយមានអគារ ៦៣ខ្នង ៣៤៨បន្ទប់ បង្គន់អនាម័យ ១៤ខ្នង ៣១៤បន្ទប់ ដោយបំពាក់គ្រឿងសង្ហារិមតាមការិយាល័យ អន្តេវាសិកដ្ឋាន និងសម្ភារឧបករណ៍ពិសោធន៍។

ក្រោមកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ (UNESCO) ហេដ្ឋារចនាសម្ព័ន្ធសាលាសាលាគរុកោសល្យ និងវិក្រឹតការខេត្តចំនួន ១១ បានធ្វើការកែលម្អ ព្រមទាំងមានបំពាក់សម្ភារៈបរិក្ខារផ្សេងៗ រួមមានប្រព័ន្ធអ៊ីនធឺណែត បណ្ណាល័យ បន្ទប់កុំព្យូទ័រ និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រដែលផ្តល់អត្ថប្រយោជន៍ដល់គ្រូឧទ្ទេសជាង ២៤០ នាក់ និងគ្រូបង្រៀនបឋមសិក្សាជិត១ ៣០០ នាក់ជារៀងរាល់ឆ្នាំ។ កិច្ចការនេះត្រូវបានធ្វើឡើងក្នុងអំឡុងខែមិថុនា ឆ្នាំ២០២០ រហូតដល់ ខែមិថុនា ឆ្នាំ២០២១។

ក្រៅពីនេះ ក្នុងឆ្នាំ ២០២២ និង២០២៣ កន្លងមក ក្រសួងបានប្រើថវិការបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំបណ្តាញ Network បំពាក់អ៊ីនធឺណែតល្បឿនលឿន រៀបចំបន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រដែលមានបំពាក់កុំព្យូទ័រ និងប្រព័ន្ធគាំទ្រការរៀនពីចម្ងាយនៅតាមសាលាគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤ផងដែរ។

# សាលាគរុកោសល្យ និងវិក្រឹតការ ខេត្តដែលបានជួសជុលរួមមាន៖


សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពត


សាលាគរុកោសល្យ និងវិក្រឹតការខេត្តពោធិ៍សាត់


សាលាគរុកោសល្យ និងវិក្រឹតការខេត្តបន្ទាយមានជ័យ


សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ស្ពឺ


សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ធំ


សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ឆ្នាំង


សាលាគរុកោសល្យ និងវិក្រឹតការខេត្តក្រចេះ


សាលាគរុកោសល្យ និងវិក្រឹតការខេត្តព្រះវិហារ


សាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង


សាលាគរុកោសល្យ និងវិក្រឹតការខេត្តស្ទឹងត្រែង


សាលាគរុកោសល្យ និងវិក្រឹតការខេត្តព្រះសីហនុ

## ២.៦.៤. មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤

ក្នុងគោលបំណងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម តាកែវ ព្រៃវែង និងកណ្ដាលក្នុងទិសដៅត្រៀមលក្ខណៈឱ្យក្លាយជាសាលាគរុកោសល្យគំរូក្នុងពេលអនាគត និងជានាឱ្យបាននូវគុណភាពនៃការបណ្ដុះបណ្ដាលក្នុងបរិបទថ្មី ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ដោយរៀបចំប្លង់មេ កសាងអគារសិក្សា អន្តេវាសិកដ្ឋាន ជួសជុលអគារនានា បំពាក់សម្ភារៈឧបទេសសម្រាប់បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ និងថ្នាក់រៀន ព្រមទាំងរៀបចំបណ្ដាញអ៊ីនធឺណែត និងបណ្ដាញប្រព័ន្ធកុំព្យូទ័រដើម្បីសម្រួលដល់ការរៀនសិក្សា និងស្រាវជ្រាវរបស់គ្រូឧទ្ទេស និងគរុសិស្ស-គរុនិស្សិត។




ប្លង់មេមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម



ប្លង់មេមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្ដាល





បន្ទប់កុំព្យូទ័រតាមសាលាគរុកោសល្យ

ចាប់ពីឆ្នាំ២០២០មក ក្រសួងបានកែលម្អបណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ៤ ឱ្យក្លាយជាបណ្ណាល័យសតវត្សរ៍ទី២១ ក្នុងនោះមានមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម តាកែវ ព្រៃវែង និងកណ្ដាល ដោយប្រើថវិការបស់រាជរដ្ឋាភិបាល សរុបចំនួន ៧៩១ ១២០ ០០០រៀល។ បណ្ណាល័យនីមួយៗត្រូវបានរចនាដោយផ្អែកលើប្រធានបទខុសៗគ្នា។

បណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាមមានផ្ទៃក្រឡាសរុបចំនួន២៤៣ម៉ែត្រការ៉េ ដែលអាចផ្ទុកអ្នកអានបានប្រមាណ៧០នាក់នៅផ្នែកខាងក្នុង និងប្រមាណ៣០នាក់នៅផ្នែកខាងក្រៅ សរុបប្រមាណ១០០នាក់ និងអាចផ្ទុកសៀវភៅចំនួនប្រមាណ២០ ០០០ក្បាល ដែលជាចំនួនមួយឆ្លើយតបនឹងចំនួនគ្រូឧទ្ទេស និងគរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។ បណ្ណាល័យនេះត្រូវបានរៀបចំឡើងដោយផ្អែកលើប្រធានបទ «ប្រាសាទកណ្ដាលព្រៃ» ដែលសំដៅលើឃ្លាំងកំណប់នៃចំណេះវិជ្ជាដែលទោះជាស្ថិតនៅទីណាក៏ជាសម្បត្តិដ៏មានតម្លៃក្នុងការលើកកម្ពស់សតិបញ្ញា និងអត្តសញ្ញាណមិនអាចកាត់ថ្លៃបានរបស់មនុស្សម្នាក់ៗ ប្រៀបបានទៅនឹងប្រាសាទបុរាណខ្មែរដែលជាបេតិកភណ្ឌជាតិមិនអាចកាត់ថ្លៃបាន និងជាមោទនភាពសម្រាប់ប្រជាជនខ្មែរគ្រប់ជំនាន់។ ឆ្លើយតបនឹងប្រធានបទនេះ បណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាមត្រូវបានរៀបចំឡើងនៅអគារដែលស្ថិតក្នុងបរិស្ថានដែលមានដើមឈើព័ទ្ធជុំវិញ ដោយរៀបចំឱ្យមានកន្លែងអាននៅបរិវេណខាងក្រៅនិងរចនាឡើងដោយប្រើប្រាស់ពណ៌ធម្មជាតិ មានតាំងលម្អនូវរូបប្រាសាទនានា។

បណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវមានផ្ទៃក្រឡាសរុបចំនួន១៦៨ម៉ែត្រការ៉េ ដែលអាចផ្ទុកអ្នកអានបានប្រមាណ៧០នាក់ និងអាចផ្ទុកសៀវភៅចំនួនប្រមាណ១០ ០០០ក្បាល ដែលជាចំនួនមួយឆ្លើយតបនឹងចំនួនគ្រូឧទ្ទេស និងគរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។ ត្រូវបានរចនាឡើងដោយផ្អែកលើប្រធានបទ «អានក្រោមម្លប់ឈើធំ»។ ដើមឈើធំដែលអាចផ្ដល់ម្លប់ទាមទារពេលវេលាយូរក្នុងការដាំដុះ និងធំធាត់ ហើយទាមទារនូវឫសរឹងមាំ មែកធាងសាខា ស្លឹកឈើខៀវខ្ចី ដែលបង្ហាញពីអន្តរទំនាក់ទំនង និងការចូលរួមបំពេញតួនាទីជាប្រព័ន្ធដ៏ស៊ីសង្វាក់គ្នារបស់ផ្នែកនីមួយៗនៃដើមឈើ ពោលគឺប្រៀបបាននឹងការអានដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃការសិក្សាដែលមនុស្សម្នាក់ៗត្រូវអត់ធ្មត់ចំណាយពេលវេលាក្នុងការរៀនសូត្រ ហ្វឹកហាត់ខ្លួនឱ្យក្លាយជាធនធានមួយដ៏មានគុណភាព ប្រៀបបាននឹងឈើដ៏ធំដែលរឹងមាំ ហើយអាចបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងជាប្រយោជន៍សម្រាប់គ្រួសារ សិស្សានុសិស្ស និងសង្គមជាតិទាំងមូល។ ហេតុដូច្នេះ ការរចនាបណ្ណាល័យនេះគឺប្រើពណ៌បៃតងជាហាយឡាយសំខាន់ ដោយមានរូបដើមឈើធំលម្អនៅត្រង់ចំណុចកណ្ដាលនៃបណ្ណាល័យ និងមានផ្ទៃការ៉ូពណ៌ដីធម្មជាតិ។




បណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម តាកែវ ព្រៃវែង និងកណ្ដាល

បណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគហ៊ុនសែនព្រៃវែង មានផ្ទៃក្រឡាសរុបចំនួន ២១២,៤ម៉ែត្រការ៉េ ដែលអាចផ្ទុកអ្នកអានបានប្រមាណ៩០នាក់ និងអាចផ្ទុកសៀវភៅចំនួនប្រមាណ ១០ ០០០ក្បាល ដែលជាចំនួនមួយឆ្លើយតបនឹងចំនួនគ្រូឧទ្ទេស និងគរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគហ៊ុនសែនព្រៃវែង។ បណ្ណាល័យនេះត្រូវបានរចនាឡើងដោយផ្អែកលើប្រធានបទ«សតិប្រាជ្ញាគ្មានដែនកំណត់» ដោយការប្រើប្រាស់ពណ៌ខៀវជាហាយឡាយសំខាន់ ពីព្រោះពណ៌ខៀវជាពណ៌តំណាងផ្ទៃមេឃ និងមហាសមុទ្រ ជាការបង្ហាញថា បណ្ណាល័យនេះជាទីកន្លែងបើកចំហរ (open space) ទាំងសម្រាប់សេរីភាព រូបារម្មណ៍ សតិបញ្ញា ការគិត និងការសិក្សាស្រាវជ្រាវដែលគ្មានដែនកំណត់។

បណ្ណាល័យនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគហ៊ុនសែនខេត្តកណ្តាល មានផ្ទៃក្រឡាសរុបចំនួន១៨៨ម៉ែត្រការ៉េ អាចផ្ទុកអ្នកអានបានប្រមាណ៧០នាក់ និងអាចផ្ទុកសៀវភៅចំនួនប្រមាណ ៨ ០០០ក្បាល ដែលជាចំនួនមួយឆ្លើយតបនឹងចំនួនគ្រូឧទ្ទេស និងគរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគហ៊ុនសែន ខេត្តកណ្តាល។ បណ្ណាល័យនេះត្រូវបានរចនាឡើងតាមបែប «តិចនិយម ឬ Minimal» ដែលមានន័យថា តិចប៉ុន្តែពេញលេញ ដោយការប្រើប្រាស់ពណ៌ស និងពណ៌ឈើ ជាហាយឡាយសំខាន់។ ការជ្រើសរើសរចនាបថបែបនេះ គឺដោយសារបណ្ណាល័យនេះមានទំហំតូច ដូច្នេះ ដើម្បីឱ្យគ្រូឧទ្ទេស និងគរុសិស្សអាចប្រើប្រាស់បណ្ណាល័យនេះឱ្យបានពេញលេញ អស់លទ្ធភាព និងពុំមានអារម្មណ៍ចង្អៀត ក្រសួងបានជ្រើសរើសពណ៌ស និងឈើដែលបង្ហាញពីភាពសាមញ្ញ ងាយស្រួល និងទូលាយ ព្រមទាំងជ្រើសរើសយកតែសម្ភារៈដែលចាំបាច់ ដើម្បីជាប្រយោជន៍ និងប្រសិទ្ធភាពខ្ពស់បំផុតក្នុងការប្រើប្រាស់។

បណ្ណាល័យនីមួយៗដោយមានកន្លែងអានដែលឆ្លើយតបនឹងអ្នកអានដែលមានតម្រូវការខុសៗគ្នាដូចជាកន្លែងអង្គុយផ្ទាល់ដី កន្លែងអង្គុយដាច់ដោយឡែកដែលរក្សានូវភាពផ្ទាល់ខ្លួន កន្លែងអង្គុយប្រមូលផ្តុំ សាឡុង បញ្ជរកុំព្យូទ័រ កន្លែងដាក់សៀវភៅអានរួច កន្លែងដាក់សំពៀត បន្ទប់ពហុបំណង ព្រមទាំងបន្ទប់ និងកន្លែងបំពេញការងាររបស់បណ្ណារក្សផងដែរ។ ក្នុងបណ្ណាល័យទាំងមូល មានបំពាក់នូវគ្រឿងបរិក្ខារទំនើបទាន់សម័យ កន្លែងអង្គុយមានផាសុកភាព ម៉ាស៊ីនត្រជាក់ កុំព្យូទ័រក្នុងការស្រាវជ្រាវ ព្រមទាំងសៀវភៅទាំងភាសាអង់គ្លេស បារាំង និងខ្មែរ ទាំងជាសៀវភៅ និងទាំងជាឯកសារទន់ ដែលបានចុះលេខកូដតាមប្រព័ន្ធឌូវី។



បណ្ណាល័យទាំង ៤ បានដាក់សម្ពោធឱ្យប្រើប្រាស់នៅចន្លោះឆ្នាំ២០២០ និង២០២៣ ដែលនេះបង្ហាញពីឆន្ទៈក្នុងការលើកកម្ពស់ការអប់រំ ពិសេសសាលាគរុកោសល្យ ទោះបីជាកំពុងស្ថិតក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ។

## ២.៧. ការផ្សារភ្ជាប់សាលាគរុកោសល្យនឹងសាលាអនុវត្តន៍ និងសាលាសហការ

ដើម្បីលើកកម្ពស់ការអប់រំនៅតាមសាលាគរុកោសល្យ ពិសេសដើម្បីគាំទ្រការធ្វើកម្មសិក្សា និងស្រាវជ្រាវគរុកោសល្យ ក្រសួងបាន និងកំពុងអភិវឌ្ឍសាលាអនុវត្តន៍ទាំង២៤ ដោយក្នុងនោះមានវិទ្យាល័យអនុវត្តន៍ចំនួន១ អនុវិទ្យាល័យអនុវត្តន៍ចំនួន ៤ និងបឋមសិក្សាអនុវត្តន៍ចំនួន ១៩ ព្រមទាំងថ្នាក់មត្តេយ្យអនុវត្តន៍ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គុណវុឌ្ឍិគណៈគ្រប់គ្រង គ្រូឧទ្ទេស គ្រូបង្រៀន កម្មវិធីសិក្សា វិន័យ និងបទបញ្ញាផ្ទៃក្នុងឱ្យទៅជាសាលាជំនាន់ថ្មីជាបណ្តើរៗ និងជំរុញឱ្យសាលាគរុកោល្យនីមួយៗសហការគាំទ្រ និងរៀនសូត្រពីសាលាជំនាន់ថ្មី និងសាលាគំរូ ដែលស្ថិតក្នុងតំបន់ ដើម្បីបានចូលរួមគាំទ្រក្នុងកំណែទម្រង់សាលារៀនផង ជាការជំរុញលើកកម្ពស់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងគ្រូឧទ្ទេសផង និងជាការទាញយកបទពិសោធផង ដើម្បីអភិវឌ្ឍសាលាអនុវត្តន៍ សំដៅលើកកម្ពស់ការបណ្តុះបណ្តាលគ្រូ។ ទន្ទឹមនឹងនេះ សាលារៀនអនុវត្តន៍មួយចំនួនបានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសាលារៀនតាមប្រព័ន្ធឌីជីថល ដើម្បីគ្រប់គ្រងវត្តមាន ការរៀន និងបង្រៀន និងទិន្នន័យលម្អិតទាំងសិស្សានុសិស្ស បុគ្គលិកអប់រំ និងព័ត៌មានសាលារៀនជាដើម។

ជាក់ស្តែង វិទ្យាស្ថានជាតិអប់រំបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៃអនុវិទ្យាល័យអនុវត្តន៍ ដោយធ្វើការជួសជុលអគារសិក្សា ការិយាល័យបំពេញការងាររបស់លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រង បរិស្ថានសិក្សា ទីលានហាត់កីឡា កន្លែងលេងសម្រាប់សិស្សានុសិស្សកម្រិតបឋមសិក្សា បណ្ណាល័យ និងថ្នាក់រៀនជាដើម។ បណ្ណាល័យត្រូវបានពង្រីកឱ្យមានទំហំធំជាងមុនទ្វេដង ស្របនឹងវិធីសាស្ត្របង្រៀនតាមទ្រឹស្តីស្ថាបនានិយម ដែលជំរុញការសិក្សាស្រាវជ្រាវរបស់សិស្សឱ្យសិស្សមានចំណេះដឹងជាមូលដ្ឋានច្បាស់លាស់ មានគំនិតផ្តួចផ្តើម និងសហគ្រិនភាព, ចេះទំនាក់ទំនង និងសរសេរយ៉ាងប៉ិនប្រសប់, ចេះវិភាគវាយតម្លៃព័ត៌មាន, ចង់ឃើញ ចង់ដឹង និងមានការស្រមើស្រមៃ, ចេះគិតបែបវិភាគស៊ីជម្រៅ និងការដោះស្រាយបញ្ហា, ចេះសហការ, និងមានភាពរហ័សរហួន និងចេះយកចំណេះដឹងទៅអនុវត្ត។ បណ្ណាល័យនេះបំពាក់នូវទូរទស្សន៍វៃឆ្លាត ដែលជាជំនួយដល់សិស្សានុសិស្សក្នុងការសិក្សាបន្ថែម កន្លែងសម្រាប់ឱ្យសិស្សសម្រាកអានសៀវភៅធំទូលាយ មានផាសុកភាព និងមានសៀវភៅគ្រប់គ្រាន់ក្នុងការសិក្សាស្រាវជ្រាវ។ នៅតាមបន្ទប់រៀននីមួយៗមានបំពាក់នូវម៉ាស៊ីនត្រជាក់ចំនួន២គ្រឿង កង្ហារដំបូលចំនួន៤គ្រឿង អំពូលភ្លើងចំនួន១២គ្រាប់ LCD Projector ១គ្រឿង តុកៅអីតាមស្តង់ដាសាលារៀនជំនាន់ថ្មី ដែលធ្វើឱ្យដំណើរការសិក្សាអាចប្រព្រឹត្តទៅបានតាមតម្រូវការការអប់រំ ក្នុងសតវត្សរ៍ទី២១។ រីឯកន្លែងលេងកម្សាន្ត និងបរិស្ថានសិក្សាក៏សមស្របនឹងតម្រូវការ និងធានានូវសុវត្ថិភាពសម្រាប់ប្អូនៗសិស្សានុសិស្សផងដែរ។











វិទ្យាល័យអនុវត្តន៍

រីឯវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបាន និងកំពុងជំរុញលើកកម្ពស់ការផ្សារភ្ជាប់វិទ្យាស្ថាន និងសាលាអនុវត្តន៍តាមរយៈសកម្មភាពសំខាន់ៗដូចខាងក្រោម៖

• ការបង្កើតក្រុមគ្រូឧទ្ទេសបង្គោលចុះជួយសាលាបឋមសិក្សាអនុវត្តរាជធានីដើម្បីពង្រឹងគុណភាព ការអនុវត្តកញ្ចប់អំណានដំបូង ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រកម្រិតបឋម ការអប់រំសុខភាព និងអប់រំសិល្បៈ

• ការបង្កើតក្រុមគ្រូឧទ្ទេសបង្គោលចុះជួយសាលាអនុវិទ្យាល័យអូរបែកក្អមដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀនមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ផែនដីវិទ្យា ICT ភាសាអង់គ្លេស និងប្រវត្តិវិទ្យា

• ការរៀបចំសិក្ខាសាលាបំប៉នដល់គ្រូបង្រៀននៅសាលាអនុវត្តន៍ទាក់ទងនិងវិធីសាស្ត្រថ្មីៗ ការអប់រំសុខភាព និងសហការរៀបចំបន្ទប់សុខភាពក្នុងសាលាអនុវត្តន៍ទាំងពីរ

• ការលើកកម្ពស់ការចូលរួម និងអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀននៅសាលាអនុវត្តន៍ទាំងពីរ តាមរយៈការប្រជុំលើការសិក្សាស្រាវជាវមេរៀនប្រចាំសប្តាហ៍តាមដេប៉ាតឺម៉ង់របស់វិទ្យាស្ថាន

• ការបង្កើតក្រុមសិក្សាស្រាវជ្រាវមេរៀនដែលសមាជិកក្រុមរួមមានគ្រូឧទ្ទេសវិទ្យាស្ថាននិងគ្រូបង្រៀននៅសាលាអនុវត្តន៍ទាំងពីរដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀនកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិលើមុខវិជ្ជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ក្រោមកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់ JICA ក្នុងគម្រោងពង្រឹង វិទ្យាស្ថានគរុកោសល្យ (S-TEC)

• ការជំរុញការស្រាវជ្រាវប្រតិបត្តិដែលធ្វើឡើងដោយគ្រូបង្រៀននៅសាលាអនុវត្តន៍ និងគ្រូឧទ្ទេសវិទ្យាស្ថានដែលជាគ្រូដឹកនាំ និងលើកកម្ពស់ការធ្វើបទបង្ហាញរួមគ្នាក្នុងសន្និសីទថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងការបោះពុម្ពផ្សាយផ្សាយលទ្ធផលស្រាវជ្រាវដែលគ្រូបង្រៀននៅសាលាអនុវត្តន៍ជាអ្នកនិពន្ធទី១ និងគ្រូឧទ្ទេសដឹកនាំនៅវិទ្យាស្ថានជាអ្នកនិពន្ធបន្ទាប់។

• ការលើកកម្ពស់ការចូលរួមរបស់គណៈគ្រប់គ្រង និងគ្រូបង្រៀននៅសាលាអនុវត្តន៍ក្នុងកម្មវិធីផ្សេងៗរបស់វិទ្យាស្ថានដូចជា បាឋកថាដោយវាគ្មិនកិត្តិយសមកពីបណ្តាស្ថាប័នពាក់ព័ន្ធនានា ពិធីពិព័រណ៍ស្នាដៃគរុនិស្សិត សន្និសីទស្រាវជ្រាវអប់រំ ជាដើម។

ជាមួយគ្នានេះដែរ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញក៏បាននិងកំពុងយកចិត្តទុកដាក់ខ្លាំងលើការផ្សារភ្ជាប់វិទ្យាស្ថាននឹងសាលាអនុវត្តន៍ ដោយបានកំណត់ជាគោលដៅសំខាន់ក្នុងផែនការយុទ្ធសាស្ត្រ២០២៤-២០២៨ ក្នុងការលើកកម្ពស់ គុណភាពនិងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀន។



សាលាបឋមសិក្សាអនុវត្តន៍រាជធានីភ្នំពេញ និងអនុវិទ្យាល័យអនុវត្តន៍(អូរបែកក្អម)

ក្នុងន័យនេះ សាលាអនុវត្តន៍គឺជាថ្នាលសម្រាប់គរុសិស្ស-គរុនិស្សិតអនុវត្តវិធីបង្រៀន និង សាកល្បងវិធីសាស្ត្របង្រៀនថ្មីៗក្នុងអំឡុងពេលសិក្សានៅសាលាគរុកោសល្យ និងក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យ ព្រមទាំងការអនុវត្តការសិក្សាស្រាវជ្រាវប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។

## ២.៨. កិច្ចសហប្រតិបត្តិការ

ក្នុងគោលបំណងធានាគុណភាពនៃការបណ្តុះបណ្តាលគ្រូឱ្យមានភាពប្រកួតប្រជែង ទាំងក្នុងប្រទេស តំបន់ និងពិភពលោក ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាសាលាគរុកោសល្យនានាបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ក្រសួងពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍនានា គ្រឹះស្ថានអប់រំសាធារណៈ និងឯកជនទាំងគ្រឹះស្ថានដែលអនុវត្តកម្មវិធីសិក្សាជាតិ និងអន្តរជាតិ និងសាកលវិទ្យាល័យនានាដែលទទួលបន្ទុកក្នុងការងារអប់រំគ្រូបង្រៀនទាំងក្នុង និងក្រៅប្រទេស ដើម្បីទទួលបានកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ ទាំងការគាំទ្រលើការលើកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីសិក្សា គុណវុឌ្ឍិគ្រូឧទ្ទេស និងគ្រូបង្រៀន វិធីសាស្ត្របង្រៀន ការរៀបចំផែនការយុទ្ធសាស្ត្រ និងចែករំលែកឧត្តមានុវត្តន៍ជាដើម ។ល។

ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡាបានទទួលការគាំទ្រទាំងថវិកា និងបច្ចេកទេស ពីមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក អង្គការយូណេស្កូ (UNESCO) អង្គការយូនីសេហ្វ (UNICEF) ទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) អង្គការខេប (KAPE) អង្គការVSO ។ល។

រីឯ សាលាគរុកោសល្យនីមួយៗក៏បានចុះអនុស្សរណៈយោគយល់គ្នាជាមួយដៃគូ និងគ្រឹះស្ថានឧត្តមសិក្សាជាតិ និងអន្តរជាតិនានា ដើម្បីលើកកម្ពស់ការអប់រំគ្រូបង្រៀននៅតាមគ្រឹះស្ថានឱ្យមានគុណភាពប្រកួតប្រជែងទាំងកម្រិតថ្នាក់ជាតិ តំបន់ និងពិភពលោក។





កិច្ចសហការជាមួយដៃគូ

## ៣. ផែនការឆ្ពោះទៅកាន់ឆ្នាំ២០៣០ និង២០៥០

ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ធ្វើកំណែទម្រង់ និងអភិវឌ្ឍសាលាគរុកោសល្យទាំងផ្នែកគោលនយោបាយ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្នែកទន់ ក៏ដូចជាលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន គុណវុឌ្ឍិ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងជីវភាពរស់នៅរបស់គ្រូបង្រៀន ដើម្បីធានាឱ្យបាននូវគុណភាពអប់រំសម្រាប់ប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា។

សមិទ្ធផលទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបន្តអនុវត្តផែនការរបស់ក្រសួង ក្នុងការបន្តធ្វើកំណែទម្រង់សាលាគរុកោល្យ ក៏ដូចជាធ្វើវិក្រឹតការគ្រូបង្រៀនផងដែរ។ ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡាមានគោលបំណង៖

១. ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យទាំង៤ ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យ ដោយច្របាច់បញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត រួមមាន កណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ តាមគំរូបាត់ដំបង និងរាជធានីភ្នំពេញ ដោយប្រើប្រាស់ថវិការដ្ឋ និងដៃគូអភិវឌ្ឍក្នុងគោលបំណងបណ្តុះបណ្តាលគរុសិស្ស-គរុនិស្សិតតាមកម្មវិធី១២+៤ ឬបរិញ្ញាបត្រ+១ ដើម្បីឱ្យគ្រូបង្រៀនកម្រិតបឋមសិក្សា និងអនុវិទ្យាល័យមានគុណវុឌ្ឍិយ៉ាងហោចណាស់កម្រិតបរិញ្ញាបត្រ ព្រមទាំងទទួលបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ក្នុងទិសដៅធានាឱ្យបាននូវគុណភាពនៃការអប់រំក្នុងសតវត្សរ៍ទី២១នេះ

២. លើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសឱ្យមានគុណវុឌ្ឍិយ៉ាងហោចណាស់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានបទពិសោធក្នុងការបង្រៀន ព្រមទាំងមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ភាសាបរទេស និងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស

៣. បន្តផ្តល់ឋានៈសាស្ត្រាចារ្យសម្រាប់គ្រូឧទ្ទេស

៤. ប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូឱ្យមានស្តង់ដាសាលាគរុកោសល្យគំរូ

៥. ពិនិត្យឡើងវិញតួនាទីសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ដោយផ្តោតលើការធ្វើវិក្រឹតការគ្រូបង្រៀន

៦. ប្រែក្លាយសាលាអនុវត្តន៍ឱ្យទៅជាសាលាស្តង់ដាគំរូ និងក្លាយជាសាលារៀនជំនាន់ថ្មី

៧. អនុវត្តវិធីសាស្ត្របង្រៀន រង្វាយតម្លៃ និងការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការរៀន និងបង្រៀន ដែលអាចឱ្យសិស្សអភិវឌ្ឍបំណិនគិតប្រកបដោយវិចារណញ្ញាណក្នុង ការដោះស្រាយបញ្ហាប្រចាំថ្ងៃ

៨. លើកកម្ពស់ការអប់រំឌីជីថលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលគ្រូ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការបង្កើត APPS សម្រាប់អំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង

និងសាលាឌីជីថល ដើម្បីឱ្យគ្រូធ្វើស្វ័យសិក្សាដោយខ្លួនឯង

៩. ជំរុញការបណ្តុះបណ្តាលប្រឹក្សាគរុកោសល្យ សម្រាប់ការចុះគាំទ្រដល់គ្រូបង្រៀន

១០. លើកកម្ពស់ការផ្តល់មគ្គុទ្ទេសក៍ និងការផ្តល់ប្រឹក្សាអាជីព ដោយរៀបចំមុខងារគ្រូផ្នែកមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ដើម្បីជួយសិស្សក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ ការសិក្សារៀនសូត្រ និងការអភិវឌ្ឍអាជីព

១១. លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលាចំនួន ១៣០០០នាក់ ក្នុងរយៈពេលពីឆ្នាំ ២០២៤ ដល់ ២០២៧

១២. បណ្តុះបណ្តាលមិនផ្តល់ក្របខណ្ឌ សម្រាប់ជំនួសគ្រូបង្រៀនជាប់កិច្ចសន្យា និងឈានឆ្ពោះទៅអនុវត្តអាជ្ញាបណ្ណវិជ្ជាជីវៈគ្រូបង្រៀនដើម្បីដោះស្រាយតម្រូវការគ្រូបង្រៀនដែលមានគុណវុឌ្ឍិស្របតាមស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក៏ដូចជាជានាឱ្យបាននូវគុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រប់កម្រិត និងគ្រប់ទីកន្លែង

១៣. កែលម្អគោលនយោបាយស្តីពីគ្រូបង្រៀន

១៤. អនុវត្តគន្លងអាជីពគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក៏ដូចជាបញ្ចូលគន្លងអាជីពគ្រូឧទ្ទេស និងគ្រូជាប់កិច្ចសន្យាទៅក្នុងគន្លងអាជីពគ្រូបង្រៀន

១៥. បន្តបណ្តុះបណ្តាលគ្រូអប់រំពិសេស ជំនាញផ្នែក គ ថ្លង់ ពិការភ្នែក និងខ្សោយសតិបញ្ញា

១៦. អភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែងឱ្យមានឧត្តមភាពក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនពហុភាសា សម្រាប់ជនជាតិដើមភាគតិច ដោយក្នុងនោះមានពូង កាវ៉ែត គ្រឹង ទំពួន ព្រៅ និងចារ៉ាយ។

ការចូលរួមបំពេញការងារប្រកបដោយការទទួលខុសត្រូវ ពីសំណាក់បុគ្គលិកអប់រំគ្រប់កម្រិតថ្នាក់ ដោយមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងជំរុញឱ្យគោលបំណងនេះអាចសម្រេចទៅបាន ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាឱ្យមានការប្រកួតប្រជែងទាំងក្នុងតំបន់ និងពិភពលោក ពោលគឺជានាឱ្យបាននូវការកសាងមូលធនមនុស្សស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល និងនាំកម្ពុជាឆ្ពោះទៅការអភិវឌ្ឍយ៉ាងពិតប្រាកដនៅឆ្នាំ២០៥០។

**«លើកកម្ពស់សមត្ថភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
គឺលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន»**

# គន្ថនិទ្ទេស


ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១០

ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ, ២០១០

ក្រសួងអប់រំ យុវជន និងកីឡា, គោលនយោបាយស្តីពីគ្រូបង្រៀន, ២០១៣

ក្រសួងអប់រំ យុវជន និងកីឡា, គោលនយោបាយស្តីពីគ្រូបង្រៀនៈ ផែនការសកម្មភាព, ២០១៥

ក្រសួងអប់រំ យុវជន និងកីឡា, គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ, ២០១៧

ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដានាយកសាលារៀន, ២០១៧

ក្រសួងអប់រំ យុវជន និងកីឡា, ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨

ក្រសួងអប់រំ យុវជន និងកីឡា, ផែនការសកម្មភាពស្តីពីការអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តសម្រាប់ទិសដៅរយៈពេល ៥ ឆ្នាំ (២០១៩-២០២៣), ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ២០១៩-២០២៣, ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា, ក្របខ័ណ្ឌ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀន និងនាយកសាលា, ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា, ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនកម្រិតបញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ, ២០២១

ក្រសួងអប់រំ យុវជន និងកីឡា, សៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំៈ មគ្គុទេសក៍ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនៅកម្ពុជា, ២០២១

ក្រសួងអប់រំ យុវជន និងកីឡា, ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០២១

ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីណែនាំប្រតិបត្តិក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០២១

ក្រសួងអប់រំ យុវជន និងកីឡា, សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាម គ្រឹះស្ថានសិក្សាសាធារណៈ, ២០២១

ក្រសួងអប់រំ យុវជន និងកីឡា, ការអនុវត្តសាកល្បងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (អវប) និងប្រព័ន្ធHRMIS ៖ របាយការណ៍វាយតម្លៃចុងអាណត្តិ, ២០២២

វិទ្យាស្ថានជាតិអប់រំ, វិទ្យាស្ថានជាតិអប់រំៈ ផែនការយុទ្ធសាស្ត្រ ២០២១ -២០២៥, ២០២២

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, របាយការណ៍ស្តីពីលទ្ធផលសម្រេចបានធៀបនឹងផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩-២០២៣) ទិសដៅឆ្នាំសិក្សា ២០២៣-២០២៤, ២០២៣

ក្រសួងអប់រំ យុវជន និងកីឡា, ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនៈ ការអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ, ២០២៣

ក្រសួងអប់រំ យុវជន និងកីឡា, ផែនការសកម្មភាព គោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ ២០២៤-២០៣០, ២០២៣

ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ, ២០២៤

ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដាសាលាគរុកោសល្យគំរូ, ២០២៤

ក្រសួងអប់រំ យុវជន និងកីឡា, ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនអនុវិទ្យាល័យតាមប្រព័ន្ធ បញ្ញាបត្រ + ១, ២០២៤

ក្រសួងអប់រំ យុវជន និងកីឡា, របាយការណ៍លទ្ធផលការស្ទង់មតិស្តីពីការអនុវត្តកម្មវិធីអប់រំ គ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិកម្រិតបរិញ្ញាបត្រអប់រំ ១២+៤ នៅសាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ, ២០២៤

Ministry of Education, Youth and Sport, Teacher Education Provider Standards, 2016




ឧបត្ថម្ភការបោះពុម្ពដោយ

UNESCO

unesco

GPE

Transforming Education

ISBN: 978-9924-947-85-1